**OMI0006**

## មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ ញ៉ឹម សឿន ភេទប្រុស អាយុ៥៨ឆ្នាំ**

**មុខងារជំនាន់ខ្មែរក្រហម ៖ "ពេទ្យកងទ័ព"**

**សព្វថ្ងៃនៅភូមិស្វាយចេក ឃុំថ្មាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២**

**សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា**

**០២:០៩:១៧**

**០០:៥៩:៥០**

**៧៣ទំព័រ**

ដារ៉ា : អ៊ីចឹងដូចខ្ញុំជំរាបរួចមកហើយអ៊ីចឹង ដើម្បីកុំឲ្យខាតពេលវេលា ខ្ញុំសុំសម្ភាសន៍លោកពូ ។ ហើយជាដំបូងនេះខ្ញុំសុំស្គាល់ឈ្មោះលោកពូសិន ។ លោកពូឈ្មោះអីដែរ?

សឿន : ឈ្មោះ ញ៉ឹម សឿន ។

ដារ៉ា : មានឈ្មោះហៅក្រៅអីផ្សេងទៀតដែរពូ?

សឿន : អត់ អត់មានទេ ។

ដារ៉ា : ប្រើប្រាស់តែឈ្មោះនឹងតែមួយតែម្ដង?

សឿន : បាទ ។

ដារ៉ា : ពូអាយុប៉ុន្មានឆ្នាំដែរឆ្នាំនេះ?

សឿន : គិតអាយុពិតយើងវា ៥៨ហើយ ។

ដារ៉ា : ពូកើតឆ្នាំណា ឬក៏ពូកើតឆ្នាំអីដែរ?

សឿន : ខ្ញុំឆ្នាំ១៩៥៥ ហើយ ។

ដារ៉ា : ជាឆ្នាំខ្មែរយើងពូឆ្នាំអីដែរពូ?

សឿន : ឆ្នាំមមែ ។

ដារ៉ា : ស្រុកកំណើតកើតជាលោកពូនៅឯណាដែរ?

សឿន : ខ្ញុំពីមុននោះយើងគេហៅភូមិដូនចិន ដូនចិន ឃុំបុស្សខ្នោរ ស្រុកចំការលើ ខេត្តកំពង់ចាម ។

ដារ៉ា : ហើយសព្វថ្ងៃលោកពូនៅភូមិអី ឃុំអីដែរ?

សឿន : នៅភូមិស្វាយចេក ។

ដារ៉ា : ឃុំថ្លាត អ៊ីចឹង?

សឿន ៖ ឃុំថ្នាត ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។

ដាវ៉ា ៖ សព្វថ្ងៃលោកពូមានតួនាទីមុខងារអីដែរនៅក្នុងរដ្ឋាភិបាល?

សឿន ៖ ខ្ញុំសព្វថ្ងៃនឹងស្មៀនឃុំ ។

ដាវ៉ា ៖ ស្មៀនឃុំថ្នាតពូ?

សឿន ៖ បាទ ។

ដាវ៉ា ៖ ហើយស្មៀនឃុំពូបានឆ្លងកាត់វគ្គបណ្តុះបណ្តាលអីដែរ?

សឿន ៖ ខ្ញុំបានឆ្លងកាត់ច្រើនដែរ បណ្តុះបណ្តាលខាងផ្នែកច្បាប់ និតិវិធីដោះស្រាយទំនាស់ ភូមិបាល ការងាររគ្រប់គ្រងរដ្ឋាបាល សិទ្ធិមនុស្ស អំពើហឹង្សា ។

ដាវ៉ា ៖ ច្រើនដែរពូ?

សឿន ៖ បានច្រើន ។

ដាវ៉ា ៖ ជាប់ជាស្មៀនឃុំហ្នឹងតាំងពីឆ្នាំណាមកដែរ?

សឿន ៖ ឆ្នាំ២០០២ ។

ដាវ៉ា ៖ ហើយតាមរយៈការប្រលង ឬក៏យ៉ាងម៉េច?

សឿន ៖ តាមរយៈការប្រលង ។

ដាវ៉ា ៖ តាំងពីពូធ្វើការមក មានការដូរឃុំ ឬមេឃុំអីប៉ុន្មានអ្នកដែរហើយ?

សឿន ៖ អត់ទាន់ដែរមានដូរទេមេឃុំ ។

ដាវ៉ា ៖ នៅទេណោះ?

សឿន ៖ បាទនៅ ។

ដាវា ៖ នៅតែមេឃុំតែមួយដដែល គាត់ឈ្មោះអីពីមុនមក?

សឿន ៖ ឈ្មោះ អុច ដាង ។

ដាវ៉ា ៖ ចុះលោកពូក្រុមគ្រួសារលោកពូ ត្រូវជាគ្រួសារលោកពូឈ្មោះអីដែរលោកពូ?

សឿន ៖ ឈ្មោះ គង ចាន់នី ។

ដាវ៉ា ៖ គាត់អាយុប៉ុន្មានឆ្នាំហើយ?

សឿន ៖ អាយុ៤៣ឆ្នាំ ។

ដាវ៉ា ៖ ហើយគាត់ធ្វើអីដែរ?

សឿន ៖ ធ្វើស្រែធ្វើចំការ ។

ដាវ៉ា ៖ ហើយគាត់អ្នកស្រុកណាដែរ?

សឿន ៖ នៅចំការលើដែរ ខាងភូមិត្រពាំងឫស្សី ឃុំស្ដី ស្រុកចំការលើ ខេត្តកំពង់ចាម ។

ដារ៉ា : អ្នកចំការលើ ដូចគ្នា ។ ពូមានកូនចៅប៉ុន្មាននាក់ហើយពូ?

សឿន : ៧នាក់ហើយ ។

ដារ៉ា : ប្រុសប៉ុន្មាន ស្រីប៉ុន្មានពូ?

សឿន : ប្រុស៣ ស្រីបួន ។

ដារ៉ា : ហើយបានរៀនសូត្រអីខ្លះដែរ កូនពូប៉ុន្មាននាក់បានរៀនសូត្រ?

សឿន : នៅរៀនសូត្រទាំងអស់ អូរមានគ្រួសារមួយ ហើយទៅធ្វើការអស់ពីរហើយ ចេញធ្វើការ ងារ នៅសល់៥នាក់ ។

ដារ៉ា : ក្នុងចំណោមកូនពូទាំង៧នាក់នឹង មានកូនណាដែលរៀនបានច្រើនជាងគេ បានន័យថារៀន បានថ្នាក់ខ្ពស់ជាគេ?

សឿន : កូនទីពីរ កូនស្រី ។

ដារ៉ា : កូនស្រី រៀនដល់ថ្នាក់ណាដែរ?

សឿន : ដល់ថ្នាក់ទី១១ ថ្នាក់ទី១២ហើយ ប៉ុន្តែចេញទៅធ្វើការងារទៅឈប់រៀនទៅ ។

ដារ៉ា : ទៅធ្វើការងារអីពូ?

សឿន : ទៅកន្លែងកាស៊ីណូ ខាង Dealer ។

ដារ៉ា : អីចឹងកូនពូ នៅតូចៗដែរបើនិយាយទៅ មានគ្រួសារមួយ?

សឿន : បានមានគ្រួសារមួយក្រៅពីនឹងនៅទាំងអស់ ។

ដារ៉ា : មានគ្រួសារនឹងកូនប្រុស កូនស្រី?

សឿន : កូនស្រី ។

ដារ៉ា : ហើយមុនមានគ្រួសារនឹងបានរៀនដល់ថ្នាក់ណាដែរ?

សឿន : អត់បានរៀនទេ ។

ដារ៉ា : មូលហេតុអីដែរពូ?

សឿន : យើងវាក្រពេកនឹងនោះ ខ្វះខាត ហើយណាចូលរៀនទៅក៏វាពិបាកមុខក្រោយ នៅតូចៗ ពេក បានបណ្តុះបណ្តាលបានកូនមួយ ។

ដារ៉ា : ឥឡូវមានកូនណាស្នងដែលរៀនបានខ្ពស់ជាងគេ?

សឿន : មិនមានទេបើចេញ មានតែមួយនឹងប៉ុន្តែវាទៅធ្វើការងារអស់ហើយ ។

ដារ៉ា : ចុះកូនក្រោយៗមកទៀតរៀនថ្នាក់ទីប៉ុន្មាន?

សឿន : នៅទើបតែបានរៀន ទើបតែថ្នាក់ទីមួយទេនេះ ។ មួយទៀតនោះក៏ឈប់ អាពីរ ក៏ឈប់ ។

ដារ៉ា : ម៉េចអីចឹងពូ មានកត្តាអីដែលធ្វើឲ្យឈប់?

សឿន : រឿងខ្លួនវាតែម្តងដែលដេញវាឲ្យទៅ ជូនវាទៅដល់សាលាហើយ អត់រៀនទៀត ចាញ់ចេះ មិនដឹងជាឲ្យជាធ្វើយ៉ាងម៉េច ថ្នាក់ដល់ខាងអគ្គការគេមកជួយដឹកនាំវាយកទៅទៀតក៏អត់ទៅ ពីរនាក់ ស្រីមួយ ប្រុសមួយ អត់ទៅរៀន ។

ដារ៉ា : អាយុប្រហែលប៉ុន្មានឆ្នាំពូ?

សឿន : មួយហ្នឹងអាយុ១៨ឆ្នាំស្រី បើអាប្រុសនោះអាយុ១៦ឆ្នាំហើយ អត់ចូល ។

ដារ៉ា : ធ្លាប់បានចូលសាលាដែរ ឬក៏យ៉ាងម៉េច?

សឿន : បានចូលសាលារៀន ដល់ថ្នាក់ទី៣នោះអាមួយឈប់ហ្នឹង ដល់អាបងវានោះអាហ្នឹងរៀនថ្នាក់ ទី៨ ទៅធ្វើការ ទី៩ទៅធ្វើការ ។

ដារ៉ា : លោកពូជាប្រវត្តិលោកពូមកជាហូរហែរ តាំងពី ពីភូមិពូនៅជូនចិន ជូនអីមកណាលោកពូ ពូ អាចរៀបរាប់ពីប្រវត្តិនឹងមយត្រួសមើលពូ ហេតុអីបានចេញពីភូមិហ្នឹងរហូតមកដល់អន្លង់ វែងយើងហ្នឹង? វាមានប្រវត្តិយ៉ាងម៉េចដែរ ដែលពូឆ្លងកាត់យ៉ាងម៉េចអីយ៉ាងម៉េចដែរពូ?

សឿន : ខ្ញុំនិយាយត្រឹមពីចូលឆ្នាំ៧០ រដ្ឋប្រហារមក ។

ដារ៉ា : បាទ ។

សឿន : ថ្ងៃទី១៨ មិនា ឆ្នាំ១៩៧០ នោះមក ខ្ញុំចូលកងទព័មករហូត ចូលកងទ័ពនឹងក៏បានទៅធ្វើ ពេទ្យ បង ឈិន នឹងគាត់អាណិតខ្ញុំ គាត់ចូលឲ្យធ្វើពេទ្យទៅ បាននៅតាមកងទ័ពរហូតមក (សើច) ធ្វើពេទ្យរហូតមកដល់យើងឆ្នាំ៧៥នឹង វ៉ៃដាច់ភ្នំពេញ វ៉ៃដាច់អីហ្នឹងទៅ ឈ្នះ អាមេរិកមក ក៏នៅតែពេទ្យដដែល នៅមន្ទីរពេទ្យ៤៥០ កងពលហ្នឹងគេដាក់៤៥០ ។ ដល់ ពេលចាប់វាមានសភាពការណ៍នៅភូមិខគួរយើងនឹងទៅ ក៏គេចាប់មេៗហ្នឹងទៅគេថាសមាស ភាពពួកក្បត់ពួអីចឹងទៅ ខ្ញុំហ្នឹងក៏គេបញ្ជូនឲ្យទៅយើងនឹងតាំងក្រសាំង វត្តឃ្នួញយើងនឹង ទៅ នៅនឹងឯងកន្លែងដែលគេលត់ដុំ ទៅកន្លែងនឹងតែបាក់ស្នាបព្រារហូបបាយខ្លួនឯងនឹង ក៏យក ទៅព្រៃសដែរ អីចឹងទៅនឹង នៅនឹងរហូតដល់យើង៧៨ ។ សភាពការតាមព្រំដែននៅខាង កើតនឹងយួនចូលមកនឹង ក៏គេបញ្ជូនទៅឲ្យវ៉ៃនៅនោះឯង បញ្ជូនទៅឲ្យវ៉ៃនៅនោះ ខ្ញុំក៏នៅ តែពេទ្យទៀតទៅ គេឲ្យធ្វើពេទ្យដដែល ធ្វើពេទ្យនឹងរហូតដល់ពេលយើង៧៩ ។ ៧៩នឹង ប៉ុល ពត ចាញ់ទៅនឹងក៏ខ្ញុំទៅដល់ផ្ទះ ទៅនៅផ្ទះបានពីរឆាំដែរ ទាល់តែដល់៨១បានចូល ព្រៃមួយសារទៀត ដោយសារស្រុកវា យើងវាមានសកម្មភាពវាមិនល្អអីចឹងទៅ ចូលមក ព្រៃវិញដដែល បានមកនៅនឹងអន្លង់វែងនឹងរហូតទាល់តែយើងបច្ចុប្បន្ននឹងតែម្តង ។

បូលី : សុំបើរន្ធង់ក្រចកបន្តិចៗ កន្លែងដែលពូថានៅកងពល៤៥០ ស្នួង យាន ថាន យ៉ាន់ គឺថា គេចាប់មួយចង្កោមទាំងអស់គ្នាតែម្តង?

សឿន : បាទ ហ្នឹងហើយបាទ ។

បូលី : ឆ្នាំប៉ុន្មានពូចាប់ហ្នឹង?

សឿន : ចាប់ហ្នឹងយើងចាប់ យើង៧៨កាលហ្នឹង ។

បូលី : ប្រហែល ។

សឿន : ប្រហែល៧៨មិនដឹង ៧៧យើងនៅទេហ្នោះ បានទាល់តែ៧៨នឹងបានយើងចាប់ទាំងអស់ ។

បូលី : បន្ទាប់ពីចាប់ខ្លួនអ្នកទាំងអស់នឹងហើយ កងពល៤៥០ គឺរំលាយចោលតែម្តង?

សឿន : បានរំលាយទៅជា ៦០៣ វិញ ។

បូលី : បាទ អរគុណ ។

ដារ៉ា : អ៊ីចឹងលោកពូ មុនពេលឆ្នាំ៧០នឹងលោកពូបានរៀនសូត្រអីដែរលោកពូ?

សឿន : ខ្ញុំរៀនដល់ថ្នាក់ទី៥ ។

ដារ៉ា : រៀនថ្នាក់ទី៥នឹងរៀននៅសាលាណាពូ?

សឿន : នៅវិទ្យាល័យកំពង់ចាម វិទ្យាល័យយើងពីដើមដាក់វិទ្យាល័យព្រះសីហនុអ្នស កំពង់ចាម បាទ!នឹងហើយ ។

ដារ៉ា : អ៊ីចឹងនិយាយទៅពូរៀនបានច្រើនដែរ ដល់ថ្នាក់ទី៥ពូ?

សឿន : បាទ ។

ដារ៉ា : ទី៥នឹងប្រឡងឌីប្លូមហើយឬនៅពូ? នៅទេពូ?

សឿន : នៅទេ ។

ដារ៉ា : រៀនដល់ឆ្នាំណាថ្នាក់ទី៥នឹង?

សឿន : យើងរៀនបានតិចនឹងយើងនឹង រៀនបានមួយឆ្នាំដែរនឹងបានរដ្ឋប្រហារ បានមួយឆ្នាំជិតនិងប្រឡងចូលទី៤ហើយ (សើច) ។

ដារ៉ា : អ៊ីចឹងពេលដែលមានរដ្ឋប្រហារនឹងបានឈប់?

សឿន : បាទ រដ្ឋប្រហារនឹងបានឈប់ ។

ដារ៉ា : ចុះសភាពការណ៍វាយ៉ាងម៉េចយើងបានអត់អាចបន្តរៀនបានអ៊ីចឹងពូ?

សឿន : យើងនៅនឹងខ្លាចបែកម៉ែបែកឪ ព្រោះអីម្តាយនៅឯណេះ យើងរៀននៅឯកំពង់ចាមឯនោះ អ៊ីចឹងឈប់បណ្តោយទៅ អត់ទៅរៀនទៀត ហើយណាមួយនៅខាងហ្នឹងយួនវៀតកុងវៃចូលមក កំពង់ចាម ដល់វៃចូលមកអ៊ីចឹងទៅ ខ្ញុំរត់ចេញពីនឹងមក មកនៅឯផ្ទះបណ្តោយលែងទៅវិញ គ្រូហៅឲ្យទៅវិញដែរ ប៉ុន្តែអត់ទៅ ទៅ ទៅនឹងចាប់ធ្វើទាហានហើយ (សើច) ជំនាន់នោះ ដល់អ៊ីចឹងយើងថាឃើញគ្រាន់តែយួនវៃចូលមកមិនឈប់ឈរ ទាហាន លន់ នល់ ផាប់

សំបើមណាស់ ខ្ញុំថាអូរមិនកើតទេ ដល់យើងទៅព្រៃ ទៅព្រៃអីចឹងទៅគាត់ ស្គាល់គ្នា បងឈិន នឹងណា ធ្លាប់ស្គាល់គាត់ គាត់នៅកន្លែងរមាស ខាងក្រោយវត្តនរគរ នឹង ស្គាល់ នឹងក៏យកខ្ញុំឲ្យទៅនៅធ្វើពេទ្យ ទៅរៀនពេទ្យកន្លែងនឹងទៅ ។

ដារ៉ា : កាលរៀនពូមានស្គាល់ឈ្មោះលោកគ្រូឈ្មោះអីខ្លះទេ លោកគ្រូរបស់លោកពូអី មានឈ្មោះអីខ្លះពូ?

សឿន : គ្រូ ។

ដារ៉ា : គ្រូបង្រៀនពូ?

សឿន : លោកគ្រូពីវិទ្យាល័យខ្ញុំភ្លេចអស់ហើយ នៅចាំតែលោកនៅបឋម លោកវាច្រើនជំនាន់នឹងមិនសូវចាំឈ្មោះ តាមម៉ោងរបស់គេ វិទ្យាល័យ កាលនេះនឹងខ្ញុំរៀនថ្នាក់កុមារដ្ឋានអីដំបូងខ្ញុំរៀនជាមួយលោកគ្រូ ឃ្វាំង លឹម ស្រៀង ឡើងដល់ថ្នាក់ទី១១ ឈ្មោះអ្នកគ្រូ ក្វាកក្វាន ដល់រៀនចូលថ្នាក់ទី១០ លោកគ្រូ ឃ្វាង លឹម ស្រៀង នឹងគាត់ឡើងទៅបង្រៀននៅថ្នាក់ទី១០ទៀត ដល់ចូលថ្នាក់ទី៩អ្នកគ្រូ ក្វាក ក្វាន នឹងគាត់ឡើងទៅបង្រៀននៅថ្នាក់ទី៩នោះទៀត ជាមួយនឹងអ្នកគ្រូ អេង ឡេង បាទអ្នកគ្រូ អេង ឡេង ពីរនាក់ ទៅនៅរៀននៅនឹង ចូលថ្នាក់ទី៨មកនឹងឈ្មោះអ្នកគ្រូ មុំ ខៀវវណ្ណ ដល់តែឡើងថ្នាក់ទី៧នឹងឡើងមកមុំ ខៀវវណ្ណ នឹងឡើងមកតាមទៀត (សើច) ឡើងរហូត ហើយគ្រូច្រើនទៀតដែរ ស្គាល់ដែរ ឈ្មោះ តា ប៉ាល់ ឈ្មោះ តា សុន លោកគ្រូ សុន នឹងមានពីរ ថ្នាក់ទី១០ មួយកុមារដ្ឋាននោះមួយ ។

ដារ៉ា : ខុសគ្នាពីរនាក់នឹងអ្ហេស?

សឿន : បាទ ឈ្មោះ តា សុន ស្គាល់នៅចាំបានប៉ុណ្ណឹង ប៉ុន្តែគាត់នឹងយ៉ាងម៉េច ស្លាប់អស់ហើយក៏មិនដឹង អីមិនដឹងទៅណាទេ ។

ដារ៉ា : អីចឹងពេលរដ្ឋប្រហារហើយ លោកគ្រូអ្នកគ្រូទាំងអស់នឹងគាត់នៅក្នុងស្រុកភូមិ នៅបង្រៀនក្រោយរដ្ឋប្រហារនឹងតទៅទៀត ឬក៏យ៉ាងម៉េចដែរពូ?

សឿន : គាត់នៅបង្រៀន បង្រៀនរហូត បង្រៀននៅសាលានឹង ព្រោះផ្ទះគាត់នៅជិតៗសាលា នឹងដែរ ។

ដារ៉ា : ហើយលោកពូត្រូវបានគ្រូហៅឲ្យមកចូលរៀនវិញដែរ តែលោកពូអត់មក?

សឿន : បាទ! អត់ទៅ ខ្លាចបែកម៉ែបែកឪ នៅជាមួយម្ដាយ ព្រោះអីខ្ញុំមានតែម៉ែមួយកូនមួយកំព្រា តាំងពីអាយុ៦ឆ្នាំ ហើយខ្ញុំទៅនៅឯវត្តនឹងនៅជាមួយលោកតាជីដូនមួយបង្កើត ។

ដារ៉ា : គាត់ឈ្មោះអីដែរលោកតាហ្នឹង?

សឿន ៖ លោកតា ហួ ទូក នៅវត្តនរគ នឹងឯង ។
ដារ៉ា ៖ នៅក្រុងភូមិដូនចិន នឹងពូ?
សឿន ៖ ទេ នៅវត្តនរគរ កំពង់ចាម ។
ដារ៉ា ៖ ចុះលោកពុក ពូ គាត់ ។
សឿន ៖ គាត់ស្លាប់ ។
ដារ៉ា ៖ គាត់ឈ្មោះអីពូ?
សឿន ៖ ឈ្មោះ ញ៉ឹម អៀម ។
ដារ៉ា ៖ គាត់ស្លាប់?
សឿន ៖ បាទ ស្លាប់តាំងពីខ្ញុំអាយុ៥ឆ្នាំ ដល់អាយុ៦ឆ្នាំ លោកតាខ្ញុំយកទៅនៅវត្តនឹងបណ្ដោយ ។
ដារ៉ា ៖ ចុះម្ដាយលោកពូ?
សឿន ៖ ម្ដាយខ្ញុំគាត់នៅ នៅបនពីរនាក់ ដល់ស្លាប់អស់ប្អូនពីរនាក់នឹងទៀតទៅ នៅសល់ម្ដាយតែឯង ។
ដារ៉ា ៖ ម្ដាយឈ្មោះអីលោកពូ?
សឿន ៖ ឈ្មោះ យ៉ែម រន ។
ដារ៉ា ៖ ហើយបងប្អូនពីរនាក់នឹងមានតាំងពីពូនៅភូមិនៅឃុំនឹងដែរ ឬក៏?
សឿន ៖ បាទ នៅជាមួយគ្នានឹង ទាល់តែស្លាប់ទាំងអស់ ។
ដារ៉ា ៖ បើតាមស្ដាប់ទៅបងប្អូនពូ ពូកូនទីប៉ុន្មានអីចឹង?
សឿន ៖ ខ្ញុំកូនទីមួយ ។
ដារ៉ា ៖ កូនទីមួយ អីចឹងប្អូនពូពីរនាក់ទៀត?
សឿន ៖ បាទ ប្អូនពីរនាក់ទៀតស្លាប់នឹង ។
ដារ៉ា ៖ ស្រី ឬប្រុស?
សឿន ៖ ប្រុសៗទាំងពីរ ។
ដារ៉ា ៖ ប្រុសទាំងពីរ អត់មានកូនស្រីទេ?
សឿន ៖ អត់មានសោះ ។
ដារ៉ា ៖ ហើយស្លាប់ក្នុងជំនាន់ណាពូ?
សឿន ៖ ស្លាប់នឹង ហ៊ឺ យូរហើយតាំងពីខ្ញុំអាយុ ប៉ាខ្ញុំគាត់ស្លាប់ខ្ញុំអាយុ៥ឆ្នាំ មកប្អូនទៀតស្លាប់បន្តទៀត ក្នុង៦ឆ្នាំនឹងស្លាប់អស់ពីរនឹងតែម្ដង ។
ដារ៉ា ៖ មូលហេតុអីជំនាន់នឹងពូ?

សឿន : មិនដឹងជាមូលហេតុអីខ្ញុំមិនសូវចាំដែរដឹងតែស្លាប់ ចាំបានតែប៉ុណ្ណឹងខ្ញុំអីស្លាបចាំបាន ។

ដារ៉ា : ជាជំងឺឬជាអី ឬក៏យ៉ាងម៉េច?

សឿន : ជាជំងឺ បងអាបន្ទាប់ខ្ញុំនឹង អាហ្នឹងកើតបូសនៅក្នុងពោះចាំអីចឹង ហើយមួយទៀតមិនដឹងជាឈឺអីស្លាប់អត់ដឹង អាពៅគេនឹង ។

ដារ៉ា : ដល់ពេលរដ្ឋប្រហារហើយអីចឹងពូមានបានសង្កេតឃើញទេថានៅក្នុងភូមិនឹង នៅក្នុងភូមិពូផ្ទាល់នឹងណា ពេលដែលមានរដ្ឋប្រហារហើយអីចឹង ថាតើសភាពការណ៍ក្នុងភូមិពូវាមានការប្រែប្រួល ឬក៏យ៉ាងម៉េចដែរពូរ?

សឿន : ពេលរដ្ឋប្រហារហើយនឹងមានប្រែប្រួល គាំទ្រយើងសម្តេច នាំគ្នាធ្វើបាតុកម្មប្រឆាំងជាមួយលន់ នល់ កាលហ្នឹង ។

ដារ៉ា : ប៉ុន្តែក្រោយពីបាតុកម្មនឹងហើយអីចឹងទៅវាមានសភាពយ៉ាងម៉េចតទៅទៀតនៅក្នុងភូមិ?

សឿន : រួចទៅយើងខ្លាចអីចឹង យើងក៏នៅសម្ងំស្ងៀមទៅ សម្ងំស្ងៀមរហូតដល់ថ្ងៃទី១៨ ខែ៧ វៀតចូលដល់ភូមិខ្ញុំ ។

ដារ៉ា : ឆ្នាំ៧០នឹងពូ?

សឿន : បាទ ។

ដារ៉ា : ខាងណាវៀតចូលពូ?

សឿន : ខាងខ្មែរក្រហមយើងនៅក្នុងព្រៃ ហើយជាមួយនឹងវៀតចូលមក ។

ដារ៉ា : យួនកាលនឹងពួកអី ពួក?

សឿន : ពួកយៀកកុង ។

ដារ៉ា : អីចឹងសហការជាមួយពួកខ្មែរក្រហមនឹងដែរ?

សឿន : បាទ និងហើយ ។

ដារ៉ា : វៀតចូលមកដល់ភូមិពូ?

សឿន : បាទវៀតចូលមកដល់ ។

ដារ៉ា : វៀតទៅរំដោះបានអត្តពូ?

សឿន : បាន វៀតតែមួយយប់រំដោះបាន បានរហូតដល់ ត្រៅ ឯណោះ មួយយប់នឹង។ រួចទៅបានប៉ុន្មាន ថ្ងៃទី១៩នឹងវៀតបាន ថ្ងៃទី២៧ខ្ញុំមកចូលបណ្តោយ ។

ដារ៉ា : ថ្ងៃប៉ុន្មានពូ ថ្ងៃ២៧?

សឿន : បាទ ២៧ ខែ៧ ។

ដារ៉ា : ៧០?

សឿន  :  បាទ ៧០  បាទចូលមក ។

ដារ៉ា  :  លក្ខណៈចូលនឹងយ៉ាងម៉េចដែរ  មានអ្នកនាំចូលឬក៏យ៉ាងម៉េច?

សឿន  :  ចិត្តយើងចង់ចូល  ណាមួយពូសួរគាត់ថាឲ្យទៅរៀនពេទ្យ  ចង់បានចំណេះដែរ  ទៅបណ្តោយ ទៅរៀន  បាទទៅ  គាត់យកទៅដាក់កន្លែងពេទ្យមែន ។

ដារ៉ា  :  អ្នកណា  ពូសុំប្រាប់ឈ្មោះម្តងទៀតមើល?

សឿន  :  បង  ឈិន ។

ដារ៉ា  :  គាត់ឈ្មោះពេញយ៉ាងម៉េចដែរ?

សឿន  :  ឈ្មោះគាត់ឈ្មោះ  មិនដឹងជាត្រកូលអីខ្ញុំអត់ចាំ  អត់ដឹងទេកាលនឹង  ដឹងតែឈ្មោះ  ឈិន  នឹង ហ្នឹង ។

ដារ៉ា  :  គាត់អ្នកស្រុកណាពូ?

សឿន  :  គាត់អ្នកស្រុកកន្លែងរមាសយើងនៅក្រោយវត្តនរគ  នឹងឯង ។

ដារ៉ា  :  នៅកំពង់ចាមនឹងដែរ?

សឿន  :  នៅកំពង់ចាម  អ្នកបឹងធំ ។

ដារ៉ា  :  ហើយគាត់មានឋានៈស្អីទៅ  បានមានសិទ្ធ?

សឿន  :  កាលនឹងគាត់កាន់កងពលហើយ ។

ដារ៉ា  :  ឈិន?

សឿន  :  បាទ ។

ដារ៉ា  :  កងពលប៉ុន្មានពូ?

សឿន  :  កងពល៤០៣មួយសារនោះ  ភូមិភាគ៣០៤  កងពល៤០៣ ។

បូលី  :  របស់ខ្មែរពូ?

សឿន  :  របស់ខ្មែរ ។

ដារ៉ា  :  ភូមិភាគ  ភូមិភាគ៣០៤  ដល់ពេលកងពល  កងពល៤០៣វិញ?

សឿន  :  បាទ ។

ដារ៉ា  :  អាហ្នឹងក្នុងឆ្នាំ៧០  អីនឹងពូ?

សឿន  :  បាទ ៧០ ។

ដារ៉ា  :  អីចឹងពេលនឹងខ្មែរក្រហមកកើតចេញជាកងពល  កងអីហើយអីចុះ?

សឿន  :  បាទ  បង្កើតកងតំបន់  កងពល  មានតាំងពីនោះមក  ប៉ុន្តែមានតិចដែរទេ  មិនជាច្រើនប៉ុន្មាន ទេ ។

ដារ៉ា : ពូនិយាយថាកងពល៤០៣នេះ អាចដូចថា មានកម្លាំងដូចជាកងពលអីបច្ចុប្បន្នដែរ ឬក៏យ៉ាងម៉េចពូ?

សឿន : មានកម្លាំងដូចគ្នាប៉ុន្តែវាតិច មិនទាន់ពេញលក្ខណៈជាកងពល ។

ដារ៉ា : អាចថាមានប្រហែលជាប៉ុន្មាន?

សឿន : អាចមានត្រឹម៣០០នាក់ប៉ុណ្ណឹង ។

ដារ៉ា : ហើយឈ្មោះ ឈិន នឹងជាប្រធានកងពលហ្នឹង?

សឿន : បាទ ។

ដារ៉ា : ហើយចុះក្រោម ឈិន នឹងមានពីណាទៀតទេ?

សឿន : អាហ្នឹងខ្ញុំភ្លេចហើយ មិនដឹងពីណាខ្លះទេ ព្រោះអីខ្ញុំអត់បាននៅជាប់ហើយក៏មិនសូវជាបានដឹងថាអ្នកណាទៀត ភ្លេចដែរ ទាល់សព្វថ្ងៃនេះ រកនឹកមិនឃើញចាំតែគាត់មួយ ។

បូលី : ខ្ញុំសុំបញ្ជាក់បន្តិចពូ កាលនឹងមុនកាលឆ្នាំ៧០ មក៧៥ កងពលខុត្តរមាន៣ កងពល១ កងពល២ កងពល៣ អីចឹង៤០៣នឹងជាស្អីវិញ?

សឿន : បាទមាន ៤០៣ជាកងពល ។

បូលី : ក្រែងមានកងពលលេខ១ កងពលលេខ២ កងពលលេខ៣ ខុត្តរ?

សឿន : បាទនឹងហើយ ហើយកងពលលេខមួយ នឹងមិនដឹងជាលេខប៉ុន្មាន កងពលលេខពីរនឹងមិនដឹងជាលេខប៉ុន្មានអត់ដឹង ដឹងថាកងពលខ្លួនឯងមិនដឹងជាលេខប៉ុន្មានផង ជំនាន់នឹងណា ។

ដារា : អីចឹងពូពេលពូចូលធ្វើពេទ្យនៅក្នុងឆ្នាំ៧០នឹង គឺអីចឹងពូចូលធ្វើពេទ្យកងទ័ពនៅក្នុងកងពល ៤០៣ អីចឹងហ្នឹង ដឹងតែអីចឹងហ្នឹង ឬក៏?

សឿន : បានចូលនៅនឹងបានតែបន្តិចទេ កងពលនឹងណ៎ា បានគាត់បញ្ជូនឲ្យរៀននៅយើងនៅស្ទឹងណោះ ដល់ចេញទៅមិននៅនឹងកងពលនឹងដដែលទេ ចេញពីកងពលនឹងហើយ គេរៀបចំកងពលទៀតណ៎ា ដាក់ទៅឡើងទៅកងមជ្ឈិម ។

ដារ៉ា : អីចឹងនៅក្នុងឆ្នាំ៧០នឹងដែរ ខែ៧ ខាងមូលដ្ឋានមានរៀនចំ ខាងមូលដ្ឋាននឹងមានរៀបចំជារដ្ឋាបាលមូលអីហ្នឹងម៉េចដែរ?

សឿន : មាន មានរៀបចំអស់ហើយ មានសង្កាត់ យើងហៅសង្កាត់កាលហ្នឹង ។

ដារ៉ា : មានសង្កាត់ មានស្រុក មានតំបន់អីចឹង?

សឿន : បាទ! មាន ។

ដារ៉ា : លោកពូអាចស្គាល់ជាសង្កាត់ ជាស្រុកអីទេ ស្គាល់ឈ្មោះ គ្រាន់តែតួៗថា អាចស្គាល់ឈ្មោះអីចឹងទៅណ៎ា?

សឿន : បាទ ក្មេចអស់ហើយកាលហ្នឹង មិនដឹងពីណាកាន់ស្រុកកាន់តំបន់អីអស់ អីចឹងបានថាអត់មាន សួរចាប់អារម្មណ៍អីសោះ (សើច) អត់សួរដឹងអីទេចូលទៅនឹង ចូលទៅធម្មតាយើងទៅ មិនដឹងគណៈតំបន់ហ្នឹងពីមុនហ្នឹងពីណា បង ស្រេង អីចឹងទៅ បង ស្រេង ឈ្មោះ បង ស្រេង គណៈតំបន់ ។

ដារ៉ា : តំបន់អីគេអាហ្នឹងគេហៅតំបន់?

សឿន : តំបន់អីចឹង លេខហ្នឹងមិនដឹងលេខប៉ុន្មានទេ?

បូលី : នៅក្នុងភូមិភាគណា?

សឿន : ភូមិភាគឧត្តរ ពីមុនហ្នឹង បង ធុច គណៈតំបន់ រួចមកពី បង ធុច គាត់ឡើងទៅមជ្ឈមទៅ ឡើងមក បង ស្រេង គណៈតំបន់ បន្តមកទៀតមកបាន អ៊ំ ពក នេះ ក្រោយគេ ។

ដារ៉ា : តំបន់ជាតំបន់៤១?

សឿន : បាទ៤១អ្ហីកាលហ្នឹង អូរហ្នឹងហើយ៤១ ។

ដារ៉ា : វាមាន៤១ ៤២ ៤៣?

សឿន : បាទ!៤១កាលហ្នឹងតំបន់យើងមុនគេ៤១ ។

ដារ៉ា : អីចឹងភូមិភាគអ្នកណាជាភូមិភាគកាលហ្នឹង? កាលឆ្នាំ៧០នឹង?

សឿន : ភូមិភាគ បង ធុច ។

ដារ៉ា : ចុះមិញពូថា ធុច?

សឿន : ពីមុនគាត់តំបន់មែន ដល់ពេលគាត់ឡើងទៅភូមិភាគទៅ ឡើងមក បង ស្រេង ហ្នឹងហើយ ។

ដារ៉ា : អីចឹងមានន័យថាពេលបង្កើតភូមិភាគ៣០៤នេះ គឺ ធុច ជា ។

សឿន : ជាមេ ។

ដារ៉ា : ជាប្រធានភូមិភាគហើយក្រោយមកបានឲ្យស្រេងមកធ្វើជាគណៈតំបន់ជំនួសនិង ធុច ហ្នឹង?

សឿន : គណៈតំបន់ បាទ គណៈតំបន់មាន អ៊ំ ពក ហ្នឹងក៏គណៈតំបន់ដែរ ។ ខាងកំពង់ចាម ហ្នឹងមិនដឹងសែប៉ុន្មានទេ ។

បូលី : ខ្ញុំសុំបញ្ជាក់កន្លែងនេះបន្តិច កន្លែងកងពល៤០៣មិញហ្នឹងអ្នកាស ដែលពូថា ឈិន លេខា កងពលហ្នឹង ពូដែលឮឈ្មោះ ម៉ែន ម៉េង ទេ?

សឿន : ម៉ែន ម៉េង មិនដែលទេ ។

បូលី : ឈិន ឈ្មោះដើមរបស់គាត់ ម៉ែន ម៉េង?

សឿន : ម៉ែន ម៉េង មិនដែលទេ ឮសួរតែឈ្មោះ ឈិន ហ្នឹងតែម្តង ។

បូលី : ឈិន ឈិន ហ្នឹង ឈិន គាត់លេខាកងពល២របស់ភូមិភាគឧត្តរហ្នឹង ហើយអាចកងពល២ ហ្នឹងកងពល៤០៣ហ្នឹងឯង ។

ដារ៉ា : កងពលទី២ហ្នឹងអ្ន?

សឿន : បាទ ៤០៣ហ្នឹង យើងដល់ក្រោយមក គាត់មិនកាន់នៅ៩២០ហ្នឹង ។

បូលី : ដល់ក្រោយមកដូរទៅជាកងពល៩២០នោះ ។

សឿន : បាទ!ហ្នឹងហើយ ។

បូលី : ដល់ក្រោយមក៤០៣ហ្នឹង ឬកងពលទី២ហ្នឹង ដូរទៅជាកងពល៩២០នោះ ក្រោយឆ្នាំ៧៥

សឿន : បាទនឹងហើយ ។

បូលី : បាទ ដែលមាន ឈិន ជាលេខា ។

សឿន : បាទ ។

បូលី : ហើយ តា ០៦ នេះឡើងក្រោយ ឈិន ពេលចាប់ ឈិន?

សឿន : បាទ ហ្នឹងហើយ ក្រោយក្រោយគេ តា ០៦ ហ់ង ។

ដារ៉ា : អីចឹងពេលដែលពូចូលជាទ័ពនៅខាងពេទ្យអីហ្នឹងណាពូ អាពូ ឈិន ថា ពូ ឈិន គាត់យក ចូលអីចឹង?

សឿន : បាទ ហ្នឹងហើយ ។

ដារ៉ា : ហើយពូថាមានចិត្តចូលដែរ?

សឿន : មានចិត្តចង់ព្រោះចំណេះវិជ្ជាយើងចង់បាន (សើច) ដល់អីចឹងហើយវាមិនសូវគិតរឿងអី គិតតែពីខំប្រឹងរៀនទៅ រៀននោះ ។

ដារ៉ា : ហើយកាលហ្នឹងម៉េចក៏ ពូ ឈិន ហ្នឹងស្គាល់ ពូ ឈ្មោះ ឈិន ហ្នឹងស្គាល់ពូ?

សឿន : ស្គាល់ ស្គាល់តាមរយៈតាខ្ញុំ តាខ្ញុំគាត់អ្នកដឹកឈើចូលព្រៃចូលអីហ្នឹងទៅ ទាក់ទងខ្មែរក្រហម ក្នុងព្រៃណា៎ អីចឹងគាត់ស្គាល់តាខ្ញុំហើយ តានេះតាជីទួត ជីលួតជីលាហើយ ប៉ុន្តែនៅក្បែរ ផ្ទះគ្នាហ្នឹងឯង ។

ដារ៉ា : ប៉ុនគាត់ឈ្មោះអីតាពូ?

សឿន : តាខ្ញុំនោះ ឈ្មោះ មឿង ទុយ កូនគាត់មួយឈ្មោះ មឿង សុផុន ហ្នឹងមួយងាប់នៅនឹង ព្រៃសហ្នឹងឯង ទៅជាមួយបងឈិន ហ្នឹងឯង គេចាប់យកទៅ ទៅជាមួយគ្នា ទៅរកមើល រូបថតមិនដែលឃើញមានសោះ បាត់អត់ឃើញ ។

ដារ៉ា : ឈ្មោះអីពូ?

សឿន : មឿង សុផុន ហៅ ផេង ។ ឈ្មោះជំនាន់នោះគេដាក់ ផេង ។

ដារ៉ា : ទៅជាមួយ ឈិន ហ្នឹង គេចាប់ហ្នឹងអ្ហេស?

សឿន : បាទ ចាប់ទៅជាមួយ ឈិន ហ្នឹង ឆ្នាំ៧៧ ។ មុនចាប់ហ្នឹងជួបខ្ញុំដែរតើ ហើយ បង ឈិន គាត់ផ្ដាំផ្ញើថាឲ្យខ្ញុំរត់មកផ្ទះ ហើយខ្ញុំអត់ទេ ព្រោះអីខ្ញុំអត់មានពាក់ព័ន្ធពួកគាត់ ហើយអីចឹង អ្ហែងនៅទៅ ខំប្រឹងកសាងខ្លួន ហើយខ្ញុំក៏ហៅអាផុន ហ្នឹង អាផុន ហៅ ផេង ហ្នង ខ្ញុំហៅថា នៅនឹងហើយកុំទៅ វាថា ហ៊ឺ ទៅជាមួយបង ក្រែងលោមិនអី ទៅតាមមើលគាត់ ដល់ទៅបាត់ឈឹងបណ្ដោយ បាត់ឈឹង ពេលខ្ញុំទៅយកទៅដាក់នៅព្រៃសហ្នឹងហើយ គេឲ្យពួកខ្ញុំហ្នឹង ដូចថាយកពួកខ្ញុំទៅគំរាមអ្ហាស ឲ្យទៅមើល ហើមស្ពឹងអស់អីចឹងទៅ យកទៅមើលម៉េចស្គាល់ សូម្បីតែអ្នកដែលស្គាល់យើងនៅក្នុងហ្នឹងក៏អត់ហ៊ានហៅយើងដែរ គេអត់ហ៊ានហៅបើគេអ្នកដែលអាណិតស្រឡាញ់យើងទៀត គេអត់ហៅយើងតែម្ដង តែកាលណាហៅគឺមានពាក់ព័ន្ធហើយ ដល់អីចឹងដើរទៅហ្នឹងឃើញ គ្រាន់តែបានតែសម្លឹងមើលមុខយើងអីចឹង ហើយយើងមើលទៅគេវិញ អត់ស្គាល់ទេ វាហើមខ្លួនអស់ទៅ ដល់អីចឹងមិនដឹងអ្នកណាអ្នកណី ហើយអត់មានសួរនាំថា អូរ ផុន នៅត្រង់ណា បងឈិន នៅត្រង់ណា អត់ហ៊ានសួរទេ ។

ដារ៉ា : ចុះពេលពូដែលចូលជាពេទ្យហើយពូត្រូវបានបញ្ចូលមករៀន មករៀនសូត្រវិជ្ជាពេទ្យហ្នឹងអ្ហេស?

សឿន : បាទ ។

ដារ៉ា : នៅថានៅកំពង់ស្ពឺ?

សឿន : មិនមែនទេ នៅស្ពឺ ស្រែវាល យើងនេះ ។

ដារ៉ា : នៅស្ពឺ ស្រែវាល នៅស្រុកអី ឃុំអីពូ?

សឿន : ខ្ញុំរៀននៅស្ពឺហ្នឹង ឃុំស្ពឺតែម្ដង ឃុំស្ពឺស្រុកចំការលើ ខេត្តកំពង់ចាម ។

ដារ៉ា : រៀនប៉ុន្មានខែប៉ុន្មានឆ្នាំពូ?

សឿន : ខ្ញុំរៀនមួយឆ្នាំ ពេទ្យបឋម ។

ដារ៉ា : ពេលបញ្ជូនពូទៅរៀនហ្នឹងតែម្នាក់ឯងពូ ឬពីហ្នឹងទៅ?

សឿន : ពីរនាក់ ពីរនាក់ ដេង ។

ដារ៉ា : ពីរនាក់ឈ្មោះ ដេង ហ្នឹង?

សឿន : បាទ ។

ដារ៉ា : ហើយរៀនហ្នឹង រៀនមុខវិជ្ជាអីខ្លះ?

សឿន : រៀនមុខវិជ្ជាជំងឺទូទៅ ពេទ្យបឋមហ្នឹង ជំងឺទូទៅ មិនទាន់បានរៀនអីជ្រៅជ្រះទេ ។

ដារ៉ា : ហើយមានគ្រូពេទ្យគ្រូអី ជាគ្រូមកបង្រៀនច្បាស់លាស់ទេគ្រូពេទ្យ?

សឿន : មាន បង ណា ឈ្មោះ បង ណា ហ្នឹង ឈ្មោះដើមគាត់មិនដឹងជាស្អីទេ ណា ប៉ិនគាប្រពន្ធគាត់ក៏ភ្លេចទៀត គាត់នៅហ្នឹងស្វាយទៀប យើង តា អុង នេះ ស្វាយទៀប បុស្សខ្នោរ ស្វាយទៀប ស្រុកចំការលើ បុស្សខ្នោរ ។

ដារ៉ា : គាត់ជាប្រធានពេទ្យឬក៏គាត់ជា?

សឿន : គាត់ជាប្រធានពេទ្យហ្នឹង ។

ដារ៉ា : ប្រធានពេទ្យហើយបង្រៀន?

សឿន : បាទ បង្រៀន ។

ដារ៉ា : បង្ហាត់បង្រៀនដែរ?

សឿន : បាទ ពេទ្យគាត់តាំងពីយើងជំនាន់ ពីជំនាន់តានោះមកអួស ។

ដារ៉ា : ជំនាន់ សម្តេចតា?

សឿន : បាទ ជំនាន់ សម្តេចតា ។

ដារ៉ា : ពេទ្យហ្នឹងហៅពេទ្យអីគេកន្លែងនឹង?

សឿន : ពេទ្យហ្នឹង ពេទ្យភូមិភាគដែរ ។

ដារ៉ា : ពេទ្យភូមិភាគហ្នឹង?

សឿន : បាទ ពេទ្យភូមិភាគ ។

ដារ៉ា : ភូមិភាគ៣០៤?

សឿន : បាទ ភូមិភាគ៣០៤នឹង ខាងឧត្តរហ្នឹងតែម្តង ។

ដារ៉ា : ដែរមានទីតាំងនៅឃុំស្ទឹ?

សឿន : នៅឃុំស្ទឹ ។

ដារ៉ា : ហើយមានជាសិក្ខាកាមអីទៅរៀនប៉ុន្មាននាក់ៗដែរ?

សឿន : ច្រើនដែរហ្នឹងអួស បុគ្គលិកនៅហ្នឹងតែម្តងហ្នឹង ទៅរៀនជាបុគ្គលិកបណ្តោយ អត់មានសិក្ខាកាម គឺជាស្តែងផ្ទាល់ហ្នឹង ជាបុគ្គលិកបណ្តោយហ្នឹងឯង ទៅហ្នឹងដកចេញមកតាមទ័ពក៏ដកទៅ ដកចេញតែតាមតំបន់តាមសង្កាត់អីក៏ដកទៅ អ្នកណាចេះស្ទាត់ហើយណា ដកចេញមករើសបញ្ចូលថែមទៀតទៅ ។

ដារ៉ា : ហើយពេលរៀនមួយឆ្នាំហ្នឹង មានរៀនជាវិជ្ជាពេទ្យសុទ្ធតែហ្នឹង ឬក៏មានជាវគ្គនយោបាយបំពាក់បំប៉នគោលជំហរនយោបាយអីផ្សេងៗទេ?

សឿន ៖ មិនមានទេ មិនមានអីទេ បើបំពាក់បំប៉នខាងផ្នែកនយោបាយ អាហ្នឹងគេប្រជុំហ្នឹង ល្ងាចឡើងយើងប្រជុំគ្នា បានបំពាក់បំប៉នផ្នែកនយោបាយ

ដារ៉ា ៖ ប្រជុំអាហ្នឹងប្រជុំជារៀងរាល់ថ្ងៃ ឬក៏អាចចន្លោះពេល?

សឿន ៖ ចន្លោះពេល ពេលបីថ្ងៃប្រជុំម្ដង ហើយក្រោយពីបីថ្ងៃហ្នឹងគឺយើងប្រជុំតាមពួករបស់យើង អ្នកស ៣ ៣ ៣ អ្នកស មកប្រជុំរាល់ថ្ងៃអាហ្នឹង អាហ្នឹងប្រជុំកសាងគ្នា តិទៀន ស្ដីយតិទៀន ៗ

ដារ៉ា ៖ អាហ្នឹងកសាងយ៉ាងម៉េច បើតែបីនាក់គ្នាយើង? ឧបមាថាបីនាក់អីចឹង?

សឿន ៖ តែបីនាក់ហ្នឹងក៏យើងប្រជុំបានដែរ ៗ

ដារ៉ា ៖ ហើយនិយាយពីស្អីខ្លះទៅពូ?

សឿន ៖ និយាយលើកពីបញ្ហាគុណវិបត្តិរបស់យើង គុណសម្បត្តិរបស់យើង យើងលោកលាតត្រដាងជូនតែទាំងបីនាក់ទៅ តែលើកទាំងអស់គ្នាអីចឹងទៅ ហើយក៏ពីរនាក់ទៀតក៏សាងយើងទៅជួយ ជំរុញយើងកែប្រែយើងទៅណា ៗ

ដារ៉ា ៖ អាហ្នឹងមានជាការប្រជុំមួយក្រុមបីនាក់ហើយ មានរាយការណ៍ឡើង?

សឿន ៖ បាទរាយការណ៍ទៅក្រុម ហើយដល់ទៅ៥ថ្ងៃយើងប្រជុំក្រុមអីម្ដងទៅ ដល់ទៅកន្លះខែយើងប្រជុំក្នុងអង្គភាពម្ដងទៅ ពេលប្រជុំអីចឹងបានគេបំពាក់បំប៉នខាងផ្នែកនយោបាយហ្នឹងទៅ ៗ

ដារ៉ា ៖ អីចឹងពេលដែលពូរៀនពេទ្យមួយឆ្នាំហ្នឹងហើយ ពូមានប្រសាសន៍ពីខាងដើមថាពូត្រូវបានបញ្ជូនមកកងទ័ព មកកងពល៤០៣វិញ ៗ

សឿន ៖ បាទ

ដារ៉ា ៖ មកនៅពេលហ្នឹង កងពល៤០៣ហ្នឹងមានមូលដ្ឋានមានអីច្បាស់លាស់ឬនៅ នៅក្នុងភូមិអី ឃុំអីដែរ?

សឿន ៖ មាននៅបុស្សខ្នោរហ្នឹងតែម្ដង ៗ មានតាំងមន្ទីរពេទ្យកងពលបណ្ដោយ ៗ

ដារ៉ា ៖ ចុះអាកន្លែងសាលារៀនទៅជាយ៉ាងម៉េចវិញបើអីចឹង?

សឿន ៖ សាលារៀនមួយជំនាន់នោះកំពុងតែរ៉ៃហ្នឹងអត់មានអីទេ សាលារៀនជំនាន់នោះណា៎ ៗ

ដារ៉ា ៖ ចង់និយាយសាលាពេទ្យនេះ អាសាលាពេទ្យភូមិភាគដែលពូទៅរៀននោះណា៎?

សឿន ៖ អូរ នៅរៀនតាមផ្ទះធម្មតាដាក់ស្លែងហ្នឹង ប្រើការងារដាក់ស្លែងបណ្ដោយ ហើយយប់ឡើងហើយយប់ឡើងបានយើងទៅរៀនខាងផ្នែកទ្រឹស្ដី ពេលថ្ងៃអនុវត្តន៍ដាក់ស្លែង យប់រៀនទ្រឹស្ដីមួយម៉ោងពីរម៉ោង ៗ

ដារ៉ា ៖ ពេលដែលរៀននៅសាលាពូមានអារម្មណ៍បែបណាដែរ នៅពេលហ្នឹង? ដូចថា មានអារម្មណ៍ ជាការភិតភ័យ ក្នុងការប្រព្រឹត្តកំហុសអីនៅពេលហ្នឹង ពេលដែលកំពុងរៀនក្នុងពេទ្យហ្នឹង ។

សឿន ៖ បាទមាន កាលហ្នឹងវាកំហុសដែលយើងមួយជំនាន់ៗថាខ្លាំងជាងគេ គឺរឿងសីលធម៌ហ្នុង តែមានបញ្ហាអារឿងស្រីញីហើយគឺអត់បានហ្នុង រ៉ៃចោលក្វាម មានអារម្មណ៍អីចឹងដែរ តែប៉ុណ្ណឹង ។

ដារ៉ា ៖ តែមួយហ្នឹងទេ?

សឿន ៖ បាទ តែមួយហ្នឹងទេកាលហ្នឹង អត់ទាន់មានអារម្មណ៍អីច្រើនទេ អត់ទាន់មានអារម្មណ៍អីបែកច្រើនទេ ទាល់មកយើង ៧៨ ៧៩ ហ្នឹង បានមានអារម្មណ៍ ៧៧ ៧៨ អាដេញជាច់ភ្នំពេញហើយហ្នឹង បានមានអារម្មណ៍បែកច្រើនណាស់ អារម្មណ៍មួយអាយុជីវិតរបស់យើងដល់ពេលយើងដឹងថាសភាពការណ៍ហ្នឹងមើលទៅវាពិបាកពេកអីចឹងទៅ អារម្មណយើងវិលអីចឹងទៅនឹកឃើញថា មិនរស់ថ្ងៃណា ម្លោះយើងរង់ចាំតែថ្ងៃរាប់ហ្នុង ។

ដារ៉ា ៖ អីចឹងពេលដែលរៀននៅសាលាពេទ្យហ្នឹង មានពេទ្យទាហានហ្នឹងជាប្រុសជាស្រីអីរៀនជាមួយគ្នាហ្នឹងដែរ?

សឿន ៖ បាទមាន ។

ដារ៉ា ៖ រៀនជាចម្រុះ?

សឿន ៖ បាទចម្រុះគ្នា ។

ដារ៉ា ៖ ហើយមានឃើញជាករណីជាក់ស្តែងដែរ អំពីការខុសសីលធម៌ខុសអីក្នុងពេលដែលរៀនពេទ្យហ្នឹង លោកពូ?

សឿន ៖ មាន មានឃើញដែរតើ ។

ដារ៉ា ៖ ឃើញយ៉ាងម៉េចដែរពូ?

សឿន ៖ ឃើញបើវាទាក់ទងអីចឹងទៅចាប់យកទៅបាត់ទៅ មិនដឹងទៅណា ។

ដារ៉ា ៖ អាចក្នុងករណីណាមួយជាក់ស្តែង ពូអាចលើកជាមុខបុគ្គលណា ពាក់ព័ន្ធរឿងហ្នឹង?

សឿន ៖ អត់បានចាំឈ្មោះទេ ។ មិនចាំឈ្មោះទៀត ។

ដារ៉ា ៖ តែពូប្រាកដថាមានអីចឹង?

សឿន ៖ បាទ មានជំនាន់ហ្នឹងមាន ។

ដារ៉ា ៖ ចុះពេលពូមកនៅក្នុងកងពល៤០៣វិញហ្នឹងថាមូលដ្ឋានកងពលនៅបុស្សខ្នោរអីចឹងពូ?

សឿន ៖ បាទ ។

ដារ៉ា : អាហ្នឹងជាការងារអីយ៉ាងម៉េច អីតទៅទៀតពូ?

សឿន : ការងារខ្ញុំនៅមន្ទីរហ្នឹង គឺមានព្យាបាលជំងឺយុទ្ធជន ឈឺគ្រុន របួសអីណា មានព្យាបាលប៉ុណ្ណឹង ហើយក៏ប្រជាជន ។

ដារ៉ា : មានប្រជាជនអាចមកចូលព្យាលបាលបានដែរ?

សឿន : បាទ ព្យាបាលបាន ហើយក្នុងស្រុកក្នុងភូមិសុទ្ធតែបងប្អូនទៀតផង ហើយអ្នកស្គាល់ក៏ច្រើននៅក្នុងស្រុកយើងហើយហ្នឹង ប៉ុន្តែពេលដែលយើងព្យាបាលឲ្យប្រជាជនអីចឹងទៅ វាមានបញ្ហាដែរ ។

ដារ៉ា : បញ្ហាយ៉ាងម៉េចទៅ?

សឿន : បញ្ហាយើងប្រើប្រាស់ថ្នាំហ្នឹង គឺវាមានរឿងដែរហ្នឹងណា យើងប្រើថ្នាំសម្រាប់តែកងទ័ពហើយប្រជាជនយើងអត់មានឲ្យប្រើ អាហ្នឹងយើងមានចិត្តវាមិនដាច់ គ្នាឈឺចង់ងាប់ចង់រស់អីចឹង យើងមិនជួយមើលគ្នាវាមិនកើត អីចឹងទៅយើងមើលទៅ ហើយថ្នាំហ្នឹងបើយើងផ្ញើហ្នឹង ជនកាលថ្នាំវាមានតាមថ្នាក់របស់វាទៀតណា៎ យើងប្រើថ្នាំតែមិនស្រួលហ្នឹងគេស្តីឲ្យយើងសព្វបែបយ៉ាងទាំងអស់ ថ្នាំណាសម្រាប់ប្រើគេកម្មាភិបាលអីចឹងទៅ មានអីចឹងទៀតអ្ហាស គេស្តីឲ្យយើងណាស់ ហើយខ្ញុំបើថា បើជំងឺវាត្រូវតែប្រើហើយ យើងទុកសម្រាប់កម្មាភិបាលអត់ឈឺម៉េចកើត ម៉េចវាមិនប្រើអីចឹងអ្ហាស ខ្ញុំចេះតែជិនះ អាជិនះហ្នឹងហើយដែលតែងតែគេរករឿងយើងកាន់តែខ្លាំង ប៉ុន្តែវាមិនអី ផ្ញើទៅវាមិនកើត ។

ដារ៉ា : អាថ្នាំប្រភេទយ៉ាងម៉េចដែលគេសម្រាប់កម្មាភិបាល ថ្នាំប្រភេទយ៉ាងម៉េចដែលមិនមែនសម្រាប់កម្មាភិបាលអីចឹងណាពូ?

សឿន : បាទ យើងប្រើវាតាមកម្រិត យើងកុំឲ្យប្រើហួសហេតុពេក វាមិនមែនថ្នាំណាសម្រាប់អ្នកណា៎ ដូចថាយុទ្ធជនយើងប្រើកម្រិតណា កម្មាភិបាលយើងឲ្យប្រើកម្រិតណាអីចឹងទៅណា៎ ។

ដារ៉ា : អាហ្នឹងសំដៅទៅលើគុណភាពថ្នាំឬក៏យ៉ាងម៉េច?

សឿន : យើងមិនមែនសំដៅទៅលើ នឹងហើយសំដៅទៅលើគុណ អ្ហ នឹងក៏គុណភាពថ្នាំដែរដូចគ្នាទេ យើងប្រើដូចថាវាតិចទៅណា យុទ្ធជន បើកម្មាភិបាលយើងព្យាបាលថ្នាំច្រើនទៅណា អារបៀបថាពង្រឹងសុខភាពយុទ្ធជនអ្ហាស នឹងហើយ គោលបំណងគេគឺចង់ពង្រឹងសុខភាព ។

ដារ៉ា : ពង្រឹង?

សឿន : ហ្នឹងហើយពង្រឹងសុខភាព ឲ្យវាទ្រុឌទ្រោម កុំឲ្យវាមានកម្លាំងអីចឹងទៅណា៎ ។

ដារ៉ា : ម៉េចអីចឹង?

សឿន ៖ មិនដឹងគេ មិនដឹងធ្វើម៉េច ហើយគ្រាន់តែគេនឹងគេមិននិយាយប្រាប់យ៉េងទេ ប៉ុន្តែខ្ញុំយល់អីចឹង បើធ្វើ បើប្រើថ្នាំរបៀបហ្នឹងហើយមានតែដូវនឹង ។

ដារ៉ា ៖ ជាទូទៅច្រើនតែថ្នាំអីដែលប្រើជំនាន់នឹងពូ?

សឿន ៖ កាលហ្នឹងយើងកងទ័ពមិនមានថ្នាំអីប៉ុន្មានទេ ទាល់តែមកឆ្នាំ៧៣បានមានថ្នាំស្លូចេញខ្លួនឯងថ្នាំគ្រាប់ ធ្វើជាថ្នាំគ្រាប់ខ្លួនឯង ថ្នាំដបខ្លួនឯង មានតើ ដាក់ដប អាដបទឹកក្រូចយើងហ្នឹង ប៉ុន្តែខ្ញុំមិនសូវប្រើទេ ព្រោះអីថ្នាំហ្នឹងវា ចាក់ទៅច្រើនតែដំបៅក្បាយ ខ្ញុំអត់ដែរប្រើទេ ខ្ញុំមកដល់ខ្ញុំលួចដាក់បូមចាក់ៗឲ្យវាច្រើនទៅ បូមចោលៗទៅ បូមឲ្យគេឃើញអីចឹងទៅ អាណិតគ្នាដំបៅអីទៅ ខ្លះដំបៅឡើងអស់ហើយកំប៉េះគូទហ្នឹង ។

ដារ៉ា ៖ ពេលព្យាបាលអីម្តងៗពូអាចមានអារម្មណ៍ ជាការភិតភ័យ ឬក៏មានអារម្មណ៍យ៉ាងណា នៅពេលដែលព្យាបាលរំបួសទ័ពក៏ដោយ ប្រជាជនក៏ដោយអីចឹងអ្នកស ជាលទ្ធផលរបស់វាអ្នកសថាតើពេលហ្នឹងពូមានអារម្មណ៍យ៉ាងម៉េចដែរ? ប្រសិនជាថាការព្យាបាលទៅវាមិនបានជាឬក៏យ៉ាងម៉េចនោះ?

សឿន ៖ យើងមានអារម្មណ៍ដែរ មានអារម្មណ៍ប៉ុន្តែវា មានអារម្មណ៍ភិតភ័យមួយខ្លាចគេសម្លាប់ មានអារម្មណ៍មួយទៀតការប្រើប្រាស់ថ្នាំវាច្រើនពេកក៏គេស្តីឲ្យយើង យើងភ័យដែរណ៎ា ហើយដូនកាលព្យាបាលឲ្យប្រជាជនអីចឹងទៅក៏យើងមានការភិតភ័យ ដូចខ្ញុំបញ្ជាក់ខាងដើមអីចឹងតែយើងប្រើថ្នាំពាសវាលពាសកាលទៅគេស្តីឲ្យយើងហើយ តែមិនស្រួលៗហ្នឹងគេលីលកហើយ (សើច) ។

ដារ៉ា ៖ ហើយមាននៅក្នុងកងពលមានពេទ្យប៉ុន្មាននាក់ពូ?

សឿន ៖ មានបុគ្គលិក៤នាក់ មកនៅជាមួយខ្ញុំ មានកងពលមិនសូវជាមានស្អីច្រើប៉ុន្មាន អកជំងឺមួយខែមានពីរ-បីនាក់អីចឹងទៅ ព្រោះអីសំខាន់គឺពេទ្យនៅតាមកងនឹងដែលបានព្យាបាលនៅតាមកង កាត់គទៅមិនអីទេ បើអាខ្លះខ្លាំងបានបញ្ជូនដលយើង ។

ដារ៉ា ៖ អីចឹងមានតែបួននាក់ទេពេទ្យមួយកងពលហ្នឹង?

សឿន ៖ បាទមានបួននាក់ ។

ដារ៉ា ៖ មានឈ្មោះអីខ្លះពូដឹងទេ មកនៅជាមួយពូ?

សឿន ៖ អាហ្នឹងមានឈ្មោះ ហៀង អត់ស្គាល់ត្រកូលគេទេកាលហ្នឹង ។ ហៀង មួយ តុង នោះមួយ អឿ មួយទៀត ហើយនិង អា ផេង នោះមួយ ។

ដារ៉ា ៖ អីចឹងទាំងអស់បូកទាំងពូ ៥?

សឿន ៖ ៥ បាទ ។

ដារ៉ា : អាហ្នឹងសម្រាបពេទ្យភូមិភាគផ្ទាល់?

សឿន : ទេ កងពលទេ

ដារ៉ា : មានពេទ្យភាគគេទៀតទេ ឬយ៉ាងម៉េច?

សឿន : ពីនឹងទៅមានសេនាធិការ សេនាធិការទៅបានភូមិភាគទៀត ។

ដារ៉ា : អីចឹងពេទ្យហ្នឹងអត់មានឆ្លងបានទេ?

សឿន : អត់ឆ្លងបានទេ ។

ដារ៉ា : ពួកម្រិតត្រឹមតែនៅកងពល?

សឿន : បាទ នៅកងពល បើយើងព្យាបាលមិន យើងអត់មានលទ្ធភាពព្យាបាលគេបញ្ជូនទៅ ដាក់ទៅកន្លែងសេនាធិការក៏បាន កន្លែងភូមិភាគក៏បាន ។

ដារ៉ា : ពេលហ្នឹងភូមិភាគ៤០៣ហ្នឹងមានបែងចែកជាវរសេនាធំ វរសេនាតូចតទៅទៀតទេពូ?

សឿន : មាន ។

ដារ៉ា : បែងចែកទៅជាវរសេនាធំអីខ្លះ? អាចចាំបានទេ?

សឿន : វរសេនាធំកាលហ្នឹងមិនដឹងពីណាខ្លះពីឆ្នាំ៧០ ។

ដារ៉ា : តែដំបូងសុំជាលេខ ឬក៏ឈ្មោះវរសេនាធំ មានប៉ុន្មាន?

សឿន : អត់ទាន់ដឹងទេកាលហ្នឹង អត់ចាំ ទាល់តែដល់ឆ្នាំ៧៣ ៧៤បានមានវរៈសេនាធំហ្នឹង បានដឹងតែលេខហ្នឹង ។

ដារ៉ា : អីចឹងដល់ឆ្នាំ៧៤ហ្នឹង វរសេនាធំមានប៉ុន្មាន?

សឿន : កងពលមានបីវរសេនាធំ ចាំតែឈ្មោះលេខមិនចាំ ។

ដារ៉ា : ឈ្មោះអីខ្លះពូ?

សឿន : មាន បង អែម នោះមួយ បង អែម ជាមួយ បង ដាត ហើយក្រោយពីនឹងទៀត បង សូ ។

ដារ៉ា : សូ ជាមួយអ្នកណា?

សឿន : បង សូ ជាមួយពីណាទេនេះ ភ្លេចឈ្មោះទៅ រកនឹកមិនឃើញ ។

ដារ៉ា : បន្ទាប់មក?

សឿន : ហើយវរសេនាធំមួយទៀតក៏ភ្លេចឈ្មោះទៀត បីវរសេនាធំភ្លេចអស់ហើយ ។

ដារ៉ា : ខ្ញុំឆ្ងល់អីចេះ ថាហេតុអីបានជាពូចាំឈ្មោះមនុស្ស បែរជាអត់ចាំវរសេនាធំវិញទ៎ពូទ៎?

សឿន : អត់ អត់សូវចាប់អារម្មណ៍រឿងហ្នឹង ។

ដារ៉ា : ដោយសារពូធ្វើការទាក់ទងជាមួយវរសេនាធំនឹង ជាមួយបុគ្គលនឹងកងវរសេនាធំ ឬក៏យ៉ាងម៉េច?

សឿន : ខ្ញុំវាមិនសូវជាមានការទំនាក់ទំនងយ៉ាងម៉េចទេ ហើយក៏វាដូចថាមិនសូវជាចាប់អារមណ៍ម៉េចសោះ ហើយណាមួយនឹកឃើញថា ព្រួយគិតតែរឿងការពារតែខ្លួនឯង អត់គិតអីទេមែនថានិយាយត្រង់ បានភ្លេចនឹង ហើយណាមួយយើងវាមិនសូវជាអ្នកចងចាំបានច្រើនទៀតណាភ្លេច ភ្លេចច្រើនណាស់ កាលនៅតែជាមួយក្នុងកងពលរាល់ថ្ងៃពីជំនាន់នោះ រាល់ថ្ងៃម៉េច សួរថាវរសេនាធំនេះលេខប៉ុន្មាន វរសេនាធំនេះលេខប៉ុន្មានទៀត ក៏ខ្ញុំអត់ចាំ មកពីយើងមិនចាប់អារម្មណ៍ ។

ដារ៉ា : អីចឹងមានន័យថា ពូជាពេទ្យនៅកងពលនឹងអត់អាចមកព្យាបាលឆ្លងមកវរសេនាធំ វរសេនាតូចទេឬក៏យ៉ាងម៉េច?

សឿន : យើងនៅក្នុងកងពលអត់ចុះទៅទេ ទាល់តែវរសេនាធំនឹងបញ្ជូនមកឲ្យយើង មានពេទ្យទៅតាមវរសេនាតូច វរសេនាធំរបស់គេមួយទៀតណា បាទគេបញ្ជូនមកឲ្យយើង បានយើងព្យាបាល ឬមួយក៏យើងហៅពេទ្យគេហ្នឹងមកប្រជុំអីចឹងទៅ ប្រជុំយើងប្រជុំមានអីទេ ប្រជុំពីរឿងការងារពេទ្យរបស់យើងតែប៉ុណ្ណឹងឯង ។

ដារ៉ា : ចុះមានដាឋានៈមានដាឋានៈពេទ្យអីដែរនៅក្នុងកងពល?

សឿន : អត់មានទេ យើងមានតែនៅក្នុងកងទ័ពហ្នឹង អត់មានថ្នាក់អី អត់មានមន្ទីរអ៊ីទៀតអត់ទេមានតែមានដេកនៅជាមួយទ័ពហ្នឹងតែម្ដង ។

ដារ៉ា : ចុះក្នុងចំណោមពូហ្នឹងអ្នកណាគេ៤នាក់ទៀត អ្នកណាគេគ្រប់គ្រងពេទ្យនេះ?

សឿន : ខ្ញុំ ។

ដារ៉ា : អីចឹងពូ?

សឿន : បាទ ។

ដារ៉ា : អីចឹងពូជា គេហៅថាប្រធានពេទ្យសំរាប់កងពល?

សឿន : បាទ ។

ដារ៉ា : ហើយលក្ខណៈជ្រើសរើសពូជាប្រធានពេទ្យនឹង ដោយពូយ៉ាងម៉េចបាន គេជ្រើសរើសជាប្រធានពេទ្យកងពល? ព្រោះចេះជាងគេ ឬក៏យ៉ាងម៉េច?

សឿន : បងឈិន ហ្នឹង គាត់អ្នកចាត់តាំងបណ្ដោយ ប៉ុន្តែចេះ ចេះហើយ ព្រោះអីយើងមាន រៀនបានថ្នាក់ក៏ខ្ពស់ ហើយគេមិនសូវចេះអក្សរទៀត ។

ដារ៉ា : អូរអ្នកផ្សេងៗទៀតអ្ហពូ?

សឿន ៖ បាទ អត់សូវបេះទេ ។

បូលី ៖ ប្រធានពេទ្យកងពល ឬក៏ប្រធានពេទ្យភូមិភាគ?

សឿន ៖ កងពលទេ ។

ដារ៉ា ៖ ប្រធានពេទ្យកងពល?

សឿន ៖ ហ្នឹងហើយតាមកងទ័ព ។

ដារ៉ា ៖ ពេលនឹងឈ្មោះ ឈិន គាត់ជាលេខាកងពលមិនណេះ?

សឿន ៖ បាទ ។

ដារ៉ា ៖ ហើយដោយសារថាពូមានទំនាក់ទំនងជាមួយ ឈិន នឹងទៅក៏បានធ្វើជាប្រធានពេទ្យកងពល?

សឿន ៖ បាទ ពេលគាត់ផ្លាស់មកហ្នឹង ពេលបងឈិន គាត់ផ្លាស់ទៅខ្ញុំមកនៅក្នុងកងពលយើង៣០៤ ដដែលហ្នឹងឯង ប៉ុន្តែផ្លាស់មេផ្លាស់អ្នកដឹកនាំ ខ្ញុំនៅជាមួយឈ្មោះ ជាប ជាប នឹងស្រុកកំណើតគាត់នៅហាន់ជ័យ ខាងលិច(៤៦ៈ០៥ ស្តាប់មិនបាន) ជាប មារ អែម មារ អែម ឡើងដុតពីវរសេនាធំយើងមក គាត់ឡើងមកកងពលដែរ នឹងនៅជាប់រហូតហើយ ។

បូលី ៖ កងពលប៉ុន្មាន?

សឿន ៖ នៅកងពលទី៣នឹងដដែល មកកងពលទីបី ចេញពី បង ឈិន មកនៅជាមួយ ជាប នឹងឯង ។

បូលី ៖ អាហ្នឹងពូនិយាយឆ្នាំណា?

សឿន ៖ ឆ្នាំ៧១ ចេញពី បង ឈិន យើងនៅជាមួយបងឈិន ឆ្នាំ៧០ ដល់៧១ នៅជាមួយបង ជាប ដល់ឆ្នាំ៧៣បានទៅនៅជមួយបងសួង តាមដំណាក់របស់វា ដល់៧៣ហ្នឹងទៅជាបុគ្គលិកគេ វិញហើយខ្ញុំ នៅមន្ទីរពេទ្យ (សើច) ប៉ុន្តែខាងផ្នែកបញ្ចេកទេសវះកាត់ ។

ដារ៉ា ៖ នៅឆ្នាំ៧៣?

សឿន ៖ បាទ ៧៣ខាងវះកាត់ រហូតដល់យើងដាច់ហ្នឹងហ្នងវះកាត់នៅមន្ទីរទេព្យ ។

បូលី ៖ ពូរៀបរាប់ម្តងទៀតបានទេ សមាជិករបស់ បង ឈិន? មាន ជាប

សឿន ៖ ទេអាហ្នឹងមេកងពលហ្នង ប្តូរពី បង ឈិន ទៅ មក បង ជាប ខ្ញុំចេញពី បង ឈិន ហើយមកនៅជាមួយ បង ជាបនេះ ។

ដារ៉ា ៖ អីចឹងបើនិយាយពីរៀបរាប់មកឡើងវិញឲ្យវាច្បាស់លាស់អ្វាសពូ ក្នុងឆ្នាំ៧០នេះ ពូបានធ្វើជាពេទ្យកងពល តែអត់ទាន់បានទៅរៀនទេមែនទេនេះ

សឿន ៖ បាទ ។

ដារ៉ា : នៅជាមួយឈ្មោះ ឈិន កងពល៤០៣?

សឿន : បាទ ។

ដារ៉ា : ពូថាទៅរៀនបានមួយឆ្នាំ មានន័យថាវាអាចដល់ឆ្នាំ៧១ ខែ៧អីហ្នឹង ។

សឿន : បាទហ្នឹងហើយ ។

ដារ៉ា : អីចឹងពេលពូត្រឡប់មកពីរៀនវិញ ពូអត់មានបាននៅជាមួយ ឈិន ទេ ។

សឿន : អត់ទេ នៅជាមួយ បងដាប ។

ដារ៉ា : នៅជាមួយឈ្មោះ ដាប ឈ្មោះ អែម នេះ ដែលជាលេខាកងពល ៤០៣ ។

សឿន : បាទ ។

ដារ៉ា : ហើយពេលហ្នឹង នៅក្នុងឆ្នាំ៧១ហ្នឹង ឈិន ទៅផ្លាស់ចេញ ។

សឿន : បាទ ។

ដារ៉ា : អីចឹង ឈិន ទៅណាពេលហ្នឹងពូ?

សឿន : គាត់មកនៅយើងខាងស្រុកព្រៃឈរ ហ្នឹង គេហៅសណ្តែកទ្រព្យ សណ្តែកទ្រព្យ ចុងព្រៃ យើង យើង តាគោក ។

ដារ៉ា : គាត់មកធ្វើជាស្អីវិញ?

សឿន : កងពលដដែល ។

ដារ៉ា : កងពលដែរ?

សឿន : បាទ ពង្រីក អាហ្នឹងគេពង្រីក គេមានកងពលទៅគេចេះតែពង្រីក កងទ័ពចាមច្រើនដែរណា៎ ។

បូលី : កងពលលេខប៉ុន្មានពេលគាត់មកហ្នឹង?

សឿន : អត់ដឹងទេកាលនោះ ។

បូលី : ដឹងតែមេកងពលដដែលអ្ហេស?

សឿន : បាទ ដឹងតែកងពល ។

ដារ៉ា : ហើយដល់ពេលនេះទៅ កងពល៤០៣នេះ គឺឈ្មោះ ដាប ហើយនិង អែម ។

សឿន : បាទ ហ្នឹងហើយ ។

ដារ៉ា : ជាលេខា អនុលេខាអីចឹងទៅ ។

សឿន : ដល់ ៧៣-៧៤នោះ បានផ្លាស់ចេញពីនឹងមក មកនៅជាមួយបងសួង ។

ដារ៉ា : ដល់ពេលដែលឆ្នាំ៧១ ពូមកនៅជាមួយ ដាប ជាមួយ អែម នេះពូជាប្រធានពេទ្យដែរ ឬក៏យ៉ាងម៉េចពូ?

សឿន ៖ ជាប្រធានពេទ្យដដែល ។

ដារ៉ា ៖ អ៊ីចឹងដល់ឆ្នាំ៧៣បានពូផ្លាស់មកនៅជាមួយឈ្មោះ សួងនេះ នៅហ្នឹងកងពលអីហើយ?

សឿន ៖ នៅហ្នឹងកងពលទីបចូល កងពលយើងហ្នឹង ៤៥០ ។

ដារ៉ា ៖ ពេលហ្នឹងពូមានប្រសាសន៍ថា ពូមិនមែនជាប្រធានពេទ្យទៀតទេ?

សឿន ៖ បាទ ជាបុគ្គលិកគេម្ដង ។

ដារ៉ា ៖ ពូជាបុគ្គលិកពេទ្យ តែធ្វើការខាងផ្នែកឯកទេសវះកាត់?

សឿន ៖ បាទ ។

ដារ៉ា ៖ ចុះពេលដែលនៅជាមួយមានអ្នកការគេជាអនុលេខា ហើយអ្នកណាគេជាសមាជិកពូអ្ហេស?

សឿន ៖ អាហ្នឹងមាន មានបងអែម នោះ គាត់ឡើងជា អូរបងអែម នៅវរសេនាធំដដែល នៅតែ បងសួង នឹងប្រធាន ហើយបងហ៊ាន បងយ៉ាន់ បងយាន បីនាក់នឹងឯងកាលហ្នឹង ។

ដារ៉ា ៖ ហើយចុះពេទ្យនឹង អ្នកណាជាប្រធានពេទ្យវិញនៅអ៊ីចឹង?

សឿន ៖ ឈ្មោះ ម៉ែន ។

ដារ៉ា ៖ ម៉ែន ។

សឿន ៖ បាទ ម៉ែន ប្រធាន វុទ្ធ អនុ វុទ្ធ ហ្នឹងអ្នកខាងយើងនៅក្រចេះ ប៉ុន្តែមិនដឹងភូមិអីកាល ហ្នឹង ។

ដារ៉ា ៖ ពី៧៣ដល់ឆ្នាំណាទៀតដែលពូមានការផ្លាស់ប្តូរ ឬក៏ ធ្វើការនៅណាទៀត?

សឿន ៖ ខ្ញុំធ្វើការរហូតដល់មកយើងឆាំ៧៨ហ្នឹង ។

ដារ៉ា ៖ សុំកាត់ពូបន្តិច ដល់ឆ្នាំ៧៥ ដល់ឆ្នាំ៧៥យ៉ាងម៉េច?

សឿន ៖ ៧៥ហ្នឹងខ្ញុំនៅតែពេទ្យរហូត នៅក្នុងមន្ទីរពេទ្យ ។

ដារ៉ា ៖ អ៊ីចឹងបានន័យថាពូនៅក្នុងមន្ទីរពេទ្យជាមួយ កងពលរបស់ សួង កងពល៤០៥នេះ ។

សឿន ៖ ៤៥០ ។

ដារ៉ា ៖ អូរកងពល៤៥០ ពី៧៣ រហូតដល៧៥ហ្នុងពូ?

សឿន ៖ បាទ៧៥ដល់៧៧ ៧៨ នឹងទៀត តរហូតមក ។

ដារ៉ា ៖ អ៊ីចឹងពេលដែលវៃចូលដល់ភ្នំពេញនេះ ពូចូលមកជាមួយកងពលហ្នឹងដែរឬក៏យ៉ាងម៉េច?

សឿន ៖ នៅជាមួយកងពលហ្នឹងដែរ រហូត ។

ដារ៉ា ៖ ជាប់ជាមួយកងពលហ្នឹងហ្នុងអ្ហេស?

សឿន ៖ បាទ ។

ដារ៉ា ៖ ចូលមកដល់ភ្នំពេញចូលតាមច្រកណាពូ?

សឿន ៖ ចូលតាមផ្លូវលេខ៥ តាម ។

ដារ៉ា ៖ ផ្លូវជាតិលេខ៥?

សឿន ៖ បាទ តាមយើងពីប្រាំងចំរេះហ្នឹងទៅរហូត ព្រែកក្ដាម ទៅរហូត ទៅដល់យើងត្រឹមជ្រោយចង្វារ ត្រឹមហ្នឹង ។

ដារ៉ា ៖ ចូលមកចូលនៅក្នុងថ្ងៃណាអីហ្នឹង?

សឿន ៖ ចូលមកចូលថ្ងៃ ថ្ងៃហ្នឹងថ្ងៃប៉ុន្មាន១៧ អី១៧មេសាហ្នឹងឯង ។

ដារ៉ា ៖ ព្រឹកឬក៏ល្ងាចចូលមកដល់ភ្នំពេញ?

សឿន ៖ ចូលល្ងាច ខ្ញុំចូលដល់ ម៉ោង៤ល្ងាច ។

ដារ៉ា ៖ មួយកងពលហ្នឹងហ្នងអ្ហេស ចូលដល់ម៉ោង៤ល្ងាច ឬក៏យ៉ាងម៉េច?

សឿន ៖ បើកងពលគេចូលតាំងពីព្រឹកម្ល៉េះ ម៉ោង៦កន្លះចូលដល់ ស្ពានជ្រោយចង្វារពួកខ្ញុំ ប៉ុន្តែខ្ញុំចូលក្រោយគេពេទ្យ ចូលម៉ោង៤បានចូលទៅ ។

ដារ៉ា ៖ ពេលដែលចូលដល់ភ្នំពេញតាមជ្រោយចង្វារថាមកដល់ម៉ោង៤ហ្នឹង ពូមានបានសង្កេតឃើញទីក្រុងហ្នឹងយ៉ាងម៉េចដែរ សភាពប្រជាជនហ្នឹងយ៉ាងម៉េចដែរពេលហ្នឹង?

សឿន ៖ ប្រជាជនគាត់ មើលទៅសភាពគាត់វា ដូចជានឹកគ្នា អាណោចអាធមរបស់គាត់ដែរណាស្ដាយផ្ទះស្ដាយសម្បែងគាត់ គាត់ចេញទៅ ហើយអាខ្លះក៏ស្លាប់នៅតាមផ្លូវ គាត់ភ័យគាត់ខ្លាច ចេញទៅ ច្រើនណាស់ចេញទៅតាមនឹងទៅរហូតទៅ ចេញទៅហ្នឹងមិនអីដឹកជញ្ជូនទេ គ្រាន់តែទៅតែខ្លួនៗទៅ ខ្លះ ហើយពេលហ្នឹងម៉ូតូឡានអីដកចេញខ្ទេចអស់ហើយ ឲ្យដើរទៅតែខ្លួនៗទេ ទៅយកទៅតែមួយខ្លួនៗ ហើយខ្លះក៏មានចាប់អាចិនទៅ តាមចាប់ដោយមិនដឹងថាកងទាហាន មិនមេទាហាន មេអីចាប់យកទៅវិញទៅ ហើយហ្នឹងពួកសិល្បៈ អ្នកចម្រៀងអ្នកអីហ្នឹងចាប់ ចាប់បានគេចអីចឹងទៅរស់ទៅ ខ្លះក៏គេចាប់យកទៅវិញទៅ ។

ដារ៉ា ៖ ពូដឹងអីចឹងដឹងតាមរបៀបយ៉ាងម៉េច តាមការប្រជុំឬក៏ឃើញដាក់ស្ដែង?

សឿន ៖ ដឹងតាមយើងឃើញដាក់ស្ដែងតែហង ។

ដារ៉ា ៖ ពេលចូលមកអ្ហេស?

សឿន ៖ បាទ ឃើញដាក់ស្ដែងតែម្ដង ។ ដឹងថាមេទាហាន ចាប់យកទៅដាក់នៅកន្លែងមន្ទីរពេទ្យ ខ្ញុំថា អូរងាប់ហើយយកមកដាក់អីហ្នឹងអូស មិនដឹងដាក់ឯណាមកដាក់ទៅ យើងចូលទៅដល់អីចឹងយើងតាំងមន្ទីរពេទ្យនៅផ្ទះប្រជាជនមួយអីចឹងទៅណា ហើយឃើញគេចាប់បណ្ដើរមកអីចឹងទៅ គិចនេះចាប់បណ្ដើរមក គិចនោះចាប់បណ្ដើរមកអីចឹងទៅ អង្គុយមើលតែគេអីចឹងទៅ ។

ដារ៉ា : ជាមេទ័ពនៅក្នុងរបប លន់ នល់ ពូអេ្ហស?

សឿន : ហ្នឹងហើយ ។

ដារ៉ា : ម៉េចអាចដឹងថាជាមេទ័ពជាអីបាន?

សឿន : យើងដឹង ដោយសារតែពួកហ្នឹងគេមកនិយាយប្រាប់យើងដែរ អ្នកចាប់ហ្នឹងអ្ហាស យើងសួរថា ធ្វើអី ដូចថាស័ក្តិ៥អីចឹងទៅ ចាប់មកទៀតទៅសួរថា គាត់ធ្វើអីទៅ ខ្លះថាផ្នែកស្ពីប្រធានអី សិល្បៈអីទៅអាហ្នឹង អ្នកបញ្ចូលសម្លេងអីចឹងទៅ ខ្ញុំនឹកក្នុងចិត្តថា ចុះចាប់ធ្វើអីបើទុកឲ្យពួកហ្នឹងទៅច្រៀងរកទៅទៀតទៅវាម៉េច ។ គេមិនមាត់ តែនឹកក្នុងចិត្តណា៎ គេយកទៅ ទៅ យកទៅហ្នឹងមានតែនៅហ្នឹងវត្តសំរោងអីចឹងទៅ ។

ដារ៉ា : វត្តសំរោង នៅក្នុងភូមិអី ឃុំអីទៅ?

សឿន : សំរោងនឹងមិនដឹងជាភូមិអី ភូមិសំរោងយើងហ្នឹង សំរោងយើងទៅអាផ្លូវយើង ព្រែកក្អ្អាហ្នឹងអ្ហាស យើងបត់ទៅមិនចូលទៅខាងតាមវត្តសំរោង ហ្នឹងតាមហ្នឹង ។

ដារ៉ា : ចុះទីតាំងពូនៅហ្នឹង? ចុះពូអត់បានចូលមកដល់ភ្នំពេញទេអីចោះ?

សឿន : ខ្ញុំចូលមកដល់ជិតស្ពានជ្រោយចង្វារ ហើយនៅត្រង់កន្លែងផ្ទះមួយនឹង ផ្ទះ ផ្ទះមេព្រៃមិនដឹងឃើញមានកំភ្លើងបាញ់សត្វ ឃើញមានអីអាហ្វង់ឌីណុង លេប៉ូ ច្រើនណាស់ នៅផ្ទះគាត់នឹងសម័យក្រាល សម័យអី ឃើញថាផ្ទះគាត់ ខ្ញុំនៅហ្នឹងហ្នង ។

ដារ៉ា : អត់បានចូលមកដល់កណ្តាលទីក្រុងភ្នំពេញអីទេអ្ហេស?

សឿន : អត់បានចូលទៅទេ ព្រោះខ្លាចសភាពការគេនោះវាវឹបក ម៉េចម៉ាទៅយើងរត់រួច ដល់ចូលជ្រៅពេកហ្នឹងចេះតែខ្លាច វាមិនទាន់ថាយើងរៀបរយស្រួលបួល ហើយខាងកងពលខ្ញុំហ្នឹងគេឲ្យចូលតែត្រឹមនឹងដែរ គេមិនឲ្យចូលដល់កណ្តាលក្រុងទេ ឲ្យបានត្រឹមតែស្ពានជ្រោយចង្វារតែប៉ុណ្ណឹងឯង ក្រៅពីហ្នឹងទៀត កងពលទី១ គេនៅក្នុងក្រុង ពីត្រឹមទួលគក អង់តែនទួលគកនឹងមក ទៅផ្សារចាស់អីចឹងទៅ គេចែកខណ្ឌគ្នាអីចឹងណា៎ ឲ្យខាងនិរតី ឲ្យខាងពាយ័ព្យវាចូលត្រឹមណាអីត្រឹមណាអីចឹងទៅ គេមានកំណត់របស់គេ តែយើងចូលហួសនឹងក្បែរៗនឹងគេចាប់យើងយកទៅ ចាប់ពួកខ្ញុំទៅអស់ច្រើនណាស់ខាងនិរតី ចូលហួស ចាប់ទៅបាត់លែងឃើញមកវិញបណោយ (សើច) ។

ដារ៉ា : ចូលទៅដល់ជ្រោយចង្វារហ្នឹងពូនៅបានប៉ុន្មានថ្ងៃ ប៉ុន្មានអាទិត្យទៅ?

សឿន : ខ្ញុំនៅហ្នឹងបានយូរដែរហ្នឹង បានប្រហែលជា២ខែចេញមកធ្វើស្រែ ចេញមកធ្វើស្រែយើងនៅឯត្រពាំងឈូក ។

ដារ៉ា : ភូមិអី ឃុំអី ត្រពាំងឈូក ហ្នឹងពូ?

សឿន ៖ ត្រពាំងឈូក វាហ្នឹង មិនដឹងភូមិអី ខាងកើតកំពង់ធំដែរអី ។

ដារ៉ា ៖ ពូថានៅប្រហែលជាបាន២ខែ អីចឹងពូថ្ងៃដែលពូមកដល់ភ្នំពេញ មកដល់ជ្រោយចង្វារហ្នឹង ថ្ងៃ១៧ មេសា ហ្នឹងដែរ តែម៉ោង៤រសៀលអីចឹងអ្ហេសពូអ្ហេស?

សឿន ៖ បាទ ។

ដារ៉ា ៖ អីចឹងប្រជាជនពូបានជួប បានឃើញប្រជាជនចេញ នឹងរយៈពេលប៉ុន្មានថ្ងៃបាន អាចដូចថា វាចំនួនវាស្រាកមកអីចឹងអ្ហាស ចំនួនប្រជាជនដែលចេញពីភ្នំពេញទៅអ្ហាស?

សឿន ៖ ចំនួន៧ថ្ងៃ ចេញ៧ថ្ងៃហ្នឹងស្រាកហ្នង ស្ងាត់បណ្តោយ ។

ដារ៉ា ៖ អាថ្ងៃទីមួយហ្នឹងចំនួនមនុស្សវាយ៉ាងម៉េចដែរពូ?

សឿន ៖ អូរច្រើនណែនតែម្តង រកដើរមិនកើតចេញមក ឡានដង ម៉ូតូដងថ្ងៃហ្នឹង ដល់អញ្ចឹងទៅយើងឃាត់ឡានអ្ហាស ឃាត់ឡានចូលតាមក្នុងផ្ទះហ្នឹងទៅ ។

ដារ៉ា ៖ អត់ឲ្យឡានចេញទេអីចឹង?

សឿន ៖ បាទ អត់ឲ្យឡានចេញទេ ទៅតែខ្លួនទៅ ដើរទៅ ។

ដារ៉ា ៖ អាហ្នឹង ការដែរឃាត់ការដែរអីចឹងពូ ជាផែនការជាស្អីយ៉ាងម៉េច បានដឹងថា អូរមិនត្រូវយកអីវ៉ាន់ទៅ ឬមិនឲ្យឡានចេញទៅអ្ហាស អាហ្នឹងយ៉ាងម៉េចពូ?

សឿន ៖ អាហ្នឹងជាផែនការហ្នង ផែនការមិនឲ្យយកទៅហ្នង ឲ្យយើងទៅធ្វើស្រែនៅតាមតំបន់ក្រៅៗហ្នឹងទៀត ។

ដារ៉ា ៖ ហើយផែនការហ្នឹងបើពូជាពេទ្យអីចឹងពូ អាចដឹងពីផែនការហ្នឹងដែរ?

សឿន ៖ បាន យើងដឹងខ្លះៗដែរ យើងអាចសួរនាំអីចឹងទៅ ជួនការគេប្រាប់យើងអីចឹងទៅណា៎ ជួនកាលគេឲ្យយើងជួយ ប៉ុន្តែយើងទៅធ្វើអីកើត មិនហ៊ានទេ ។

ដារ៉ា ៖ ផែនការហ្នឹងចេញពីត្រឹមថ្នាក់ណាដែរពូ?

សឿន ៖ ពីលើទៅបណ្តោយហ្នឹង ផែនការគេដកហូតមិនឲ្យមានចេញទៅតែហ្នង ប្រមូលឲ្យអស់ ។

ដារ៉ា ៖ អីចឹងសម្រាប់ពូ គឺយល់ជ្រួតជ្រាបពីអាបញ្ហាហ្នឹងហ្នង បញ្ហាផែនការហ្នឹងហ្នងអ្ហេស?

សឿន ៖ បាទយល់ខ្លះ បាទបានយល់ខ្លះៗ ។

ដារ៉ា ៖ បើថាជួបប្រទះត្រូវតែដកហូត ឬក៏ឃើញឡានចេញត្រូវតែឃាត់អីចឹងហ្នង?

សឿន ៖ បាទហ្នឹងហើយ ។

ដារ៉ា ៖ អាហ្នឹងពូយល់ជ្រួតជ្រាបអីចឹងហ្នងអ្ហេស?

សឿន ៖ បាទ ដឹងហ្នឹង ដឹងអីចឹង គេប្រាប់យើងអ្នាស ប៉ុន្តែយើង គេឲ្យយើងធ្វើ គេមិនល្អយើងមិនធ្វើទេ គេមានក្រុមគេធ្វើ អ្នកធ្វើហើយ ឯយើងនេះពេទ្យមានទៅតួនាទីអីយើងធ្វើហ្នឹងអត់ទេ យើងគ្រាន់តែបានតែម៉ាដឹងនឹងឯង ។

ដារ៉ា ៖ ម៉ាដឹង ម៉ាឃើញអីចឹងទៅ?

សឿន ៖ បាទ មាដឹង ម៉ាឃើញ ។

ដារ៉ា ៖ ដាដាក់ស្តែងពូនេះ?

សឿន ៖ បាទ ។

ដារ៉ា ៖ ពូអាចមានឃើញប្រទះជា ព្រឹត្តិការណ៍អីជាក់ស្តែងទេ ដែលប្រជាជនជម្លៀសចេញទៅ ព្រឹត្តិការណ៍ជាការរើងរូសជាការមិនចេញ ឬក៏ដូចថាតាមផ្លូវ ការមិនឲ្យយករបស់ទៅនៅរើងរូសថាយកទៅ ឬក៏ប្រឆាំងបទបញ្ជារបទអីចឹង ពូអាចមានប្រទះជាព្រឹត្តិការណ៍បែបអីចឹងទេពូ?

សឿន ៖ ដូចជា មិនឃើញមាន មានដែរ តែយើងនិយាយតែមួយម៉ាត់ពីរម៉ាត់ អង្គរគេអីចឹងទៅ គេថាអេអត់បានទេ ក៏មិនហ៊ាន មិនហ៊ានប្រឆាំងអីខ្លាំង បើប្រឆាំងថាមិនចេញ មិនព្រមចេញ អាហ្នឹងមែនហ្នង ។

ដារ៉ា ៖ មានអ្ហូស?

សឿន ៖ បាទ មាន មិនព្រមចេញទេ ស្តាយផ្ទះស្តាយទ្រព្យសម្បត្តិហ្នឹង ផ្ទះសម្បែងស្តាយ អាហ្នឹងមានអត់ចង់ចេញទេ ទាល់តែមានសកម្មភាពអីធ្ងន់ធ្ងរខ្លាំងទៅបានចេញទៅ អាហ្នឹងបានគាត់ដាច់ចិត្តចេញ ។

ដារ៉ា ៖ ខ្លាំងដល់កម្រិតណាដែរពូ?

សឿន ៖ បាញ់ បាញ់សម្លាប់ហ្នងអ្នាស ដាក់មួយពីរអីចឹងទៅបានផ្អើល អីចឹងទៅ លែងហ៊ានប្រឆាំងតទៅទៀតណា៎ ក៏ទៅ ទៅ ។

ដារ៉ា ៖ អាដំបូងហ្នងពូអ្ហូស?

សឿន ៖ បាទ អាដំបូងបង្អស់ហើយហ្នឹង ចូលទៅដល់ហ្នឹង ម៉ោង៨ហ្នឹង ប៉ុន្តែម៉ោង៨គេឲ្យយើងចូលទៅមែនប៉ុន្តែ ខ្ញុំអាចទៅមកៗបាន បាទយើងទៅអីចឹងជួនកាលគេហៅយើងឲ្យទៅយកថ្នាំពេទ្យថ្នាំអីដែលគេយកបានអីចឹងទៅណា៎ បើកឡានទៅយកទៅ យកមកទុកមក ចេញចូលៗ អាពេលហ្នឹងអត់អ្ហូស អាសកម្មភាពដែលយើងឃើញតាមផ្លូវតាមអីទៅ មានព្រឹត្តិការណ៍មានខ្លះៗអីចឹងទៅ បើថាមើលតែម៉ោង៨ល្ងាយ ក្នុងរយៈពេលដែលខ្ញុំទៅដល់ហ្នឹង រយៈពេល៧ថ្ងៃហ្នឹងមានតទៅទៀតហ្នឹងទៅ ចេះតែមានៗទៅ ។

ដារ៉ា : នៅក្នុងរយៈពេល៧ថ្ងៃហ្នឹងអាចមានជួបប្រទះជាអ្នកដែលដូចថាពួនជ្រកអីហ្នឹង ក្នុងផ្ទះក្នុងអី ដែលអត់ចេញអីចឹងដែរ មានដែរ?

សឿន : មាន បាទមាន រហូតដល់កណ្តាលទីក្រុងទៀតណោះ ជាទាហានហ្នឹងតែហ្មង កាលដែលខ្ញុំទៅ ដឹកថ្នាំពេទ្យអីចឹង បាញ់អ្ហាស ចេញមកបាញ់បណ្តោយ ដល់ចេញមកបាញ់អីចឹងខ្ញុំស្រែក ប្រាប់ ហើយចុះបាញ់ធ្វើអី បើថាពួនៗតែស្ងាត់ស្ងៀមទៅ ថ្ងៃស្ងាត់ចាំយើងចេញទៅ ស្រែកប្រាប់អីចឹងដែរ ប៉ុន្តែនៅតែបាញ់ បាញ់ទៅកងទ័ពគេ មានទៅទុកអីតែអីចឹង អូរដល់ ទៅមានរៀបសកម្មភាពដូចជាស្រីៗអីចឹងទៅណា៎ សម្រាប់អូរទាញកងទ័ពខ្មែរក្រហមនឹងអ្ហស អាហ្នឹងមានដែរ ។

ដារ៉ា : កន្លែងហ្នឹងយ៉ាងម៉េចទៅពូ អូសទាញខ្មែរក្រហម?

សឿន : គេរៀបចំស្រីៗឲ្យស្អាតៗអីចឹងទៅបាយទឹកអីសម្រាប់ហៅយើងចូលហូបចុកអីចឹងទៅ ឲ្យតែ ចូលទៅដល់កន្លែងហ្នឹងទៅទាហានគេនៅហ្នឹងបណ្តោយ គេនៅព័ទ្ធជុំវិញចាប់បានទាំងអស់ គ្រាន់តែចូលទៅ ព្រោះអីអាហ្នឹងជាផែនការហើយ គេប្រជុំប្រាប់ហើយ តែចូលដល់ក្រុង ភ្នំពេញត្រូវប្រយ័ត្ន រឿងសកម្មភាពដែលគេរៀបចំហ្នឹង មានស្រីស្អាតៗ ដល់មែនទៅ ស្អៀកតែស្បែងទេ ឃើញអស់ទាំងអស់ទៅណា៎ គ្រប់គ្នាអីចឹងទៅ មួយរយពីររយនាក់អីទៅ ចាំទទួលយើងអីចឹងទៅដល់ភ្លាមៗ ហើយតែបើយើងមិនចាប់អារម្មណ៍ទេ ក៏លង់ទៅតាមនឹង ក៏ងាប់ហ្នឹងហើយ ដល់អីចឹងទៅយើងសភាពការណ៍ អាហ្នឹងគេប្រជុំប្រាប់យើងអីចឹងទៅ យើងគ្រាន់តែឃើញភ្លាមយើងចាប់ ចូលភ្លាមចាប់បណ្តោយ ដល់ចាប់ទៅទាហានខ្លះថា ដឹង ថាសភាពការណ៍មិនស្រួលហើយបាញ់ផ្ទុក បោកគ្រាប់បែកពេញតែក្នុងផ្ទះហ្នឹង ងាប់អាទាំង គេ ងាប់អាទាំងឯងទាំងអស់គ្នាហ្នឹងទៅ ខ្លះក៏រត់រួចទៅ ។

ដារ៉ា : មានសកម្មភាពអីចឹងជាក់ស្តែងមែនអ្ហោះ?

សឿន : បាទ មានតាស ។ អ្នករបួសហើយមកដល់កន្លែងខ្ញុំហ្នឹង ខ្ញុំសួរទៅ ថាអូ ដល់ខ្ញុំសួរថាចុះ ក្រែងគេប្រជុំប្រាប់ដែរម៉េចក៏យើងធ្វើអីចឹងទៀត ហើយអាហ្នឹងឃើញគេស្អាតៗ(សើច) ។

ដារ៉ា : អាហ្នឹងនៅម្តុំអាចថា មានសកម្មភាពអីចឹងនៅម្តុំណាពូ?

សឿន : មាននៅម្តុំផ្សារចាស់អ្ហេស ។

ដារ៉ា : ម្តុំផ្សារចាស់?

សឿន : បាទ ផ្សារចាស់មិនដឹងម្តុំត្រង់ណាទេនេះ អាចថា បើទៅឃើញបានចំណាំ ប៉ុនថាតែឲ្យ និយាយប្រាប់ហ្នឹង ព្រោះអីយើងដើរវាមិនបានច្រើន វាអត់សូវស្គាល់កន្លែងភ្នំពេញ ។

ដារ៉ា : ខ្ញុំមានចាប់អារម្មណ៍ត្រង់ចំណុចហ្នឹង ព្រោះកាលពីយើងសម្ភាសន៍អីកន្លងមកដារច្រើនហើយពូ អត់ដែលពូបញ្ជាហ្នឹងណាពូ ពូបញ្ជាដែរថា ខាងទាហាន លន់ នល់ ហ្នឹងបានរៀបចំជាមានស្រីស្អាតៗអីដើម្បីទាក់ទាញកងទ័ពខ្មែរក្រហមឲ្យចូលអីចឹងអ្នកពូ ។

សឿន : បាទ អត់ដែលពូ?

ដារ៉ា : អត់ដែលពូទេ ទើបតែពូថាហ្នឹងដែរ ។

សឿន : ហើយសកម្មភាពហ្នឹងវានៅតែមានយូរដែរណា ជាប់ប្រហែលជា៣-៤ថ្ងៃអីណោះ លាក់ខ្លួននៅក្នុងក្រុងភ្នំពេញហ្នឹង លបបាញ់យើងអីចឹងទៅ ហើយមួយ-ពីរ ជួនកាលប្រាំ ជួនកាលដប់អីចឹង ជួនកាលច្រើនអីចឹងទៅ នៅពួនក្នុងដីក៏មានដែរ ចាប់រហូតទៅដល់ប្រហែលជាមួយខែបានអស់ បោសសំអាតហ្នឹង គេថាបោសសំអាតហ្នឹងទាល់តែមួយខែបានអស់ពួកអ្នកនៅតាមផ្ទះហ្នឹងអ្នកស សុទ្ធតែទាហានហ្នឹង ហើយជាប្រជាជនហ្នឹងក៏មានដែរ មានតិចតួចដែរគាត់មិនព្រមចេញ ជួនកាលទុកកូនឲ្យនៅ ចេញទៅតែម្ដាយឪពុក ចេញទៅកូននៅ ខ្លះចេញទៅកូនៗទៅនៅឪពុកអីចឹងទៅ ខ្លះនៅម្ដាយអីចឹងទៅ ហើយយើងប្រមូលឲ្យចេញទៅ ដល់តែអីចង់ទៅបែកបាក់គ្នាបាត់ហើយ ។

ដារ៉ា : ដូចតែជាទាហានទេអី? ហេតុអីបានជាធ្វើសកម្មភាពដូចថាឲ្យស្រីៗមកទាក់ទាញអីចឹងអ្នកស ព្រោះពេលហ្នឹងសឹងថាខ្មែរក្រហមដណ្ដើមបានសឹងទូទាំងប្រទេសហើយហ្នឹងបើនិយាយទៅ?

សឿន : អាហ្នឹងផែនការប្រុងវាយបកយើងវិញ កាលណាយើងចូលដល់ក្នុងហ្នឹងព្រឹបហើយហ្នឹង គេរៀបចំផែនការអីចឹងដើម្បីវាយបកយើងសង្គ្រុបពេលហ្នឹងឲ្យយើងបរាជ័យមកវិញ ឲ្យខ្មែរក្រហមបរាជ័យអ្វោះ ប៉ុន្តែធ្វើទៅអត់រួច ដែលកាលហ្នឹង ឡុង បូរ៉េត គាត់ចូលមកវិញ គាត់ចេញទៅហើយគាត់ចូលមកវិញ ដើម្បីដឹកនាំអ្នកដែលនៅក្នុងហ្នឹងវាយបកវិញ ប៉ុន្តែចូលមកដល់ត្រឹមអាកន្លែងទួតបារាំងហ្នឹង គេចាប់បានបណ្ដោយ ចាប់បាននៅកន្លែងទួតបារាំងហ្នឹងហ្នឹង ។

បូលី : ពូដឹងតាមណារឿងហ្នឹង?

សឿន : ដឹង ខ្ញុំនៅជិតហ្នឹងហើយ កន្លែងហ្នឹង ហើយ

បូលី : ពូស្គាល់ ឡុង បូរ៉េត ដែរ?

សឿន : ខ្ញុំមិនស្គាល់មុខគាត់ទេ ក៏ប៉ុន្តែគ្រាន់តែស្គាល់ឈ្មោះហ្នឹងណា ពូតាមវិទ្យុ ពូតាមអីហ្នឹង ហើយណាមួយគេប្រជុំប្រាប់យើងទៀត ដល់ពេលគេថា ខ្ញុំឆ្ងល់ដែរ ខ្ញុំថា ម៉េចបានជាដឹងថា ឡុង បូរ៉េត ចូលមករៀបចំវិញ បានប្រជុំប្រាប់យើងអីចឹង ខ្ញុំឆ្ងល់ត្រង់កន្លែងហ្នឹងដែរ មូលហេតុអីបានដឹងថា ឡុង បូរ៉េត ចូលមករៀបចំផែនការវាយបកវិញ ខ្ញុំឆ្ងល់ ។

បូលី : មានសួរគេអ្នស?

សឿន : អត់ហ៊ានទេ សួរម៉េចបាន សួរមិនបានទេ

បូលី : ប្រជុំហ្នឹង ប្រជុំមុនពេលវ៉ៃភ្នំពេញបក៏ក្រោយ?

សឿន : មុន រៀបចំទៅយើងដឹង សភាពការណ៍ហ្នឹងយើងដឹងថាវ៉ៃឈ្នះហើយ វ៉ៃឈ្នះហើយវ៉ៃឲ្យដាច់នៅថ្ងៃចូលឆ្នាំហ្នឹងតែហ្នុង ដល់អីចឹងទៅហ្នឹង ហើយដឹងថាយើងត្រូវដឹងថា អ្នូរ លន់ នល់ ទន់ដៃហើយ យើងត្រូវតែវ៉ៃសង្គ្រុបមុនហ្នុង វ៉ៃសង្គ្រុបទៅវាឈ្នះមែន ពេលហ្នឹងប្រជុំតែទាំងអស់អីចឹងទៅ ប្រជុំប្រាប់ថា អាដេញ លន់ នល់ រៀបចំផែនការ សកម្មភាពសព្វបែបយ៉ាងទាំងអស់នៅក្នុងទីក្រុងភ្នំពេញ មាន ឡុង បូរ៉េត អ្នកបញ្ជារ នែ៎ដឹងអ្នស យើងឆ្ងល់អាត្រង់ហ្នឹងដែរ ។

បូលី : អ្នកណាគេជាអ្នកប្រធានអង្គប្រជុំកាលហ្នឹង?

សឿន : យើងចេះតែបន្តៗគ្នាមករហូត កងវរសេនាតូច វរសេនាធំ យើងប្រជុំតាមយុទ្ធជនយើងប្រាប់ណា ពីលើចុះក្រោមមក ។

បូលី : ចុះពូប្រជុំនៅក្នុងកងណាដែរកាលហ្នឹង?

សឿន : ខ្ញុំនៅក្នុងពេទ្យហ្នឹងមែន ប៉ុន្តែនៅក្នុងកងពល៤៥០ហ្នឹងឯង ។

ដារ៉ា : មេកងពលអ្នកប្រជុំប្រាប់ពូហ្នឹង?

សឿន : បាទ តាមគាត់ហ្នឹង គាត់ប្រាប់ហ្នុង ។

បូលី : តាឈិន ហ្នឹង?

សឿន : មិនមែនទេ តាសួង ។

បូលី : អីចឹងតាសួង អ្នកនិយាយអីចឹងហ្នុងពូ?

សឿន : បាទ ទាំងអស់ គ្រប់កងពលទាំងអស់ កាលណោះបើសិនជាយើងមិនប្រយ័ត្នទេគ្រោះថ្នាក់មែនហ្នឹងហើយ បើខ្ញុំគ្រាន់តែដើរផង ដើរទៅប្រមូល ព្រោះរឿងថ្នាំពេទ្យអីយើងយកមកទុកហ្នឹងណា ទុកសម្រាប់ប្រើក្នុងកងពលយើង បាញ់ បាញ់អាកាំភ្លើង អាកាំភ្លើងខ្យល់ក៏បាញ់ អាកាំភ្លើង អាហ្វុងឌឹឡុង គ្រាប់តូចៗក៏បាញ់ អាកាំភ្លើងបាញ់សត្វហ្នឹង ។

បូលី : សម្តីដែរថា ឡុង បូរ៉េត រៀបចំផែនការក្នុងក្រុងភ្នំពេញហ្នឹងសម្តីហ្នឹងចេញពីម៉ាត់អ្នកណា? ម៉ាត់តាសួង ឬក៏ម៉ាត់អ្នកណាប្រាប់ពូ?

សឿន : ម៉ាត់តាសួង ហ្នឹងហ្នុង វាទូទាំង ទាំងអស់កងទ័ព ឲ្យតែកងទ័ពទាំងអស់ ខ្មែរក្រហមយើងហ្នឹងគឺគេប្រជុំប្រាប់យើងទាំងអស់ ហើយកាលហ្នឹងមិនដឹងជាទៅដល់ណាហើយបានបកមកវិញ

បកមកវិញចេះចុះយន្តហោះឯណា ដឹងថាគេវៃចូលទីក្រុងភ្នំពេញហើយចុះយន្តហោះមកទៀត ចុះឲ្យគេចាប់បានទៅ ទៅហើយមិនទៅមកវិញ (សើច) ។

ប៊ូលី : ក្រុមណាដែលអ្នកចាប់ ឡុង បូរ៉េត ហ្នឹង?

សឿន : កងពលទី១ ចំមុខសញ្ញាកងពលទី១ហ្នឹង ។

ដារ៉ា : កងពល តាអឿន?

សឿន : តាអឿន ហ្នឹងហើយ បាទ យើងនៅត្រង់កន្លែងចុះស្ពានជ្រោយចង្វារទៅ មិនត្រង់ហ្នឹង ។

ដារ៉ា : បាទ ចុះពីស្ពានជ្រោយចង្វារចុះមកខាងលិចហ្នឹងមិនត្រង់ហ្នឹងគឺស្ពានទូតបារាំងកន្លែងស្តាតចាស់

សឿន : បាទ ហ្នឹងហើយត្រង់ហ្នឹង ។

ដារ៉ា : កន្លែងវង្វង់មូលស្តាតចាស់ហ្នឹងឯង ។

សឿន : បាទ ស្តាតចាស់ហ្នឹងឯង ។

ប៊ូលី : ចាប់ក្នុងស្តាតហ្នឹងហ្នុងឬក៏យ៉ាងម៉េច?

សឿន : ចាប់ដល់ផ្ទះនៅស្ពានទូតហ្នឹងហ្នុង ។

ប៊ូលី : ទូតបារាំង?

សឿន : បាទ ចាប់នៅហ្នឹងបណ្តោយ ។

ប៊ូលី : នៅក្បែរគ្នា ព្រោះមានឯកសារប្រាប់ថាចាប់នៅក្នុងស្តាតចាស់អ្ហោះ ។

សឿន : មិនទេ យន្តហោះចុះនៅហ្នឹងបណ្តោយ យន្តហោះចុះមក២គ្រឿង ស្តាតចាស់ហ្នឹងមួយ នៅហ្នឹង ឡើងវត់ម៉េច ហើយខ្ញុំនៅឯស្ពានជ្រោយចង្វារ ស្ពានតែអាមេរិកគេមកគេធ្វើអីទៀតហើយ ចុះនៅស្តាតចាស់រួចហើយ ឃើញមួយទៀតចុះនៅនឹងស្ពានទូត ចុះហ្នឹងផ្លូវ ចុះឡើងបាក់បែកអីខ្ទេចខ្ទីអស់ហើយ កាលហ្នឹងឆេះ កាលហ្នឹងធ្លាក់ទៀតអ្ហូរកាលហ្នឹងអ្ហេះ ចុះរបៀបប្រញាប់ហ្នឹងណា ។

ប៊ូលី : ពូឃើញហ្នឹងភ្នែកតែហ្នុងអ្ហេះ?

សឿន : បាទ ឃើញហ្នុង ទៅហ្នឹងទាហានកំពង់គំរង់ជួរ កាលហ្នឹង ខ្ញុំគេហៅឲ្យចូលទៅយកថ្នាំនៅកន្លែងលក់ថ្នាំហ្នឹង យើងជិតស្ពានជ្រោយចង្វារហ្នឹងមានកន្លែងលក់ថ្នាំតូចៗនោះ ថ្ងៃហ្នឹងប្រុងតែថាចូលទៅមើលឲ្យដល់នឹងកន្លែង ក៏ទៅសុំគេកន្លែងកងពលទី១ហ្នឹងមានអ្នកស្គាល់ៗគាហ្នឹងសុំចូលទៅមុខទៀត ។ គេថាអ្ហឹះកុំអាលចូលសភាពការណ៍ បកក្រោយវិញ បកមកក្រោយវិញក៏មកនៅចាំនៅត្រង់កន្លែងផ្លូវបត់កែងហ្នឹងស្ពានជ្រោយចង្វារកន្លែង យើងមកពីនោះមកនៅចាំហ្នឹងទៅ ឃើញយន្តហោះចុះមកបណ្តោយ ចុះទៅខ្ញុំក៏ដើរទៅនៅខាងក្រោមស្ពាន

ជ្រោយចង្កូរហ្នឹង ខ្ចាចក្រែងលោមានការអីទៅ ទៅនៅខាងក្រោមខាងគល់ ចុងហ្នឹង ទៅនៅខាងក្រោមបណ្ដោយ លបមើលទៅឃើញ វាច្រើនដែរណា មិនមែនតែម្នាក់ឯងឯណា កងទ័ពអីទៅជាមួយគ្នាហ្នឹង ។

ដារ៉ា : យើងអត់អាចទៅលូកលាន់អីកន្លែងហ្នឹងបានទេទ៎?

សឿន : ទេអត់បានទេ ព្រោះអីកងពលទី១ គេអ្នកនៅចាំ ។

បូលី : ហើយពូមើលឃើញពេលសកម្មភាពចុះហ្នឹងយ៉ាងម៉េចទៅ មានមនុស្សប៉ុន្មាននាក់ចុះពីលើយន្តហោះ ហើយខាងខ្មែរក្រហមប៉ុន្មាននាក់ដែលសម្រុកវ៉ៃទៅចាប់មនុស្សហ្នឹង?

សឿន : អត់ឃើញ ។

បូលី : អត់ឃើញសកម្មភាពហ្នឹងអ្ហេស?

សឿន : អត់បានឃើញទេ ឲ្យណែនហ្នឹងមនុស្ស គ្រាន់តែព្រឹប គ្រាន់តែយន្តហោះធ្លាក់ដល់ព្រឹបណែនបណ្ដោយ យើងឃើញតែណែនពីខាងក្រៅមិនដឹងជាប៉ុន្មាននាក់ទៅ (សើច) ។

ដារ៉ា : ណែនមនុស្ស មនុស្សហ្នឹងប្រុងតែរត់ឡើងលើយន្តហោះហ្នឹង ឬក៏យ៉ាងម៉េចពូ?

សឿន : ព័ទ្ធ ព័ទ្ធជុំវិញ ។

បូលី : ខ្មែរក្រហមអ្ហេ?

សឿន : បាទ ហើយនៅក្នុងស្ដាតនោះយើងអត់ឃើញទេ នៅសល់យន្តហោះមួយនៅទាល់តែស្ងប់ស្ងាត់មែនទែន ចិនចូលទៅបានមកយកពីស្ដាតចាស់ហ្នឹងទៅ អាយន្តហោះកន្ទុំរុយអ្ហាះ ។

បូលី : អាកន្ទុំរុយមួយខូចក្នុងស្ដាតចាស់ហ្នឹង ចិនអ្នកយកទេអីចឹង?

សឿន : បាទ ចិនអ្នកយក ។

បូលី : ឆ្នាំប៉ុន្មានដែរចិនយកទៅ?

សឿន : ឆ្នាំ៧៥ហ្នឹងឯង ចិនគេមកដល់ យើងដល់ស្ងប់ស្ងាត់ហើយ ចិនគេចុះមកជួយរៀបចំបង្ហាត់បង្រៀនអ្នកបើកបរអីហ្នឹងណា កាលហ្នឹង ចិនគេមកយកទៅ ។

ដារ៉ា : អីចឹងបើនិយាយទៅ ទម្រាំបោសសម្អាតអាទីក្រុងភ្នំពេញហ្នឹងអស់ទាំងប្រជាជន ទាំងទាហាន លន់ នល់ អី ច្រើនថ្ងៃដែរ ច្រើនថ្ងៃច្រើនខែអីយ៉ាងម៉េច?

សឿន : ចូលជិតហ្នឹង២ខែដែរហ្នឹងណា បានស្ងាត់ស្ងៀម ២ខែជាងដែរ ដល់តែ៣ខែស្ងាត់មែនទែនបណ្ដោយ មានឃើញសុទ្ធតែ (០១:១៨:៣០ស្ដាប់មិនបាន) សុទ្ធតែខាងពាណិជ្ជកម្មអីចឹងទៅ ។

ដារ៉ា : អីចឹងពេលហ្នឹងពូនៅហ្នឹងភ្នំពេញហ្នឹងរហូតហ្នឹង ឬក៏ពូដកទៅខាងណាវិញ?

សឿន : ខ្ញុំនៅហ្នឹងរហូត អត់មានដកទេ ដក ដកដែរ ដកតែទៅធ្វើស្រែហ្នឹងបានតែប៉ុន្មានហ្នឹងក៏ចូលមកវិញ ។

ដារ៉ា : ដែលថាទៅធ្វើស្រែហ្នឹង ធ្វើនៅ?

សឿន : នៅភូមិឈូក ។

ដារ៉ា : ត្រពាំងឈូកនេះ?

សឿន : បាទ ត្រពាំងឈូក ។

ដារ៉ា : ក្នុងឆ្នាំ៧៥ដែរពូអ្ហែរ?

សឿន : បាទ ៧៥ ទៅបានតែប៉ុន្មានខែហ្នឹងក៏មកវិញ ទៅមិនទាន់ដាច់ឆ្នាំផងចូលមកវិញ ។

ដារ៉ា : ចង់និយាយថាក្រោយរំដោះបានប៉ុន្មានខែ ប៉ុន្មានថ្ងៃទៅ បានគេដកពូ បានទៅធ្វើស្រែហ្នឹងពូ?

សឿន : ប្រហែល២ខែដែរ ទៅហ្នោះបាន២ខែបកមកវិញ ។

ដារ៉ា : ទៅធ្វើស្រែហ្នឹងទាំងកងពលហ្នឹងហ្នុងឬក៏យ៉ាងម៉េច?

សឿន : ទៅទាំងកងពល ទៅហ្នឹងជិះកង់ទៅ មួយៗម្នាក់ទៅរហូតហ្នុង ។

បូលី : បានកង់មកពីណា?

សឿន : កង់ក្នុងក្រុងហ្នឹងឯង (សើច) អត់មានឡានជិះទេ ឲ្យជិះកង់ ។

ដារ៉ា : ហើយពេលដែលធ្វើស្រែហើយត្រឡប់មកនៅភ្នំពេញនេះនៅក្នុងកងពលដដែល ឬក៏យ៉ាងម៉េច?

សឿន : បាទនៅដដែល ។

ដារ៉ា : អីចឹងទីតាំងពូឈរជើងនៅម្តុំណានៅភ្នំពេញ?

សឿន : នៅពីស្ពានជ្រោយចង្វារទៅ ទៅដល់គីឡូលេខ៦ នៅឯងប្រាំងចំរេះ ។

បូលី : អ្ហូ! បាទ នៅកងពលលេខ៣ របស់តាសួង ហ្នឹងអ្ហេះ?

សឿន : បាទ ។

ដារ៉ា : នៅគីឡូលេខ៦ហ្នឹងអ្ហោះ?

សឿន : បាទ

ដារ៉ា : នៅដែនដីរបស់កងពល៤៥០?

សឿន : បាទ ហើយយើងធ្វើស្រែម៉ាជិនារខាងក្រោយហ្នឹងឯង ហើយបឹងស្រយាប វត្តឃ្លាញ វត្តយងអ្ហែស! វត្តយង ។ វត្តឃ្មង់ វត្តឃ្លាញ នៅឯយើងទន្លេបិតហ្នោះ វត្តឃ្មង់នៅឯយើងប្រាំងចំរេះ នៅឯយើងហ្នោះ ។

បូលី : អន្លង់ក្រសាន?

សឿន : បាន អន្លង់ក្រសានហ្នោះ ។

បូលី : មិនមែនឈរជើងនៅខាងអន្លងក្រសាន ទេអីចឹង?

សឿន : ធ្វើស្រែ យើងទៅធ្វើស្រែនៅនោះ គ្រាន់តែយើងមានទីតាំងនៅនោះដែរ ទីតាំងយើងនៅ ២ តាមផ្លូវលេខ តាមហ្នឹងផង នៅឯហ្នឹងផង ។

ដារ៉ា : ធ្វើស្រែដើម្បីផ្គត់ផ្គង់កងពលហ្នឹងហ្នុងពូអ្ហេ?

សឿន : បាទ ផ្គត់ផ្គង់កងពល ។

ដារ៉ា : ចុះពេទ្យអីចុះធ្វើស្រែដែរ?

សឿន : ពេទ្យមានបុគ្គលកសម្រាប់ចុះផ្លាស់ប្តូរគ្នា ។ គ្រាន់តែពេទ្យនោះវាចូលមកវរសេនាធំដែរ ហើយ ៥០០នាក់ដែរហើយ ។

ដារ៉ា : គ្រាន់តែពេទ្យហ្នឹង?

សឿន : បាទ គ្រាន់តែបុគ្គលិកពេទ្យហ្នឹង ធ្វើស្រែផ្គត់ផ្គង់ខ្លួនឯង ផ្លាស់ប្តូរគ្នាចូលព្យាបាលផង ធ្វើស្រែផង ។

ដារ៉ា : អីចឹងពេលមកដល់កងពល ស្លង ហ្នឹង បុគ្គលិកពេទ្យឡើងកើនចំនួនហើយអីចឹង?

សឿន : បាទកើន ព្រោះអីមានប្រធានដែលខ្ញុំប្រាប់មិញហ្នឹង ហ្នឹងក៏កងពលគេរៀបចំមានឲ្យកម្លាំងពេទ្យសម្រាប់ដោះស្រាយជីវភាពខ្លួនឯង អាហ្នឹងយកដកពីខាងយើងមានកងនារី យកនារីៗហ្នឹងមកទាំងអស់មកនៅហ្នឹង បែកទៅខាងកាត់ដេរខ្លះ មកនៅពេទ្យខ្លះ ហើយដកពីទ័ពមកខ្លះមក ឲ្យមកនៅកន្លែងពេទ្យ សម្រាប់ធ្វើស្រែធ្វើអីហ្នឹងទៅ ។

ដារ៉ា : អីចឹងពេលហ្នឹងបែកភ្នំពេញហើយទេអ្ហេស បានរៀបចំអីចឹងអ្ហេស?

សឿន : បាទ បែកភ្នំពេញហើយ យើងចូល៧៦ បានយើងរៀបចំហ្នឹងបាន ហើយមានមន្ទីពេទ្យកងពលហ្នឹងយើងនៅកន្លែងអ៊ុងគោ អ៊ុងគោ ជិតស្ពានជ្រោយចង្វារហ្នឹងមួយ ម៉ាបណ្តោយហ្នឹងអ៊ុងគោ ពីរ នៅទាំងពីរកន្លែងហ្នឹងឯង ។ ដោយសាសនាគ្រឹះ ។

បូលី : របស់យួន?

សឿន : បាទ ។

ដារ៉ា : អ៊ុងគោ កន្លែងណា?

សឿន : សាសនាគ្រឹះរបស់យួន ពីដើមយើងហៅ អ៊ុងគោ ពីរកន្លែងអាហ្នឹង ។

ដារ៉ា : អីចឹងគេហៅអ៊ុងគោអីចឹងហ្នុងពូអ្ហេស?

សឿន : បាទ មានពីរកន្លែង មួយហ្នឹងទៅខាងហ្មោះ មួយទៀតនៅជិតស្ពានជ្រោយចង្វារ អាហ្នឹងធំបន្តិច ។

បូលី : វ៉ៃចោលហើយ?

សឿន : វ៉ៃចោលអស់ហើយ ។

បូលី : អត់ដែលឃើញដែរឥឡូវ វ៉ៃចោលអស់ឬក៏មិនដឹង?

សឿន : ទេ ពីជំនាន់នោះខ្ញុំនៅនោះអត់វ៉ៃចោលទេជំនាន់នោះណា៎ បើវ៉ៃៗតែម៉ុងខ្មោច វ៉ៃម៉ុងខ្មោចនៅពីក្រោយហ្នឹងអ្ហា៎ះ វ៉ៃតែកន្លែងខ្លះបានកាំភ្លើង កន្លែងខ្លះខ្មោចពិតទៅ ។

ដារ៉ា : ម៉ុងហ្នឹងអ្ហេះ មានកាំភ្លើង?

សឿន : បាទម៉ុង មានកាំភ្លើង ។

ដារ៉ា : លាក់កាំភ្លើងអ្ហេះ?

សឿន : លាក់កាំភ្លើង យួនហ្នឹង កន្លែងយួន ។

ដារ៉ា : ធ្វើស្រែរហូតដល់ឆ្នាំណាទៅពូ?

សឿន : ធ្វើស្រែរហូត យើងធ្វើរហូត តាំងពីដាច់៧៩ហ្នឹងមក ដល់យើង៧៨ហ្នឹង អ្នកដែលនៅធ្វើហ្នឹងធ្វើទៅ អ្នកដែលទៅឯកើតហ្នឹងក៏ទៅ ទៅ ព្រំដែនខាងកើតហ្នឹង ដល់ពេលមានសភាពការណ៍ព្រំដែនហ្នឹងយើងទៅ ។

ដារ៉ា : ចាប់ បើនិយាយជាអារម្មណ៍នៃការរស់នៅនៅក្រោយ៧៩មកហ្នឹង វាខុសគ្នាពីអារម្មណ៍ដែលពូនៅពេទ្យជាមួយកងពលមុន៧៩?

សឿន : អារម្មណ៍ខុសឆ្ងាយណាស់ អារម្មណ៍មិនទឹងហ្នឹង ដឹងតែថ្ងៃងាប់ ព្រោះអីបើឃើញតែចាប់តិចៗចាប់ តិចៗចាប់ សកម្មភាពអារឿងដូចអត់ឃ្លាន រឿងអីអីចឹងណា៎ ខ្លះទៅយកពងមាន់ពងអីមកស្ងោរ បេះបន្លែបេះបន្ទុកគេដាំសម្រាប់ផ្គត់ផ្គង់អង្គភាពអីចឹងទៅ ក៏ចាប់គ្នាដែរអីចឹងទៅអារម្មណ៍យើងចេះតែភ័យខ្លាចហើយ ។ សីលធម៌រឿងស្រីងីអីហ្នឹងវានៅតែមានអីចឹង មិនព្រមថាបន្ទរបន្ទយអី វារឹតតែតឹងឡើងអ្ហា៎ះ អារម្មណ៍ចេះតែព្រួយជាប់រហូត អត់មានស្រួលទេ ណាមួយទៅហូបវាមិនគ្រប់មិនគ្រាន់ទៀតទៅក៏ចេះតែនឹកដល់ម៉ែឪផង នឹកដល់បងប្អូនផង នឹកដល់ខ្លួនឯងហ្នឹងក៏វាខ្លាំងទៀត អារម្មណ៍វាបែកច្រើនណាស់ ដល់អីចឹងភ័យអ្ហា៎ះ វាចេះតែភ័យ ។

ដារ៉ា : ចុះការហូបចុកវាមានលក្ខណៈខុសគ្នាដែរពូពេលហ្នឹង?

សឿន : មានអ្ហា៎ះ មានខុសគ្នាដែរតើ ។

ដារ៉ា : ពេលបែកភ្នំពេញហើយ ការហូបចុក ការរស់នៅមានលក្ខណៈយ៉ាងម៉េច?

សឿន ៖ លក្ខណៈផ្សេងគ្នាហ្នឹងហើយ យុទ្ធជននិយាយរួមមានតែខាងលើតើ ដូចឧទាហរណ៍ថា មេប្រធាន២-៣នាក់ ឬក៏៥នាក់អីចឹង ខាងលើណា៎ បានតែប្រាំនាក់អីចឹងទៅ គេហូបចុកស្រួលរបស់គេទៅណា៎ ឯក្រៅពីហ្នឹងមករហូតមក គឺស្មើរាបហ្នង សម្លមួយឆ្នាំងមកអីចឹងទៅ បាយមួយចានអីចឹងទៅ ប៉ុណ្ណឹងទៅ ស្មើគ្នាទាំងអស់បណ្ដោយ ។

ដារ៉ា ៖ ហើយពេលហ្នឹងពូដូចថា មកដល់ឆ្នាំណាដែលពូចាប់ផ្ដើមដឹងថា មានការរើសទៅសមរភូមិទៅព្រំដែនអីអ្វាះពូ?

សឿន ៖ កាលហ្នឹងភ្លេចថ្ងៃហើយណា៎ ប៉ុន្តែចាំតែឆ្នាំ៧៨ ឆ្នាំ៧៨ហ្នឹងទៅព្រំដែន ដកខ្ញុំទៅតាមកងពលទៀតបណ្ដោយ ។

ដារ៉ា ៖ ចុះឈ្មោះ សួង ហាន យ៉ាន់ យាន អីនេះ ដែលនៅក្នុងកងពលហ្នឹង?

សឿន ៖ គេចាប់អស់ហើយ ចាប់អស់ហើយ យើងចាប់តាំងពី៧៧-៧៨ហ្នឹងទៅអស់ហើយ ។

ដារ៉ា ៖ អីចឹង?

សឿន ៖ បាទ ៧៧អ្ហែះ ចាប់កាលហ្នឹង៧៧ហ្នឹងឯង ចាប់អស់ហើយ ។

ដារ៉ា ៖ ដល់ពេលចាប់អីចឹងមានអ្នកដាក់ជំនួសមកវិញអ្ហែះ?

សឿន ៖ មានមកខាង តាវិន នោះ តាវិន កូនប្រសារ តាម៉ុក ហ្នឹង ។

ដារ៉ា ៖ មាន វិន មានឈ្មោះអីខ្លះទៀតដែលមក?

សឿន ៖ អត់ស្គាល់ ស្គាល់តែមួយហ្នឹងឯង បន្ទាប់ៗពីក្រោមទៀតអត់ស្គាល់ ។

ដារ៉ា ៖ អីចឹងមានន័យថាឈ្មោះ វិន ហ្នឹងមកធ្វើជាលេខាកងពល៤៥០?

សឿន ៖ បាទ ហ្នឹងហើយ កែដាក់៦០៣វិញ ។

ដារ៉ា ៖ អីចឹងមានន័យថានៅពេលដែលចាប់ឈ្មោះ សួង យាន យ៉ាន់ ហាន អីអស់ពីកងពល៤៥០ទៅ គឺបញ្ជូនឈ្មោះ វិន ដែលជាកូនប្រសារតាម៉ុក ហ្នឹងមកកាន់ជាប្រធានកងពលហ្នឹងវិញ ហើយប្រធានកងពល៤៥០នេះ ត្រូវប្ដូរមក៦០៣?

សឿន ៖ បាទ ។

បូលី ៖ ចាប់ម៉ាសេរីជាមួយ កុយ ធួន ដែរ ខ្សែគ្នាគេ ។

សឿន ៖ បាទ កុយ ធួន ចាប់មុនប៉ុន្មានថ្ងៃហ្នឹង ក៏ចេះតែចាប់បន្តៗរហូតមកណា៎ ចាប់បន្តរហូតអីចឹងមក ឈិន អីហ្នឹង រហូតដល់មក បងឈិន ចប់មុន មុន កុយ ឃួន ចាប់មុន បានចាប់អស់ បោសអស់ហើយ បានយកពួកខ្ញុំហ្នឹងខាងពេទ្យហ្នឹង ដកពួកពេទ្យទាំងអស់ ហើយនារីដកទៅផ្សេង ដកពួកពេទ្យទាំងអស់ទៅនៅកន្លែងតាំងក្រសាំង យើងឯភូមតាំងក្រសាំង ហ្នឹងឲ្យនៅធ្វើស្រែនៅហ្នឹងឯង អន្លង់ក្វាន អន្លង់អីហ្នឹង ។

ដារ៉ា : ក្នុងឆ្នាំណាពូ?

សឿន : ឆ្នាំ៧៨អ្ហាះ ៧៧-៧៨ហ្នឹងឯង ៧៧នៅធ្វើស្រែនៅហ្នឹង ដល់៧៨ទៅព្រំដែន បាន៧៩ ហ្នឹងចូលផ្ទះបណ្តោយ ។

ដារ៉ា : ពូដែលពេលពូថាឆ្នាំ៧៧អ្ហេះដែលគេចាប់ឈ្មោះ សួង ឈ្មោះ ហាន ឈ្មោះ យ៉ាន់ ឈ្មោះ យាន ដល់ចាប់ទៅមកដាក់ឈ្មោះ វិន វិញ អីចឹងដល់ពេលហ្នឹងពូថា ពេទ្យរបស់ពូគេឲ្យទៅធ្វើស្រែនៅតាំងក្រសាំង ។

សឿន : នៅឯតាំងក្រសាំង បាទ ។,

ដារ៉ា : អីចឹងនៅកន្លែងហ្នឹងជាការរស់នៅជាអារម្មណ៍ជាអីចឹង វាមានការផ្លាស់ប្តូរយ៉ាងម៉េចទៀតទៅ?

សឿន : មានតើ ដូចខ្ញុំថាអីចឹង ខ្ញុំថាធ្វើស្រែ បើយើងមិនប្រឹងធ្វើក៏គេយកទៅដាក់ដែរព្រៃស បាក់ដងចបក៏យកទៅដែរកន្លែងហ្នឹង អារម្មណ៍យើងវា ហើយពេលទៅពីធ្វើស្រែវិញ ប្រជុំ ប្រជុំទាល់តែដល់ម៉ោង១១-១២អីចឹងទៅបានដេកអីចឹងទៅ ដេកទៅ ដល់ម៉ោង១-២ងើបទៀត ហើយដេកបានបន្តិចហ្នឹង ។

ដារ៉ា : ម៉ោង១-២យប់ហ្នឹង?

សឿន : បាទ ជួនកាលម៉ោង២យប់ ជួនកាលម៉ោង៣អីចឹងទៅ តាមតែគេហ្នឹងឃើញអ្ហាស ហើយចេញពីតាំងក្រសាំងហ្នឹងមក ហើយវត្តឃ្នុញហ្នឹង ៥គីឡូដីដែរតើ រត់រហូត ទាំងទៅទាំងមករត់រហូត ហើយហូបបាយ ហូបបាយនៅនឹងវត្តឃ្នុញហ្នឹងឯង កន្លែងបាយ គេដាំបាយហូបនៅហ្នឹង ហើយយើងធ្វើស្រែនៅហ្នឹងបឹងស្រយាបហ្នឹងឯង ហើយអារម្មណ៍អត់មានទេ អត់មានអ្នកណាមួយដូចថា ជីវិតខ្លួនឯងហ្នឹងមានរស់នៅអត់ទេ ដឹងតែពីថា ជាប់គុកៗ ដឹងតែប៉ុណ្ណឹងឯង ឬមួយក៏គេសម្លាប់អន្តរាលៗយើងអត់ដឹងទេ ពូបាវ នេះ នៅសព្វថ្ងៃនេះ ។

ដារ៉ា : ពូបាវ អ្ហេះ?

សឿន : បាទ អាហ្នឹងមេកន្លែងតាំងក្រសាំងហើយនោះ ។

បូលី : អីចឹងតាបាវ អ្ហោះ?

សឿន : បាទ តាបាវ ហ្នឹង (សើច) អីចឹងបានគាត់ជបខ្ញុំម្តងៗ ខ្ញុំផឹកជុំគ្នាអីចឹងទៅគាត់ថា ហ៊ឹបង កុំភ្លេចអនុស្សាវរីយ៍យើង ទោះបីលំបាកយ៉ាងម៉េចអាក្រក់ល្អយ៉ាងម៉េចក៏ជាអនុស្សាវរីយ៍ដែរ កុំភ្លេច ខ្ញុំអត់ភ្លេចទេ ខ្ញុំប្រាប់គាត់អីចឹងអ្ហាះ ។

បូលី : គាត់មនុស្សយ៉ាងម៉េចដែរពូ តាបាវ កាលសម័យហ្នឹង?

សឿន ៖ គាត់មាន ស្អីគាត់កាចដែរ មិនជាធម្មតាទេ បើនីរសារគាត់ប៉ុន្មានអ្នកទៀតហ្នឹងទៅនៅស្រុក ហើយ ជួបខ្ញុំដែរ ភ្លេចឈ្មោះវាទៀត ប៉ុន្តែខស្សាហ៍មកលេងដែរ ខស្សាហ៍មកលេងដែរ ហ្នឹងនីរសាររបស់គាត់ ព្រោះគាត់បើដែរ ។

បូលី ៖ តំណែងជាអីគាត់នៅតាំងក្រសាំងហ្នឹង?

សឿន ៖ គាត់ហ្នឹងមិនដឹងជាតំណែងជាស្អីទេ ប៉ុន្តែមកគ្រប់គ្រងពួកខ្ញុំកាលណោះ មកគ្រប់គ្រងនៅហ្នឹង ទាំងអស់គ្រប់ ដូចថាពួកសមាសភាពយកមកដាក់ហ្នឹងទាំងអស់ ម៉ាគ្រប់អង្គភាពគ្រប់កងពល ទាំងប៉ុន្មានដែលនៅក្នុងកងពលហ្នឹងណា៎ តាមវរសេនាធំ វរសេនាតូចគឺប្រមូលមកដាក់ហ្នឹង អ្នកដែលមានជាប់និន្នាការអី អីចឹងទៅណា៎ ។

ដារ៉ា ៖ សម្រាប់តែកងពលពូតែមួយ ឬក៏កងពលផ្សេងទៀត?

សឿន ៖ កងពលតែមួយហ្នឹងទេ ដូចថាវាមានពាក់ព័ន្ធសមាសភាពអីចឹងទៅ ណាគេសួបស្រឡាញ់វា ម៉េចទៅ គេយកមកដាក់ត្រង់ហ្នឹង ។

ដារ៉ា ៖ កន្លែងហ្នឹងបើតាមពូយល់ជាកន្លែងយ៉ាងម៉េច?

សឿន ៖ អាហ្នឹងកន្លែងគេលត់ដំ ដូចថាកន្លែងលត់ដំ កន្លែងគេតាមដានមើលសកម្មភាពយើង ល្អ អាក្រក់យ៉ាងម៉េច បើថាយើងហ្នឹងមានបញ្ហា អាហ្នឹងគេយកយើងទៅណោះទៅ បើយើង គ្មានបញ្ហាអីទេ យើងក៏នៅតែខាងហ្នឹងទៅ ។

បូលី ៖ តាបាវ ហ្នឹងគាត់នៅក្នុងកងពលលេខប៉ុន្មាន?

សឿន ៖ មិនមានកងពលលេខប៉ុន្មានទេកន្លែងហ្នឹង កន្លែងហ្នឹងកន្លែងសមាភាព ដែលគ្រប់គ្រង ។

ដារ៉ា ៖ ជាកន្លែងតាំងក្រសាំងហ្នឹងហ្នង់អ្ហេះ?

សឿន ៖ បាទ កន្លែងហ្នឹងតែហ្នង់ ។

ដារ៉ា ៖ អាហ្នឹងវាស្ថិតនៅក្រោមការគ្រប់គ្រងរបស់កងពលណាវិញ?

សឿន ៖ កងពល៦០៣ហ្នឹង ។

ដារ៉ា ៖ អីចឹង ដែលគ្រប់គ្រងដោយ រិន ហ្នឹងអ្ហេស?

សឿន ៖ បាទ ហ្នឹងហើយ ។

ដារ៉ា ៖ អីចឹងតាបាវ និង ពូរិន ហ្នឹងអាចមានទំនាក់ទំនងតាំងពេលហ្នឹងមកអីចឹង តាំងពីនៅតាំងក្រ សាំងនោះមកអីចឹង?

សឿន ៖ បាទ ។

ដារ៉ា ៖ ចុះអនុ តាបាវ មានអ្នកណាបន្តពីគាត់មក?

សឿន : មាន មានដូចថាគេឲ្យកាន់អនុសេនាធំអីចឹងទៅណា ប៉ុន្តែខ្ញុំវាភ្លេចឈ្មោះច្រើនដែរ មាន ឈ្មោះ ឈាង ឈ្មោះ វ៉ាន់ មួយទៀតហ្នឹងមិនដឹងឈ្មោះអីទេ អាហ្នឹងវាងព្រហើនបន្តិច ក្មេងហើយព្រហើន ឈ្មោះអីទេ ភ្លេចទៀតហើយ អេយូទៅភ្លេចដែរ អាហ្នឹងព្រហើន ណាស់ ។

ដារ៉ា : ព្រហើនរបៀបម៉េចទៅពូ?

សឿន : ព្រហើនដូចជាការមើលងាយមើលថោកលើយើងអ្ហះ មិនស្គាល់ចាស់មិនស្គាល់ទុំ ហៅយើង អា ម៉ឹង ដេរយើងទៅ ហើយដេរម៉ាវ៉ាយ ដេរអី ជៀលពូជយើងទៅ កំពូជអាភូមិភាគ ឧត្ដរ សុទ្ធតែអាពួកក្បត់ពួកអី អីណាណីអីចឹងទៅណា ហើយដល់ពេលអីចឹងនិយាយទៅវា បេះតែចេញ ដល់ពេលយកទៅវ៉ៃនៅសមរភូមិ គ្រាន់តែពួសួរកាំភ្លើងប្រាវមកហ្នឹង ញ័រដៃ ឲ្យតគាត់ បាទ អត់កើតទេ ហើយកាន់កងអនុសេនាធំដឹកនាំទ័ពវ៉ៃ បារីបៀមហ្នឹងមាត់មួយ ហើយហ្នឹង ក៏ញ័រដៃញ័រជើងហ្នឹង យកបារីមកបៀមទៀត ហើយបៀមមិនបៀមអាខាង យើងកន្ទុយ បៀមអាខាងក្បាលអុជ យីសខ្លាចដល់ថ្នាក់ប៉ុណ្ណឹងហ្នោះ ម៉េចក៏ខ្លាំងម្លេះកាល នៅឯតាំងក្រសាំងនោះ ហើយយើងវាយការទៅ ក៏ដកចេញទៅ ។

ដារ៉ា : កាលហ្នឹងនៅតាំងក្រសាំងអង្គភាពមួយ ដែលតាមពូយល់ ជាកន្លែងមណ្ឌលកែប្រែហ្នេះពូ អ្ហេះ ក្នុងឋានៈជាអ្នកគ្រប់គ្រងកន្លែងហ្នឹងមានឋានៈស្មើនឹងស្អីពូ? ជាវរសេនាធំ ឬក៏កងពល អីដែរពូ?

សឿន : គាត់ហ្នឹងតាមយើងកាលហ្នឹង គាត់ហ្នឹងស្មើនឹងវរសេនាតូច ឋានៈគាត់ ។

ដារ៉ា : ស្មើត្រឹមវរសេនាតូចអ្ហេះ?

សឿន : បាទ បានក្រោយៗមកទៀតបានឡើង ដល់យើងមកនៅក្នុងព្រៃនេះហើយទេបានគាត់ឡើង អ្ហោះ ។

បូលី : ពូស្គាល់ តាញ៉ី កងពល២០៧ដែរ?

សឿន : តាញ៉ី ហ្នឹងខ្ញុំអត់ដែលស្គាល់ទេ ។

បូលី : ព្រោះតាបាវ ហ្នឹងអនុរបស់តាញ៉ី ២០៧ ហ្នឹង ។

សឿន : អាហ្នឹងយើងមកក្រោយនេះហើយ ។

បូលី : ប្រហែលជាឆ្នាំ៧៧ ៧៨ ពេលវ៉ៃជាមួយវៀតណាមអ្ហាះ ។

សឿន : អាហ្នឹងយើងដកទៅហ្នឹងគេដកគាត់ទៅដែរ ។

បូលី : មកខេត្តកំពង់ចាមហើយ ។

សឿន : បាទ ហ្នឹងហើយ តាអុល ហ្នឹងដកគាត់ទៅនៅហ្នឹង ។

បូលី : គេដកអ្វេះ?

សឿន : បាទ អានេះខ្ញុំអត់ដឹងទេ ។

ដារ៉ា : អីចឹងតាបាវ គាត់ឈ្មោះ បាវ តាំងពីហ្នឹងមកអីចឹងអូស?

សឿន : មិនដឹងជាគាត់ឈ្មោះអីទេកាលហ្នឹងអ្វេះ ប៉ុន្តែយើងដឹងតែបាវតាំងពីហ្នឹងមក ។,

ដារ៉ា : គាត់អ្នកស្រុកណា?

សឿន : នៅយើង មិនដឹងជាកំពត មិនដឹងជាតាកែវ ។

បូលី : សៀមរាប ។

សឿន : មិនមែនសៀមរាបទេគាត់អ្វេះ ស្រុកកំណើតគាត់នៅនឹង នៅខាងហ្នឹង ព្រោះអីមកពីខាងនារតីនឹងទាំងអស់ ។

ដារ៉ា : គាត់មកពីនារតីដែរអីចឹងហ្មោះ?

សឿន : បាទ ។

ដារ៉ា : ហើយមានជាករណីដាក់ស្តែងខ្លះទេ ដូចថាអ្នកដែលកសាងខ្លួនអត់បាន ហើយត្រូវបញ្ជូនទៅព្រៃស?

សឿន : មានដែរទេតើ ។

ដារ៉ា : មានច្រើនមានតិចពូ?

សឿន : បាទ មាន មានឧទាហរណ៍ថា ដូចថាយកទៅ យកទៅមាក់មុនហើយចឹងណា៎ អ្នកនោះឆ្លើយដាក់មក ហ្នឹងយកទៅទៀតហើយ ឬក៏មានសកម្មភាពខ្លះអ្នកហ្នឹងបាក់ដងចប បាក់អីអាហ្នឹងក៏យកទៅដែរ ។

ដារ៉ា : យកអីចឹង អ្នកដែលយកទៅមុន សុទ្ធតែយកចេញឈ្មោះណាបន្តទៅទៀតហើយអីចឹង?

សឿន : ទៅទៀតហើយ បើយើងធ្វើឲ្យគេស្រឡាញ់គេអាណិតយើង គេអត់ចេះឆ្លើយដាក់ទេ ព្រោះយើងអ្នកល្អអ្វាស គេដឹងថាយើងល្អគេមិនឆ្លើយដាក់ទេ គេហ្នឹងក៏ល្អដែរ គេល្អ ល្អត្រង់ថាគេធ្វើ ធ្វើទាំងបង្ខំចិត្ត ដោយសារខ្លាចគេអ្វាណា៎ ដល់អីចឹងទៅវាចេះតែឆ្លើយពាសវាលពាសកាលទៅអាខ្លះ ដែលវាមិន ដែលវាថាដូចជាស្អប់គ្នាខ្លះ ដល់ហ្នឹងចេះតែឆ្លើយដាក់ហើយខឹងគ្នាបន្តៗ ហើយខ្ញុំនេះមិនមានអ្នកណាអ្នកឆ្លើយដាក់ ព្រោះអីយុទ្ធជនៗទាំងអស់គេចូលចិត្ត ហើយខ្ញុំគ្រប់គ្រងខាងបច្ចេកទេសហ្នឹងគេចូលចិត្តទាំងអស់ ដល់អីចឹងគេថាខ្ញុំហ្នឹងមនុស្សល្អដែរទាល់តែសព្វថ្ងៃហ្នឹងនៅតែគេថាអីចឹង ជួបមុខគ្នាអី ហើយដល់អីចឹងទៅហ្នឹងអាអ្នកដែលកម្មាភិបាលអី ដែលដឹកនាំពីលើៗខ្ញុំនឹងទៀតទៅហ្នឹង វាច្រើនតែធ្វើតាមបញ្ជារបស់គេមកវាខ្លាំង ដល់ធ្វើខ្លាំងទៅយុទ្ធជនគ្នាអត់គាំទ្រ អត់គាំទ្រកាលហ្នឹងក៏យុទ្ធជនឆ្លើយ

ដាក់ដែរណា៎ ឆ្លើយដាក់ហ្នឹង សរសេរឈ្មោះមិនឆ្លើយមាត់ទេ សរសេរឈ្មោះយកទៅដាក់ ហើយប្រមូលទៅមែន ។

ដារ៉ា : ទោះបីជាមេៗហ្នឹងក៏ដោយ?

សឿន : បាទ ប្រមូលយកទៅអស់ អាហ្នឹងគេយកកងពល យកវរសេនាធំអីទៅអស់មួយចំនួនហើយណា នៅសល់អនុសេនាតូចអនុសេនាធំហ្នឹងទៀត ពេលហ្នឹងភ័យដោយសារយុទ្ធជនហ្នឹង មិនមែនភ័យពីខាងលើមកទេ ភ័យដោយសារយុទ្ធជនបុកវិញ ប៉ុន្តែគេតាមដានសកម្មភាពជាក់ស្តែង គេឃើញថាឯងហ្នឹងមាន ទំនាក់ទំនងជាមួយពួកហ្នឹងដែរ បានជាអ្នកឯងមកធ្វើខ្លាំងដាក់យុទ្ធជនអីចឹងគេរាយការណ៍ទៅតាមនឹងទៅ យុទ្ធជនសរសេរក្រដាស់ដាក់ទៅបណ្តោយ ។

ដារា : ចុះឈ្មោះ ឈាង ឈ្មោះ វ៉ាន់ អីហ្នឹង ទៅនឹងគេនឹងឯងដែរ? ដោយគេចាប់ទៅដែរ ឬក៏យ៉ាងម៉េច?

សឿន : អត់ពួកហ្នឹងមកក្រោយតើ មកជាមួយ តាបាវ ទេពួកហ្នឹងអ្ហោះ ឃន មួយទៀតហ្នោះ ។

ដារ៉ា : ឈ្មោះ ឃន?

សឿន : ឈ្មោះ ឃន បាទ ។

ដារ៉ា : ពេលដែលនៅតាំងក្រសាំង ពេលពូទៅដល់អ្នកណាអ្នកគ្រប់គ្រង?

សឿន : ឈ្មោះ បាវ ហ្នឹងហ្នង ។

ដារ៉ា : អូរចូលដល់តាំងក្រសាំង គឺឈ្មោះ បាវ នឹងហើយនេះ ដែលគ្រប់គ្រងនៅពេលហ្នឹង?

សឿន : បាទ ខ្ញុំអ្នកដាំងបាយ ទៅដល់ហ្នឹងគេឲ្យនៅដាំបាយ (សើច) ។

ដារ៉ា : ទៅដល់ហ្នឹងបានធូរវិញ?

សឿន : បានធូ ក៏ប៉ុន្តែបានធូ អ្នកទាំងអស់ហ្នឹងស្រឡាញ់យើងវិញ បាយយើងពូតទៅបានបិុនកដៃ ហើយសម្លមួយឆ្នាំងហ្នឹងទៅគ្នា៨-៩នាក់ ហ្នឹងហូបម៉េចឆ្អែត គ្នាបេះបន្លែបេះអីយកមកដាក់ថែមទៅ ដល់អីចឹងទៅខ្ញុំមើលឃើញគ្នាដូចថាកាន់តែហេវអីចឹងទៅ កំសៀវធំៗហើយ អាបាយក្តាំងដែលយើងហាលទុកហ្នឹងយកវាមកដាក់ស្ងោរទៅ ដក់ស្ករត្នោតមួយដុំឲ្យផ្អែមខាប់បន្តិចទៅ ហូបបាយរួចយើងបេះតែកេះទៅហ្នឹង ដឹកទឹកក្តៅទៅកុំដឹកទឹកត្រជាក់ ទឹកក្តៅនៅនឹងកំសៀវអួស ប៉ុន្តែយើងលាក់ដែរ លាក់ពីពួកអស់ហ្នឹងដែរណា៎ វាមិនឲ្យដឹងអ្ហោះ ទៅដល់ហ្នឹងក៏គេចាក់មក ទឹកដឹកទៅ គេអត់មាត់ទេ គេដើរចេញទៅ គេដឹកបន្តិចៗម្នាក់ចែកគ្នាដឹកទៅ គេបាស្អ ដូចយើងស្ងោរបាយជាមួយហ្នឹងហើយណា៎ ហូបអីចឹងទៅបានគេចេះតែស្រឡាញ់យើង ហើយអំបិលអីចឹងទៅ ជួនកាលយើងលួចឲ្យទៅគ្នាទៅ គ្នាទៅកន្លែងហ្នឹងទៅ

បានត្រីបានអីទៅដុតហូបហ្នឹងទៅ ល្ងួចដុតហូបហ្នឹងទៅ មានអំបិលមានអីចុច អីចឹងទៅគ្នាអត់ហើយ ។

ដារ៉ា : ចុះពូធ្វើអីចឹងមិន វាប្រជុំយហ្នឹងគ្រោះថ្នាក់ពូដែរអេះ?

សឿន : មិនប្រជុំយយើងអាណិតគ្នា ទាល់តែប្រជុំយខ្លះ ជួយគ្នាទៅ បើថាម៉េចម៉ាវាទៅទាំងអស់ទៅ ពួកនឹងគេថាបើម៉េចម៉ាទៅទាំងអស់គ្នា ទៅទៀតហ្នឹងហើយ បើគេថាយើងក្បត់ម៉េច ក្បត់តែទាំងអស់ទៅ ធ្វើម៉េចឲ្យតែមានសុខភាពសិនទៅ ហើយអីចឹងយើងចេះតែជួយគ្នា ប៉ុនអាគេមកគេថាចាប់ពួកក្បត់ ហើយចុះអាក្រោយមកហ្នឹងទៀតម៉េចក៏ ហ៊ឹះគេថាធ្វើសកម្មភាពអីចឹងសមនឹងមុខពួកអ្ហែង សុទ្ធតែពួកក្បត់ នឹងគេថាអីចឹង ខ្ញុំថាបើចាប់អាពួកក្បត់ទៅហើយហ្នឹងក្រោយមកឲ្យវាល្អទៅ នៅតែដូចអាគ្នាដដែល ហូបបាយឆ្អែតមួយដុមប៉ុនកដៃហ្នឹងហើយរត់ពីវត្តឃ្មុញមកដល់តាំងក្រសាំងវិញដេក ប្រជុំ ប្រជុំទាល់តែម៉ោង១ ម៉ោង២ ដេកបានបន្តិចងើបឡើង ម៉ោង៤ម៉ោង៣អីងើបឡើង ងើបមកស្រែវិញ ងើបទាំងល្ងិតមកវិញហើយហើយរត់ទៀត ។

ដារ៉ា : ហើយចុះពូ វាសនាអ្នកដែលទៅដល់ព្រៃសហ្នឹង យ៉ាងម៉េចដែរពូ? បើសិនទៅដល់ហ្នឹងហើយអ្ហាះ?

សឿន : ទៅដល់នឹងហើយគឺចប់ ដូចជាមិនឃើញអ្នកណាមួយវិលវិញសោះ បាត់ឈឹង ។

ដារ៉ា : ពីកន្លែងពូទៅព្រៃសឆ្ងាយទេ?

សឿន : ពីតាំងក្រសាំងទៅប៉ុន្មានគីឡូ ដល់អាដេញនៃគុកទួលស្លែងនឹងអីហ្នឹងឯង កន្លែងយើងរាល់ថ្ងៃនឹង កន្លែងនឹងមិនដឹងជាប៉ុន្មានគីឡូ មិនដឹងដែរ ។

ដារ៉ា : ពូសំដៅថាព្រៃស ហ្នឹង គឺមកគុកទួលស្លែង ឬក៏ព្រៃសហ្នឹងមិនមែនគុកទួលស្លែងទេ ជាកន្លែងមួយផ្សេងទៀត ដែលតាមពូយល់?

សឿន : កាលហ្នឹងគេហៅថាព្រៃស មិនដឹងជាគុកកន្លែងណា បុនគេនាំខ្ញុំទៅមើលគុកដែលយើងទៅមើលរាល់ថ្ងៃហ្នឹងណា កាលដែលគេនាំខ្ញុំទៅមើលគឺគុកត្រង់នឹងឯង ។

ដារ៉ា : អីចឹងពេលដែលជំនាន់ហ្នឹង ដែលពូថាបញ្ជូនពីកន្លែងតាំងក្រសាំង ប្រសិនជាធ្វើខុសទៅព្រៃសហ្នឹងពូសំដៅថាទៅកន្លែងណា?

សឿន : មិនដឹងជាទៅកន្លែងណា ។

ដារ៉ា : អត់ដឹងទេ?

សឿន : បាទ អត់ដឹងទេ ព្រោះអីកាលហ្នឹងគេនាំទៅកន្លែងសារមន្ទីរសព្វថ្ងៃហ្នឹង គឺគេនាំទៅមើលត្រង់នឹង ដល់ត្រឡប់មកវិញ គឺនឹកឃើញតែកន្លែងនឹងឯង ។

ដារ៉ា : អីចឹង?

សឿន : បាទ នឹកឃើញតែកន្លែងហ្នឹង អត់ដឹងថាកន្លែងណាទៀត ។

ដារ៉ា : ហើយចុះពូបានទៅមើលដើងឯកទេ?

សឿន : ដើងឯកអត់ដែលបានទៅ ។

ដារ៉ា : តែបានទៅមើលកន្លែងស-២១ កន្លែងទួលស្លែងហ្នឹង គុកទួលស្លែងឥឡូវ?

សឿន : បាទ ទៅមើលហ្នឹង កន្លែងហ្នឹង ទៅមើល២ដងហើយ ។ ទៅសារមុននឹងទៅខ្លួនឯង ទៅសារក្រោយទៀតជូនប្រជាជនទៅ ខាងសារមន្ទីរគេមកនាំទៅ ក៏ជូនទៅ ទៅខ្លួនឯងហ្នឹងពីរដងហើយ ។

ដារ៉ា : អីចឹងពេលនឹងពូយល់ថា អាទៅព្រៃសហ្នឹង គឺបញ្ជូនទៅកន្លែងគុកហ្នឹងឯង?

សឿន : បាទ យល់ឃើញថាត្រង់ហ្នឹង ព្រោះវាថាព្រៃសៗដល់ពេលគេនាំឲ្យទៅមើល មួយជំនាន់នឹងអ្ហា: គេនាំទៅមើលទៅមើលអាកន្លែងហ្នឹង អារម្មណ៍ដឹងថាកន្លែងហ្នឹងឯងខ្ញុំព្រៃស(សើច) ។

ដារ៉ា : អីចឹងកាលពីជំនាន់ខ្មែរក្រហមហ្នឹងឆ្នាំ៧៧ ចិតអីហ្នឹងហ្នឹងពូពុថា បញ្ជូនទៅព្រៃស អត់ពុជាស-២១ ឬក៏អីអេះពូអ្ហែះ ឬក៏មន្ទីរសន្តិសុខអី អត់ពុអីចឹងអ្ហេះអ្ហែះ?

សឿន : អត់ទេ អត់ពុទេ មក៧៧-៧៨ អត់ពុដឹងថាស-២១ អីក៏អត់ដឹងដែរ ដឹងតែព្រៃសៗ ។

ដារ៉ា : អីចឹងពេលពូ ហេតុម៉េចបានជាគេរើសពូពីកន្លែងតាំងក្រសាំងនឹងទៅទល់ដែនវិញ ពេលនឹងវាមានសភាពការណ៍ប្រែប្រួលយ៉ាងម៉េច នៅក្នុងរបបខ្មែរក្រហមនឹងបានជ្រើសរើសពូទៅព្រំដែន វិញ ។

សឿន : ជ្រើសរើសហ្នឹងជ្រើសរើសនៅក្នុងកន្លែងនឹងអ្នកទ័ពអង្គភាពគេយកទៅបង្កើតជាអង្គភាពមួយទៀត វាអត់មានកម្លាំងអ្ហា: យើងត្រូវការកម្លាំង ហើយខ្ញុំហ្នឹងក៏គេឲ្យទៅធ្វើពេទ្យវិញដដែល ហើយនឹងមានមិត្តភក្រ្តខ្លះថា ហ៊ុកុំនៅតទៅទៀត នៅកន្លែងនឹងក៏វាមិនកើតដែរ ដូចថាទៅវ៉ៃលុក ដើម្បីលាងទោសកំហុសរបស់យើង ។

ដារ៉ា : អីចឹងអ្ហេះ?

សឿន : ហ្នឹងហើយ អ្នកដែលគេថាអីចឹងណ៎ា ខ្ញុំថាហ៊ុយល់ច្រលំហើយ យើងយល់ច្រឡំហើយ កុំថាវ៉ៃលុកលេខ កុំថាវ៉ៃលាងអីទោសកំហុសរបស់យើងអីទេ អារម្មណ៍ពីគេមកគេថាយើងយ៉ាងម៉េច គឺនៅតែដដែលអីចឹងឯង ទោះបីវ៉ៃយ៉ាងណាក៏ដោយ ក៏នៅតែគេថាយើងអីចឹងដែរ ទាល់តែខាងភូមិភាគយើងដឹកនាំខ្លួនឯងតែហ្នង ហ្នឹងបានវាល្អឡើងវិញ បើឲ្យគេគ្រប់គ្រងដដែលហ្នឹងគេថាយើងតែពួកក្បត់ដដែលហ្នឹង នេះទើបតែមកយើងអាដេញនែ៎មករត់ចូលព្រៃ ហើយទេបានកែប្រែ អីៗខ្លះទៅ កែប្រែនឹងដោយសារតែ ខ្ញុំអត់ទាន់ដឹងថាយ៉ាងណាទេ

ប៉ុន្តែខ្ញុំចូលមកតាំងពីឆ្នាំ៨៤ អូ!៨១ ខ្ញុំចូលមកវិញនឹងក៏មើលទៅសភាពការណ៍គេកែប្រែនឹងខុសពីមុន បាទវាអត់មានបញ្ហាអីទេ ។

ដារ៉ា : ពេលដែលពូបញ្ជូនទៅសមរភូមិព្រំដែននឹងពូចូលក្នុងកងអី?

សឿន : នៅក្នុងវរៈសេនាធំ នៅជាមួយវរៈសេនាធំ ខ្ញុំពេទ្យតាមវរៈសេនាធំ ។

ដារ៉ា : វរៈសេនាធំប៉ុន្មាន?

សឿន : លេខប៉ុន្មានទេ មិនចាំទេ ដឹងតែកងពលជាមួយអាដេញរ៉ែ តាញ៉ន នឹងឯង នៅកងពលជាមួយនឹងគាត់ ។

ដារ៉ា : តាញ៉ន អីចឹងអ្ហេស?

សឿន : បាទ ។

ដារ៉ា : កងពលប៉ុន្មានអាហ្នឹងកាលនឹង?

សឿន : អាហ្នឹង៦០៣ហើយ គេដាក់៦០៣វិញហើយ ហើយវរៈសេនាតូចនឹងមានឈ្មោះ ធី ឈ្មោះ ធី មួយ ឈ្មោះ រ៉ាន់ មួយ ។

ដារ៉ា : រ៉ាន់ ដែលនៅតាំងក្រសាំងនឹងមែន?

សឿន : មិនមែន ជាអ្នកផ្សេងទេ ។

ដារ៉ា : ជាវរៈសេនាតូច?

សឿន : បាទ វរៈសេនាតូច នៅជាមួយនឹងគាត់ ។

ដារ៉ា : ចុះវរៈសេនាធំអ្នកណាពូ?

សឿន : វរៈសេនាធំ ទេកាលហ្នឹងបង ញ៉ន នឹងនៅវរៈសេនាធំ ។ បងវិន កងពល បាទនឹងហើយមិនទាន់ឡើងកងពលទេ បងញ៉ន កាលនោះ ។

ដារ៉ា : ហើយជាមុខព្រួញសមរភូមិនៅកន្លែងណាពូ?

សឿន : លើកទីមួយទៅវៃនៅតាកែវ មុខព្រួញគីរីវង់ ស្រុកគីរីវង់ ទៅទល់ព្រំដែនស្រុកយួននោះ អាងយ៉ាង សំបុកមាន់ ទៅនៅហ្នឹងបានប៉ុន្មានខែទេ ដកពីនោះមកវិញទៅវៃនឹងយើងខាងមេមត់ ស្នួ ចាន់មូល អាហ្នឹងមុខព្រួយមុខវៃហើយ ។

ដារ៉ា : ស្នួ ចាន់មូល ចឹងអ្ហេស?

សឿន : បាទ ចាន់មូល ។

ដារ៉ា : ពូនៅក្នុងពេលប្រយុទ្ធម្តងៗ នៅក្នុងអាគីរីវង្សអីហ្នឹង ប្រយុទ្ធជាមួយវៀតណាមហ្នងអ្ហេស?

សឿន : បាទ ។

ដាវ៉ា : ប្រយុទ្ធដោយសារអីចូ ដោយសារថាមានការឈ្លានពាន ឬក៏ចូលឆ្លងដែន ចុះឡើងៗ ឬក៏យ៉ាងម៉េច?

សឿន : យើងអត់ដឹងទេ ដឹងតែវៀតណាមចូលមកដល់ស្រុកយើងហ្នឹង យើងដឹងតែគេឈ្លានពានយើងបណ្ដោយ ។

ដាវ៉ា : ពេលវ៉ៃនឹងវាមានលក្ខណៈដាយ៉ាងម៉េចពីការវ៉ៃហ្នឹង លក្ខណៈជាទ្រង់ទ្រាយអ្វាស ខ្ញុំចង់សួរអ៊ីចឹងអ្វាស?

សឿន : វ៉ៃនឹងលក្ខណៈជាទ្រង់ទ្រាយធំដែរនឹងអ្វាស ព្រោះកាំភ្លើងធំយើងវាច្រើនដែរ ប្រើ១៣០ ហើយកាំភ្លើងធំថ្មើរជើងមាន១២០ ដេកា៧៥ ដេកា៨២ ក៏វាច្រើនដែរ ។

ដាវ៉ា : អ៊ីចឹងក្នុងសង្គ្រាមហ្នឹងមានប្រើប្រាស់កម្រិតហ្នឹងអ្វែស?

សឿន : បាទ! ច្រើន វាទ្រង់ទ្រាយធំហើយ ព្រោះអីយើងប្រើកាំភ្លើងធំក៏វាច្រើនដែរ យើងវ៉ៃ វ៉ៃនៅហាំងប៉ុន្មានអ្វែស ៧ថ្ងៃអ្វែស បានយួនដកចូលទៅស្រុកគេវិញ ចូលទៅហើយយើងវ៉ៃចូលទៅស្រុកគេទៀតអ្វាស បាទ យើងវ៉ៃឆ្លងទៅហ្នឹងទៀត ម្ដុំអាងយ៉ាង សំបុកមាន់ហ្នឹងយើងវ៉ៃហ្នឹង រហូតទៅដល់ភ្នំដូរចូលដល់៤០គីឡូ ។

ដាវ៉ា : ចូលទៅដីវៀតណាមហ្នឹង?

សឿន : បាទ! ៤០គីឡូអ្វាស ចូលទៅក្នុង អ្នកបង្កប់ខនទៅក្នុងហ្នឹងបង្កប់ខ្លួន អ្នកបង្កប់ខនទៅក្រៅកម្ពុជាក្រោមក៏បង្កប់ខ្លួន យើងអ្នកធ្វើសកម្មភាពនៅទល់ដែននឹងក៏ធ្វើតាមហ្នឹង បាទ! នៅទាំងអស់ ។

ដាវ៉ា : ចលទៅដល់ជ្រៅអីចឹង វៀតណាមធ្វើយ៉ាងម៉េចទៅអីចោះ?

សឿន : ប្រជាជនកម្ពុជាក្រោមយើងជួយការពារ នៅហ្នឹង ហើយខ្ញុំអីហ្នឹងចូលទៅជួយព្យាបាលប្រជាជននៅក្នុងកម្ពុជាក្រោមនឹង លាក់ខ្លួននៅតាមផ្ទះតាមអីហ្នឹង ហើយពួកវៀតណាមសុទ្ធៗហ្នឹង ដូចរបងការពារយើងអីចឹង វាធ្វើផ្ទះវាជុំវិញអីចឹង ប្រជាជនវាណ៎ា ហើយយើងចូលទៅនឹងវាលាក់ខ្លួន អត់ឲ្យយើងដើរទៅណាទេ យើងជួយមើលសុខភាពគាត់អីចឹងទៅ ។

ដាវ៉ា : មើលអ្នកណា?

សឿន : មើលនៅក្នុងភូមិ ។

ដាវ៉ា : មើលអ្នកណា?

សឿន : មើលប្រជាជនកម្ពុជាក្រោម កងទ័ពផង ។

ដាវ៉ា : តែវៀតណាមព័ទ្ធជុំវិញអស់ហើយ?

សឿន : វៀតណាមព័ទ្ធ ប្រជាជនគេព័ទ្ធ ព័ទ្ធប៉ុន្តែអត់មានកងទ័ពទេ ដូចថាកងទ័ពគេគ្រាន់តែចេញចូលដើរលេងអីចឹងទៅណា៎ គេនៅការតាមព្រំដែនឯនោះទេ ។

ដារ៉ា : អីចឹងគេដឹងថាពូជាពេទ្យខាងខ្មែរក្រហមដែរ?

សឿន : ពេទ្យ ខ្ញុំចូលទៅបួន-ដប់ថ្ងៃ ខ្ញុំចេញមកវិញមក ហើយគេឲ្យចូលទៅសើបអង្កេតសើបការអីផងនោះ មិនមែនធម្មតាទេចូលទៅ កុំថាសប្បាយអរអីនោះ ម្នាក់ៗសុទ្ធតែខ្លាចទាំងអស់តែគ្នាហ្នឹងចូលទៅនោះ ។

ដារ៉ា : ខ្លាចយ៉ាងម៉េចទៅពូ?

សឿន : ខ្លាចនឹងតាំងខ្លួនឯងថាងាប់ហើយ ចុះបើចូលទៅស្រុកគេទៅហើយ ។

ដារ៉ា : តែពួកវៀតណាមដឹងទេពូ?

សឿន : កងទ័ពហើយហ្នឹងប្រជាជនវៀតណាមសុទ្ធហ្នងគឺមិនដឹងទេ សូម្បីតែប្រជាជនកម្ពុជាក្រោមក៏ដឹងភាគតិចដែរ ទាល់តែអ្នកមានការតស៊ូជាមួយខ្មែរយើង អាហ្នឹងគេដឹងទៅណា ។

បូលី : អីចឹងពូនិយាយពីអ្នកដែលចូលទៅបង្កប់ខន?

សឿន : បាទបង្កប់ខ្លួនហ្នឹងឯង ។

បូលី : អីចឹងពូក្នុងចំណោមអ្នកបង្កប់ខ្លួននឹងដែរ?/

សឿន : បាទ! ខ្ញុំចូលទៅម្ដងៗ ចូលថ្នាំពេទ្យអីទៅមើលព្យាបាលបងប្អូនយើងកងទ័ពនៅនឹង ។

បូលី : ចុះកងទ័ពពេលដកនាំចូលទៅ ពូថាចូលដល់៤០គីឡូនឹងម៉េចដែរ?

សឿន : អានឹងខាងស្រុកគេ ខាង តា ម៉ុក នៅនឹង ។

បូលី : មិនមែនខាងពូទេ?

សឿន : មិនមែនទេ មិនមែនកងពលយើងទៅពីភ្នំពេញទេ ខាងតំបន់ទេ ។

បូលី : កងពលលេខប៉ុន្មាន?

សឿន : អត់ដឹងទេ ប៉ុនគេហៅឈ្មោះ អាចារ្យ កួង នៅភ្នំខ្ទុរអានឹងដឹង គ្រាន់កាំភ្លើងធ្លោងយើង ១៣០ ធ្លោងទៅ អត់ពុស្ទូរធ្លាក់ទេ

ដារ៉ា : ម៉េចចឹង?

សឿន : ចុះវាឆ្ងាយពេក មិនដឹងជាប៉ុន្មានគីឡូម៉ាផុតកាណុង១៣០ ៗ ៣គីឡូដាង បាញ់ដីរាបស្មើ ៗ បើដាក់លើភ្នំគីរីវង់ផង បាញ់ជាប់ប្រហែល៣៥គីឡូដាង បាញ់បានឆ្ងាយ ។ ដាក់លើភ្នំគីរីវង់កាប៉ាល់ហោះសណ្ដោងដាក់លើនឹងបណ្ដោយ ។

បូលី : ខ្ញុំពុស្ទូរ២ ខ្ញុំសម្ភាសន៍ជាមួយប្រជាជនខាងនឹង មើលពូជួយវាយតម្លៃ តើមតិនឹងយ៉ាងម៉េចដែរ ទី១ខាងខ្មែរក្រហមវៃចូលទៅដល់ដីវៀតណាម សម្លាប់ជនជាតិវៀតណាមច្រើនមែន

ទែន ៗ ហើយកន្លែងដែលសម្លាប់ ចាប់កាត់កវៀតណាម គ្នាទុកទាល់រាល់ថ្ងៃនឹង ៗ វៀតណាមរក្សាទុករាល់ថ្ងៃនឹង យ៉ាងម៉េចដែរ?

សឿន : អានឹងខ្ញុំឮសូរនិយាយចឹងដែរ ខាងកងទ័ពគេនឹង គេសប្បាយគេទេ គេនិយាយអ្នកសប្បាយទេ ប៉ុន្តខ្ញុំយើងទៅវៃនឹងវាក្រោយគេទេ ព្រោះតែអាបញ្ហាពីមុនមកនឹងហើយ ដែលថាសម្លាប់ដូចថាមិញនឹង អានឹងគេមុន ៗ ហ្នឹងហើយគេវៃចឹងមែន សម្លាប់ចឹងមែន បោះក្មេងឡើងលើ យកជំពុះទង់ទ្រអីក៏មាន នឹងយើងចូលដល់ស្រុកគេ ខាងកងទ័ពនៅនឹង ហៅកងទ័ពតំបន់នឹង ព្រោះចឹងហើយបានគេវៃលុកមកជិតខេត្តតាកែវ ៗ

បូលី : វៀតណាមវៃមកវិញ?

សឿន : ហ្នឹងវៃមកវិញ អានឹងចឹង វៃបកមកវិញបានជិតដល់ខេត្តតាកែវនឹង មកដល់គិរីវង់នឹង ហួសគិរីវង់នឹង បានដកពួកខ្ញុំអីនឹងជ្រើសរើសយកមកវៃនឹង ៗ

បូលី : អូ! យកទៅជួយទប់?

សឿន : ហើយដល់ពេលវៃទៅដល់នឹង បានឮសូរពួកនឹងនិយាយប្រាប់ដូចមិញចឹងឯងដូចគ្នា ៗ

ដារ៉ា : ខាងខ្មែរក្រហមនឹងនិយាយប្រាប់?

សឿន : បាទ! អ្នកនៅកាន់កាប់នៅនឹង អ្នកនៅតំបន់នឹង ៗ

ដារ៉ា : គេប្រាប់ថាម៉េច?

សឿន : គេនិយាយប្រាប់ថាទៅសប្បាយណាស់ បានចូលទៅដល់នឹង បានស្រីៗយួន គេសម្លាប់ ខ្លះសុទ្ធតែចាប់ហែកកូនយួនអាក្នុងអង្រឹង រត់ចោលបាញ់ អាខ្លះលើបោះដាក់ជំពុះទង់ទ្រចឹង ៗ គេនិយាយប្រាប់ចឹង គេថាគេសប្បាយណាស់ចូលដល់ស្រុកយួនម៉ាសារនោះ ៗ ហើយយើងនឹងទៅនឹងគេនិយាយប្រាប់យើងពីមុនមក វាមានមែន វាមិនអត់ ៗ

ដារ៉ា : កាលនឹងកងអ្នកណា កង តា ម៉ុក កងអី?

សឿន : ហ្នឹងនៅកាលនឹងមាន តា ម៉ុក នឹងឯងខាងតាកែវខាងអីនឹង បនយើងមិនដឹងជាកងពលណា វរៈសេនាតូច វរៈសេនាធំណាយើងអត់ដឹង ៗ

ដារ៉ា : ចុះពេលដែលកងពលពូទៅដល់ ដែលថាជាកងពល៦០៣ ពេលទៅដល់ មានកងតំបន់ មានកងអីគេនៅនឹង?

សឿន : គេនៅនឹងឯង ៗ

ដារ៉ា : ចឹងពេលទៅដល់ពូស្គាល់ ឬឮជាឈ្មោះអ្នកណា ដែលនៅមូលដ្ឋាននឹងស្រាប់ហើយ?

សឿន : បាទ! អត់ដែលបានឮសូរឈ្មោះអីទេ យើងមិនបានទំនាក់ទំនងគ្នាអី ក៏ស្គាល់ឈ្មោះអីក៏ឮសូរគេហៅឈ្មោះអីអត់ទេ ៗ ប៉ុន្តគ្រាន់យើងដើរទៅជិតៗចឹង គេនិយាយគ្នាគេ យើងស្តាប់បាន

ហើយមានខ្លះទៀតគេស្គាល់ ដែលអ្នកមកពីតាកែវមកគ្រប់គ្រងភូមិភាគខត្តរនឹងគេមកអង្គុយនិយាយលេង គេប្រាប់ទៅ យើងស្តាប់ទៅគេនិយាយ ។ បាទ! មានមែនទន់ឯង ។

បូលី : ហើយទី២ គេថា តាមពិតខ្មែរក្រហមដែលវ៉ៃចូលដីវៀតណាមបាន តាមពិតវៀតណាមដកថយ ដើម្បីវ៉ៃចូល ដើម្បីគេព័ទ្ធក្រោយមកវិញសង្កប់ទៅចេះម៉ង បានជាខ្មែរក្រហមស្លាប់ច្រើនណាស់ ម៉ាកងពលថានៅសល់ប៉ុន្មាននាក់មកវិញ បើរថក្រោះកិនយកម៉ង ។ អានឹងពូឮម៉េចដែរ?

សឿន : អានឹងក៏ឮសួរគេនិយាយចឹងដែរ ។ វ៉ៃៗទៅចេះតែលុងៗចូលៗទៅ ។ ទៅដល់នោះគេលេងពីក្រោយមកវិញ ព័ទ្ធជាប់ចឹងទៅ ប៉ុន្តែព័ទ្ធជាប់ដីគេនឹង ខ្ញុំអត់ដឹងដែរ ។ បើមកព័ទ្ធនៅក្នុងដីខ្មែរយើងក៏មានព័ទ្ធដែរ ។

បូលី : វៀតណាមព័ទ្ធដែរ?

សឿន : បាទ! ព័ទ្ធដែរតើ ទ័ព្វអស់យកបាយអីទម្លាក់ឲ្យហូប បានដកពួកខ្ញុំអីទៅជួយវ៉ៃបែកបានចេញមកវិញបាន ។ នៅខាងបូព៌ាក៏ចឹងនៅខាងនឹង យើងខាងមេម៉ត់ខាងអីដែរនឹង ព័ទ្ធម៉ាសារដែរនឹងតាំងពីស្វាយរៀងអីនឹង ព័ទ្ធច្រើនកន្លែង ស្វាយរៀងក៏ព័ទ្ធ ទៅតាកែវក៏ព័ទ្ធ ខាងយើងមេម៉ត់នឹងក៏ព័ទ្ធ ។

ដារ៉ា : សុទ្ធតែវៀតណាមព័ទ្ធជាប់បាន?

សឿន : បាទ! ព័ទ្ធជាប់បានទាំងអស់ ហើយដល់ពេលពួកខ្ញុំផ្លាស់ពីនឹងមកនៅវ៉ៃខាងមេម៉ត់នេះវិញ ព័ទ្ធពួកខ្ញុំជាប់ដែរតើឡើងកន្លះខែ ទម្រាំវ៉ៃបើកចេញទៅវិញបាន ។ អានឹងយើងនិយាយទៅថាដូចគេថាពួកវាមានខ្សែវានៅពីក្នុងបានឃ្លួនវាព័ទ្ធពួកយើងបាន ខ្ញុំថាវាម៉េចៗក៏ទៅ ។

បូលី : បើតាពូយល់ ពូគិតថាម៉េច មកពូខ្សែនឹងឬយ៉ាងម៉េច?

សឿន : ខ្ញុំដូចថាពិបាកដែរ មួយថាមួយពីរថាពីរចឹង ដូចពិបាករកជឿអីមិនឃើញ ដល់ចឹងវាពិបាកដែរ ។ ដូចខ្ញុំនិយាយមិញថា អាមួយទៅហើយ អាមួយទៀតថាក្បត់ ដកអាមួយទៀតៗថាក្បត់ទៀត មិនដឹងជាអ្នកណាក្បត់ពេញផ្ទៃប្រទេសឲ្យពិតប្រាដក ។ ហើយថាមានខ្សែបង្កប់ខ្សែអីមិនដឹងជាយ៉ាងម៉េច មិនដឹងជាអ្នកណាមួយអីអ្នកណាមួយ យើងតាមដានវាមិនដឹងអីសោះចឹង ។ ហើយព័ទ្ធជាប់នឹងឡើង៦-៧ថ្ងៃ ហើយចេះថាមានខ្សែវាបានព័ទ្ធជាប់ ។ ហើយវ៉ៃបើកវិញ ទម្រាំបានវៀតណាមរត់បានចេញមក ។ ខ្ញុំថាមិនរស់ទេ កាលនោះ ។

ដារ៉ា : ព័ទ្ធរបៀបម៉េច បើចូលក្នុងសមរភូមិព័ទ្ធយ៉ាងម៉េចបានយើងអាចចេញមកវិញបាន?

សឿន : កាលនោះ បើយើងនិយាយទៅ ពួកនឹងទៅដល់ខាងបូព៌ានឹងទៅ ឮថាពួកបូព៌ា បានពួកនឹងសម្លាប់ប្រជាជនបូព៌ា សម្លាប់កងទ័ពគេនឹង ។ ថារឿងទៀតហើយ ខ្ញុំចេះថាងាប់ទៀតអញ

ពេលនេះ ចេះនឹកឃើញ ៗ ដល់ចឹងទៅពួកនឹងក៏មានរត់ទៅខាងវៀតណាមនឹងទៅណា ដោយសារខ្លាចមនុស្សស្លាប់ ខ្ញុំអីបិសៗនឹងទៅហើយតើ ចាំមើលតិចទៀតនឹងនាំគ្នាទៅម៉ាវរសេនាតូចដែរ ៗ និយាយត្រូវគ្នាហើយ ថាមេចម៉ាអីកុំនៅ យើងទៅ ៗ ដល់រត់ចឹងទៅបានពួកនេះចេះនាំវៃព័ទ្ធពួកយើងៗទៅគ្មានស្គាល់ភូមិសាស្ត្រណាប៉ុន្មាន មានតែខ្មែរគ្នាឯងព័ទ្ធនោះ ដល់ចឹងទៅបានយួនវាមកព័ទ្ធតាមក្រោយទៀត បានដកខ្មែរចេញ ព័ទ្ធឡើង៧ថ្ងៃពួកខ្ញុំ ៗ ប៉ុនព័ទ្ធនឹងមានស្រូវ មានអង្ករបុកហូប កុំអីស្រេចហើយ ៗ ភ័យខ្ញុំកាលនោះ នឹកឃើញថាអត់បានជួបមុខម៉ែទៀត បានចេញផុតមកនឹងទៅ បានអរបានគេបញ្ជូនមកដេកពេទ្យ ខ្ញុំគ្រុនដេកៗយកតែមែនទែននឹង ៗ

ដារ៉ា : ដេកនៅណា?

សឿន : ដេកភ្នំពេញ ៗ

ដារ៉ា : មកភ្នំពេញវិញ?

សឿន : បាទ! បញ្ជូនមកភ្នំពេញ ខ្ញុំគ្រុន ចុះយើងនៅបូព៌ាសភាពការណ៍យើងដឹងថា វាមិនទំនងចាញ់គេហើយណា បញ្ជូនទៅភ្នំពេញ ៗ តែប៉ុននេះលែងទៅហើយ រហូតទាល់តែដាច់ ៗ

ដារ៉ា : បញ្ជូនមកពេទ្យភ្នំពេញនឹង ដេកពេទ្យណា?

សឿន : ពេទ្យយើងពេទ្យសូវៀត ១៧មេសា ៗ

ដារ៉ា : ពេទ្យ១៧មេសា ពេទ្យសូវៀតនឹង ពេទ្យរូស៊ីឥឡូវ?

សឿន : ពេទ្យរូស៊ីនឹង ៗ ខ្ញុំដេកនៅនឹង ក៏គ្មានគេបើកដៃដែរ គូដណ្តឹងគេមើលថែទាំចឹងទៅ ៗ

ដារ៉ា : ចុះពូមានគូដណ្តឹង?

សឿន : មានៗហើយ ពេទ្យគ្នាឯង ប៉ុនអត់បានគ្នា ៗ គេនៅកន្លែងកាត់ដេរនោះ ពេលគេរត់ទៅ គេអត់មានមកយើងនេះ គេរត់ទៅមុនយើង តាមរកគ្នាមិនឃើញ ហើយខ្ញុំបកមកផ្ទះមកវង់ៗមកតាមយើងកំពង់លួងចេតយព្រៃថ្មីនោះ កាត់មកលើទំនងកំពង់លែង កាត់លើទំនប់កាត់តាមនឹងមកផ្ទះមក ៗ

ដារ៉ា : ពូបានជាគូដណ្តឹង?

សឿន : បាទ! ត្រឹមគូដណ្តឹង ៗ

ដារ៉ា : ស្គាល់គ្នាតាំងពីពេលណា?

សឿន : គូដណ្តឹងយើងស្គាល់គ្នាតាំងពីយើងឆ្នាំ៧៤មក ៗ ពួកគេនៅក្នុងកងទ័ពនារី ៗ ប៉ុនយើងមិនទាន់បានដណ្តឹងអីគ្នាទេ បានត្រឹមម៉ាស្គាល់គ្នាចឹងទៅ ៗ ដល់ពេលគេមកនៅពេទ្យជាមួយគ្នាទៅ

គេរៀបចំគូដណ្តឹងនឹងឲ្យមកនោកន្លែងវះកាត់ជាមួយខ្ញុំ។ ដល់នៅនឹងបានប៉ុន្មាន ក៏គេផ្សំផ្គុំឲ្យគ្រាន់តែដណ្តឹងសិន។

ដារ៉ា : មិនទាន់រៀបការទេ?

សឿន : មិនទាន់រៀបទេ។ ដល់យូរៗទៅ ក្រៀបពេក មានសភាពការណ៍រឿងក្បត់រឿងអីទៅក៏អត់បានគ្នា បែកគ្នាទៅ។

ដារ៉ា : ចុះពេលដែលពូចាប់នោកន្លែងតាំងក្រសាំងនឹង គូដណ្តឹងពូទៅណា?

សឿន : នៅក្បែរៗគ្នានឹងឯង។

ដារ៉ា : គេចាប់ទៅទាំងអស់ដែរ?

សឿន : បាទ! ចាប់ទៅ ប៉ុនកន្លែងនារីគេដាក់ផ្សេង នៅ តា យ៉ាន់ នឹងឯងអ្នកគ្រប់គ្រង ស្រីៗ តា យ៉ាន់។

ដារ៉ា : ឈ្មោះ យ៉ាន់ កងពល៤៥០?

សឿន : បាទ!

ដារ៉ា : ចឹងអត់ចាប់ទៅទេ យ៉ាន់ នឹង?

សឿន : បាទ! អត់ទាន់ចាប់ទេ ទាល់តែមកយើង៧៨នឹង ជិតចុះទៅវៀយួនហើយនឹង បានគេចាប់គាត់ៗនឹង កាលនឹងរឿងតែស្រីៗនឹងឯង។

បូលី : តា យ៉ាន់ គាត់គ្រប់គ្រងខាងនារី គាត់សមាជិកកងពល?

សឿន : បាទ! ហើយនិរសាជនិតរបស់ តា ម៉ុក ទៀត តា យ៉ាន់ នឹង។ ដឹងស្លាប់ ដឹងរស់ទេសព្វថ្ងៃនឹង យើងអតដឹង។

ដារ៉ា : តែនៅក្នុងនឹង ម៉េចមាន តា ម៉ុក នឹងនៅគ្រប់គ្រងកងពលវិញ?

សឿន : អត់ទេ ចុះដល់ តា យ៉ាន់ នឹងគាត់មកនោមុន ដោយសារគាត់ចេញមកតស៊ូយើងនៅខាងព្រៃនេះ ចេញពីនោះមកគេរៀបចំខ្សែបណ្តាយគេ។ ហើយដល់ពេលចាប់ចឹងទៅ មិន តា ម៉ុក គ្រប់គ្រងម៉ាជិនទាន់៧៧-៧៨។ ចាប់អស់ចឹងទៅ តា ម៉ុក គ្រប់គ្រងវិញម្តង។

ដារ៉ា : ចឹង យ៉ាន់ ជានិរសា តា ម៉ុក ជនិត ហើយជនិតបននឹងទៅចាប់ទៀត ខុសធ្ងន់ ឬម៉េច?

សឿន : ធ្ងន់រឿងស្រីៗ។

ដារ៉ា : ចឹងពូ ពេលពូទៅវៃនៅគីរីវង់នេះ នៅក្នុងកងឈ្មោះ ធី ឈ្មោះ រ៉ាន់ វរៈសេនាតូចនឹង?

សឿន : បាទ!

ដារ៉ា : ចុះពេលមកខាងមេម៉ត់?

សឿន : ខាងមេម៉ត់ នៅដដែល។

ដារ៉ា : ពេលដែលពូមានប្រសាសន៍ថាទ័ពវៀតណាម ព័ទ្ធជាប់អីនឹងគឺ?

សឿន : នៅជាមួយគ្នា ។

ដារ៉ា : ចុះដល់ថ្ងៃណា ខែណា ឆ្នាំណា បានពូរត់មកស្រុកពូ?

សឿន : យើងទាល់ដល់ថ្ងៃវៀតណាមចូលដល់ភ្នំពេញនឹងម៉ង ហើយខ្ញុំនៅបូព៌ា នៅទាក់លឿងរត់មកដល់អ្នកលឿង ។

ដារ៉ា : ពូថា ពេលមានរបួស ពូថាមកដេកពេទ្យ?

សឿន : មកគ្រូនដេកពេទ្យនឹង ទាល់យួនជិតចូលដល់ភ្នំពេញនឹង បានខ្ញុំចេញមកបណ្ដោយ ។ គ្រាន់ចូលជិតដល់ ខ្ញុំមិនចេញទៅហើយ បណ្ដើរៗហើយ ហើយខ្ញុំកាត់ទៅលើខាង ចុះភូមិសាស្ត្រនឹង ខ្ញុំកាត់ទៅខាងតាំងក្រសាំងនឹង វង់តាមនឹងមកធ្លាក់មកលើយើងផ្លូវសវិញ ជិតដីថ្មីកំពង់លួងនឹង ធ្លាក់មកលើទំនប់កំពង់លែង កាត់មកលើ តាំងគោក បារាយណ៍នឹង ធ្លាក់មកស្រុកភូមិខ្ញុំហើយ មកចំការលើ ចំការអណ្ដូងនឹងហើយ ។

ដារ៉ា : ចុះពេលពូមកដល់ចំការលើ មកដល់ភូមិដូនចិននឹងម៉ង?

សឿន : បាទ! មកដល់នឹង ។

ដារ៉ា : មកដល់ក្នុងថ្ងៃណា ខែណា?

សឿន : អត់ចាំៗ ។

ដារ៉ា : ពេលមកដល់ភូមិពូនឹង វៀតណាមចូលដល់ភូមិនៅ?

សឿន : ចូលដល់អស់ហើយ មកដល់នឹងក៏គេចាត់តាំងឲ្យធ្វើមេភូមិបណ្ដោយ មកដល់ផ្ទះមិនទាន់បានឡើងផ្ទះផង គ្រាន់ប្រជាជនគ្រលែកឃើញថាមកហើយអានោះ គេកំពុងប្រជុំជ្រើសរើសមេភូមិ ។ តាំងក៏ចាស់ៗគ្រលែកឃើញខ្ញុំនឹងក៏នោះមកហើយ ហៅវាមកក៏ឲ្យខ្ញុំធ្វើមេភូមិម៉ង ។

ដារ៉ា : ចឹងអ្នកស្រុកអ្នកភូមិអត់ដឹងថាពូចេញធ្វើទាហានអីទេ?

សឿន : ដឹងៗទាំងអស់ ព្រោះអីខ្ញុំព្យាបាលគាត់នៅនឹងដែរ នៅស្រុកភូមិនឹងហើយ ខ្ញុំធ្វើពេទ្យធ្វើអីគាត់ដឹងទាំងអស់ ។

ដារ៉ា : ចុះដឹងថាពូចេញតស៊ូយូរហើយចឹង ជាខ្មែរក្រហមយូរហើយចឹង ម៉េចក៏គាត់ឲ្យធ្វើមេភូមិទៀត?

សឿន : គេដឹងថាយើងមនុស្សស្លូត មិនដែលធ្វើអីប៉ះពាល់អ្នកណាផង ។

ដារ៉ា : គេពេលនឹងមិនមានវៀតណាមអីនៅនឹងដែរ?

សឿន : មានតើ ។

ដារ៉ា : វៀតណាមនៅគ្រប់គ្រងតាមប្រជាជននឹងឲ្យពូធ្វើប្រធានភូមិទៀត?

សឿន ៖ បាទ! យល់ព្រម ដោយសារតែយើងមិនដែលមានប៉ះពាល់អីដល់គេដល់ឯង គេដឹងថាយើងស្លូត ។ រួចខ្ញុំទៅនៅជាកងចល័ត ក៏យើងមិនប៉ះពាល់អីដល់គេទៀត មានតែជួយជីវិតគេ ។

ដារ៉ា ៖ ចឹងនៅពេលជ្រើសរើសធ្វើជាភូមិហើយម៉េចទៀតទៅ?

សឿន ៖ ជ្រើសរើសធ្វើជាភូមិ នៅធ្វើភូមិបានប៉ុន្មានខែ គេឲ្យខ្ញុំទៅនៅឃុំ ។

ដារ៉ា ៖ ឃុំអី?

សឿន ៖ នៅក្នុងឃុំនឹងខ្ញុំនៅកាន់ខាងលេខាឃុំ យើងហៅលេខាជំនាន់នោះ ។

ដារ៉ា ៖ ពូប្រាប់ថាឃុំអីគេ?

សឿន ៖ ឃុំបុសខ្នុរ ។ ដល់កាន់ខាងឃុំទៅ ឪពុកមាខ្ញុំនឹង គាត់មេឃុំនោះ គាត់ឲ្យខ្ញុំធ្វើពេទ្យៗវិញដដែល ។ នៅតែពេទ្យនឹងដដែលរហូតចឹងទៅ ។

ដារ៉ា ៖ ធ្វើពេទ្យឃុំ?

សឿន ៖ បាទ! ពេទ្យឃុំ ។

ដារ៉ា ៖ នៅក្នុងឃុំនឹងបានប៉ុន្មានឆ្នាំ?

សឿន ៖ បានមកពី៧៩មកដល់៨១ បានចេញមកវិញ ។

ដារ៉ា ៖ នៅពេលកំឡុងពេលរស់នៅនឹងពី៧៩ដល់៨១នឹង មានរឿងរ៉ាវយ៉ាងម៉េច ឬមានមូលហេតុយ៉ាងម៉េច ដែលពូចេញទៅវិញ?

សឿន ៖ រឿងរ៉ាវយើង គេថាយេ់ងយកបាយឲ្យខ្មែរក្រហមស៊ី ។

ដារ៉ា ៖ អ្នកណាចោទ?

សឿន ៖ អ្នកស្រុកអ្នកភូមិយើងនឹង ។

ដារ៉ា ៖ ចុះមុនដំបូងរើសលោកពូចូលធ្វើ?

សឿន ៖ អានឹងឯង ដែលគេមានថាអ្នកច្រណែននិន្ទាឈ្នានីសន្ធា បុករុកទៅ ។ យើងទើបមកចឹងបានធ្វើការងារអី គេនៅយូរគេមិនបានធ្វើការងារអីគេច្រណែនចឹងណា ។ ហើយអ្នកភាគច្រើនគគេយល់យើង ។ ដល់ចឹងទៅយើងទប់វាមិនបាន សូម្បីតែឪពុកមាខ្ញុំមេឃុំនឹង ក៏ទប់វាមិនឈ្នះដែរ មិនដឹងថាម៉េចបើគេចោទប្រកាន់ចឹងហើយ ។ រកភស្តុតាងរកអីចឹងទៅ គេមិនទាន់រកភស្តុតាងរកអីទេ គេយកទៅបាត់ហើយ ។ យើងវាក្រដងអីដង មិនដឹងជាគេធ្វើយ៉ាងម៉េចដើម្បីស្អី ចង់បានស្អី ប៉ុនអាក្រុមគ្រួសារអ្នកប្តឹងនឹងគេចូលធ្វើពេទ្យវិញតើ ។

ដារ៉ា ៖ ហើយពេលនឹងគេចាប់ពូដែរ?

សឿន ៖ ចាប់!

ដារ៉ា ៖ ចាប់ទៅឃុំ?

សឿន : យកទៅដាក់នៅកំពង់ចាមនោះ ឡើង១០ខែៗនឹងខ្ញុំរត់ទេណា ។

ដារ៉ា : ជាប់ជាគុក?

សឿន : បាទ! ជាប់គុក ។

ដារ៉ា : គុកកំពង់ចាម?

សឿន : បាទ! កំពង់ចាម ។

ដារ៉ា : អាគុកទីរួមខេត្តគេរាលថ្ងៃនឹង?

សឿន : ហ្នឹងហើយ ។

ដារ៉ា : មានការកាត់ទោសមានអីដែរ?

សឿន : អត់មានការកាត់ទោសអីទេ ។

ដារ៉ា : ចាប់ពីឃុំនឹងទៅ បញ្ជូនទៅដល់កំពង់ចាម?

សឿន : បាទ! បញ្ជូនទៅដល់កំពង់ចាម ប៉ុនដល់ថ្ងៃរត់នឹងនៅសល់តែកន្លះខែទៀត គេលែងខ្ញុំៗរត់ចេញបណ្តោយ ។ ដល់រត់ចេញចឹងទៅ បានអ្នកជាប់គុកៗជាមួយគ្នា មកជួប ។

ដារ៉ា : ជួបនៅណា?

សឿន : ជួបនៅព្រៃនឹង គេទៅធ្វើចំការធ្វើស្រែនឹង កុំអីចេញជាមួយគ្នានឹងឯង ។ ហ្នឹងហើយឈ្មោះមានហើយតើ ត្រូវចេញជាមួយគ្នានឹងឯង ។

ដារ៉ា : ដល់ពេលគេត្រូវដោះលែងនឹង?

សឿន : បាទ! ត្រូវដោះលែង ដល់ចឹងទៅរត់ចេញទៅវាខក ដល់ហើយរត់ចូលព្រៃ យើងរត់ចូលទៅស្រុកវិញ ចាប់លើសដើមទៀតហើយ ចឹងខ្ជិលចូលបណ្តោយទៅ នៅទៅ ។

ដារ៉ា : រត់ចេញចូលដល់ព្រៃណាអីព្រៃណា បានមកជាខ្មែរសន្ធាក់ឡើងវិញ?

សឿន : នៅខាងកើតៗភូមិនឹង នៅចំការនៅនឹងទៅក៏ជួបខ្មែរក្រហមអី ក៏មកជាមួយនឹងគេមក ។

ដារ៉ា : ជួបអ្នកណាមុនដំបូងគេ ខ្មែរក្រហមនៅណា?

សឿន : ជួបណាំឈ្មោះ វីន, តេង, តា ខឿន, ច្រើនណាស់ ។

ដារ៉ា : ហើយសុទ្ធតែនៅក្នុងកងជាមួយពូពីមុនមក ឬយ៉ាងម៉េច?

សឿន : អត់ ថ្មីៗ អ្នកថ្មី ។

ដារ៉ា : ម៉េចបានពូអាចដឹង ថាគាត់ជាខ្មែរក្រហមអី?

សឿន : ចុះបើគាត់ចេះ មកចំការមកអីញ៉ឹកញាប់យើងចឹង ហើយយើងចេះតែខ្លាចរអែងចឹងដែរ គេមកចំការយើង ចឹងទៅគេចោទប្រកាន់យើងក៏វាមិនខុសដែរ គេចូលចំការយើងញ៉ឹកញាប់គេចោទប្រកាន់យើងវាត្រូវ ។

ដារ៉ា : ហើយដល់ពេលជួបអ្នកនឹងទៅ ក៏បបួលពូមក?

សឿន : មក ។

ដារ៉ា : មកចាក់មកខាងណាខាងណែ?

សឿន : មកឡើងមកយើងលើភ្នំនឹងម៉ង នៅយើងខាងកើតទន្លេល្ពៅ នៅខាង(ស្តាប់មិនបាន)ដាំក្បាន្ត

ដារ៉ា : ទៅដល់ទន្លេល្ពៅ?

សឿន : បាទ!

បូលី : ខាង១០០១?

សឿន : បាទ! ១០០១ ។

ដារ៉ា : ពេលដល់ទន្លេល្ពៅនឹង រៀបចំជាកងអីឡើងវិញ ឬយ៉ាងម៉េច?

សឿន : អូ! គេរៀបចំមុនយូរណាស់ហើយ មុនតាំងពីនៅខ្មែរក្រហម គេចូលព្រៃម៉ាជិនាន់នឹងមក គេមានកងពល គេមានមុនរបស់គេ ។

ដារ៉ា : ដល់ឆ្នាំណាពិតប្រាកដ ដែលពូទៅដល់១០០១?

សឿន : ៨១ ។

ដារ៉ា : ក្នុងកំឡុងឆ្នាំ៨១នឹងដែរ?

សឿន : បាទ! ៨១ ។

បូលី : គេរៀបហើយអស់?

សឿន : គេរៀបហើយអស់ ។

ដារ៉ា : កាលនឹងមានជាកងពលអីខ្លះហើយ?

សឿន : កងពលតូច កងពលធំអីគេមានអស់ ។

ដារ៉ា : កាលនឹងអ្នកណានៅគ្រប់គ្រងម៉ា១០០១?

សឿន : ១០០១នឹង យើងមិនដឹងជាអ្នកណា ប៉ុន្តែយើងមកដល់នេះជួប តា ពក នឹងឯង ។

០០:៥៩:៥០

ដារ៉ា : មិញពូមានប្រសាសន៍ថា រត់ទៅដល់ភ្នំ១០០១ ទន្លេល្ពៅ អានឹងយើងទៅតាមរយៈខ្សែយ៉ាងម៉េច?

សឿន : យើងមកជាមួយកងទ័ពគេនឹងមក ដែលយើងចូលនៅក្នុងកងពលណា យើងមកតាមជាមួយកងពលនោះ យើងមកតាមគេ ។

ដារ៉ា : ចឹងពេលពូទៅដល់១០០១នឹង នៅនឹងមានការរៀបចំជាកងពលឡើងវិញអស់ហើយ?

សឿន : បាទ! មាន ។

ដារ៉ា : មាន ប្រហែលជាប៉ុន្មានកងពល?

សឿន : ទេ! កាលនោះច្រើនណាស់ មិនដឹងជាកងពលណាខ្លះទេ យើងមិនដឹង៤១៧នឹង ហើយខាងគេទន្ទេញ្ចៅនឹងគេមានកងពលប៉ុន្មានទៀត យើងអត់ដឹងទេ ខាង០៥ ០៦នឹង ខាងកងពលគាត់នឹង យើងអត់ដឹងមានប៉ុន្មានទៀតទេ ។ ហើយ៩២០ ក៏យើងដឹងថាមានដែរ ហើយ៤១៧យើងនឹងក៏មាននៅនឹង ។

ដារ៉ា : ចឹងពេលពូទៅដល់១០០១នឹង ចូលក្នុងកងណា?

សឿន : នៅ៤១៧ ។

ដារ៉ា : កាលនឹងពូថា ក្នុងឆ្នាំ៧១ពូទៅដល់នឹង?

សឿន : បាទៗ ។

ដារ៉ា : ចឹងចូលកងពល៤១៧?

សឿន : បាទ!

ដារ៉ា : ចឹងពេលនឹងកងពល៤១៧ អ្នកណាជាលេខាកងពល?

សឿន : កែ ពក ។

ដារ៉ា : ចុះអនុលេខា?

សឿន : កាលនឹង អ៊ំ ប៉ូច ។

ដារ៉ា : ឈ្មោះអី ប៉ូច?

សឿន : ទេព ប៉ូច ។

ដារ៉ា : សមាជិក?

សឿន : សមាជិកស្លាប់បាត់ហើយ ។

ដារ៉ា : គាត់ឈ្មោះអី?

សឿន : ឈ្មោះ អឿន ប្អូនថ្លៃអ៊ំ ពក នឹង ។

ដារ៉ា : ស្អី អឿន?

សឿន : ស្អី អឿន ទេ មិនបានស្គាល់ត្រកូលគាត់ កូនចៅគាត់នៅនឹងគគោក ។

ដារ៉ា : ពេលនឹងពូនៅជាកងវរសេនាតូច វរសេនាធំ ម៉េចតទៅទៀត ក្នុងកងពល៤១៧?

សឿន : នៅជាប្រជាជន មានជាប្រជាជនដែរ ។

ដារ៉ា : តែគ្រាន់ពូដឹងថា?

សឿន : នៅក្នុងកងពល ។

ដារ៉ា : តែប្រជាជនក្រោមការគ្រប់គ្រងរបស់កងពល៤១៧?

សឿន : បាទៗ ។

ដារ៉ា : ជាប្រជាជននឹងធ្វើអីវិញ?

សឿន : គេឲ្យយើងបិទចំរូង ធ្វើចំរូងធ្វើអី ហើយដឹកជញ្ជូនគ្រាប់រំសេវអីនៅខាងមុខ ។

ដារ៉ា : ដោយសារពូយ៉ាងម៉េច បានគេឲ្យពូនៅធ្វើប្រជាជន អត់ទៅទ័ពអី?

សឿន : យើងដូចថាវាចាស់ដែរហើយ ចុះខ្ទង់៣០ជាង សុខភាពយើងអត់ល្អ យើងសុំគេនៅគេឲ្យនៅ ។

ដារ៉ា : តែពូមានគ្រួសារនៅពេលនឹង?

សឿន : ខ្ញុំមានគ្រួសារតាំងពីនៅផ្ទះ ។

ដារ៉ា : គ្រួសារសព្វថ្ងៃនេះ បានតាំងពូនៅភូមិពូដែលពូចូលក្រោយ៧៩?

សឿន : បាទ!

ដារ៉ា : នៅឆ្នាំណាពូមានគ្រួសារ?

សឿន : ៧៩ ៨០ ។

ដារ៉ា : ឆ្នាំ៨០ ?

សឿន : បាទ!

ដារ៉ា : ចឹងពេលពូរត់នេះ រត់ទាំងក្រុមគ្រួសារពូម៉ង?

សឿន : បាទ!

ដារ៉ា : មិនមែនរត់តែម្នាក់ឯង?

សឿន : មិនមែនតែម្នាក់ឯង ។ មកដល់ព្រៃហើយ យើងចូលនៅព្រៃ គេរកចាប់ប្រពន្ធយើងទៀត គេខ្វាចប្រពន្ធយើងយកបាយយកទឹកមកឲ្យយើងហូប ។ គេរកចាប់ យើងក៏មកទាំងអស់គ្នា

ដារ៉ា : ចឹងពេលនឹង មានកូនមានចៅដែលទេ?

សឿន : កូនមួយ ។

ដារ៉ា : ចឹងពេលមកដល់ទន្លេល្ពៅ ដល់១០០១នេះ អាចថាដោយសារពូមានគ្រួសារបានគេអត់ឲ្យទៅទ័ព?

សឿន : មិនមែនទេ វាចោទលើសុខភាពយើង ។

ដារ៉ា : ហើយពេលនឹង កងពល៩២០ អ្នកណាជាកងពល?

សឿន : អត់ស្គាល់ខ្ញុំ ដល់នឹងមិនសូវចាប់អារម្មណ៍ទេ ក្រោយៗមកបានឮសូរថា សាន នឹង តា០៦

ដារ៉ា : ចុះ០៥?

សឿន : ០៥នឹង វឿន ។

ដារ៉ា : ឈ្មោះ សារឿន?

សឿន : សារឿន ។

ដារ៉ា : មកដល់ឆ្នាំ៨១ ពូមកដល់១០០១?

សឿន : បាទ!

ដារ៉ា : ហើយមកនៅជាមួយកងពល កែ ពក ៤១៧?

សឿន : បាទ!

ដារ៉ា : ពូអាចស្គាល់បានទេ ថាតើកងពល៤១៧នឹង បែងចែកជាវរសេនាធំប៉ុន្មាន ហើយវរសេនាធំអីខ្លះ?

សឿន : វរសេនាធំណាទេនេះ ខ្ញុំអត់សូវដឹងទេ ដូចជាមិនចាប់អារម្មណ៍រឿងចង់ដឹង ចង់អីទៀត មកនៅនឹង នៅស្ងៀមស្ងាត់ចឹងទៅ អត់មានគិតអីសោះ ។ អត់មានរវីរវល់អី បើគេប្រើក៏ប្រើទៅ ហើយអត់ដឹងថាសមាកងពល បើដឹង១ទៅ ជួនកាលអត់ដឹងទេ ។ ដឹងថាកងពលនេះកងពលនោះនៅត្រង់ណា១ដោយសារបានដើរទៅលេងនឹងគេ បានដឹង ។ បើថាឲ្យចាំច្រើនម៉ងដែលគេមិនចាំទេ ។

ដារ៉ា : ចុះជាប្រជាជនធម្មតាចឹង ពូគេឲ្យបិទជាចំរូង បិទអីយ៉ាងម៉េច?

សឿន : បិទចំរូងយកចាក់ ជញ្ជូនយកទៅចាក់តាមការពារយើងក្រោម១ ចុះមកអូរជុញ មកអី ។

ដារ៉ា : ក្នុងនឹងការរស់នៅយ៉ាងម៉េចដែរ ពេលនៅជាប្រជាជនក្រោមការគ្រប់គ្រងរបស់កងពល?

សឿន : ការរស់នៅដូចជារឿងជីវភាពអីដូចជាមិនអីទេ ព្រោះអីស្បៀងអាហារអី យើងបានកំណត់ពេលត្រឹមត្រូវ យើងដាំដំណាំ ស្រូវអង្ករអី យើងក៏អាចផ្គុំបានដូចគ្នា បន្លែបង្ការអីយើងដាំបានហូបចុកទៅ ឯងម្ហូបគេមានតែត្រីខទេ កាលនឹងបើកឲ្យ ។ ប៉ុន្តែអូរនឹងយើងអាចរកបានត្រីអី ។ បើស្ករ អំបិល ប្រហុល ប៊ីចេង ទឹកត្រី មានសព្វបើកឲ្យយើង ។ អង្ករក្នុងម្នាក់នឹង២០កំប៉ុងនឹង១០ថ្ងៃ ហូបមិនអស់ទេ១រាល់ថ្ងៃ ។ សល់ទាំងបាវ១ចិញ្ចឹមជ្រូកចិញ្ចឹមអីទៀតទៅ ។ នឹងលក្ខណៈនឹង គឺយើងរស់នៅវាស្រួលដែល មិនមានលំបាកអី ឬអារម្មណ៍អីយើងអត់មានស្មុគស្មាញអីទៀតទេ ។

ដារ៉ា : នៅប៉ុន្មានឆ្នាំ?

សឿន : នៅនឹង យើងនៅបានតែពី៨១រហូតដល់៨៣ ៨៤ រស់ យួនវៃដល់ទៀតហើយ ។

ដារ៉ា : ចឹងនៅក្នុងចន្លោះ៨១ដល់៨៤ ដែលពូថារស់នៅក្រោមការគ្រប់គ្រងរបស់កងពល៤១៧ ពេលនឹងជាអារម្មណ៍ ជាលក្ខណៈនៃការរស់នៅវាយ៉ាងម៉េចដែរ បើប្រៀបធៀបទៅនឹងសម័យ៧៥-៧៩?

សឿន ៖ ខុសគ្នាឆ្ងាយ អារម្មណ៍យើងនៅនេះ មកនៅនេះអត់មានបញ្ហាអី អត់មានទឹកឃើញថាខ្លួនឯងផាប់អីអត់ទេ អត់មានភ័យព្រួយថា ក្បត់ជាតិអីណាណៃដូចគេថាដូចមុន អត់មានទេ ហើយមិនមានថា ខ្នាំងបង្កប់ គិញបង្កប់យើងក៏អត់មានដែរ អត់មានថាទៀតទេ ។ ចឹងយើងរស់នៅធម្មតាដូចជាយើងអត់មានកើតសង្គ្រាមអី យើងរស់នៅជាប្រជាពលរដ្ឋធម្មតា កងទ័ពក៏អារម្មណ៍គាត់ធម្មតាដែរ ដូចគ្នាសប្បាយទាំងអស់ ។ ហើយគ្រាន់ថាយើងមួយអារម្មណ៍ថាយើងចុះទៅសមរភូមិ ទៅប្រយុទ្ធជាមួយយួនអីចឹងទៅ ដឹកជញ្ជូនដើរឆ្លងកាត់ អានឹងយើងមានអារម្មណ៍ភ័យខ្លាចក្រែងលរជួបប្រទះគ្នាតែប៉ុននឹងទេ ។ ដល់មានអារម្មណ៍អីនេះផ្សេងទៀត អត់ទេ ខុសគ្នា ។

ដារ៉ា ៖ ចុះពេលនឹងជាបទបញ្ហាអីផ្សេងៗ វាមានលក្ខណៈយ៉ាងម៉េចដែរ បើធៀបទៅនឹង៧៥-៧៩?

សឿន ៖ បទបញ្ហាក្នុងកងទ័ព គេផ្នែកគេទ័ពផ្សេងទៅ មានបទបញ្ហា បើបទបញ្ហាមកតាមប្រជាជនយើងរស់នៅនឹង គឺមានដែរ យើងមានកម្រិតអីទៅ ឧទាហរណ៍ចំរូង ក្នុងម៉ាគ្រួសារ ក្នុងម៉ាថ្ងៃយកប៉ុន្មាន៥០០ចំរូង យើងធ្វើគេទៅវាបានមែន ។ ប៉ុន៥០០ចំរូងបិទម៉ាភ្លែតនឹង ។ វាមិនជាពិបាកអីណាស់ប៉ុន្មានទេ តែយើងមិនទាន់ចេះបិទវាយូរ ដល់ពេលចេះទៅយើងបិទម៉ាភ្លែតទៅ៥០០ចំរូង ។

ដារ៉ា ៖ ធ្វើពីស្អី?

សឿន ៖ ឫស្សីៗយើងលើភ្នុនេះ ឫស្សីថ្នាំងវែងៗស្រណុកធ្វើសឹងអីនឹង កាំបិតយើងស្រលៀងវាឲ្យមុតទៅយើងចងវាឲ្យជាប់ទៅ យើងទាញខ្សែកៗលឿន ម្នាងតែ២កាំបិតទៅស្រួចបាត់ ។ វាមានចឹងទេ គ្រាន់បញ្ហាយើងឲ្យដាក់កំណត់ឲ្យយើង ខាងកងទ័ព រឿងទ័ពនោះផ្សេង បញ្ហារបស់គេ ។

ដារ៉ា ៖ ជាប្រជាជនរស់នៅចឹង គេឲ្យធ្វើអីខ្លះ?

សឿន ៖ គ្មានធ្វើអីទេ គ្រាន់តែដឹកជញ្ជូនៗជិតៗនឹង ឬក៏ពួកៗខ្លះមានសមត្ថភាពទៅឆ្ងាយចឹងទៅ ហើយធ្វើចំរូង តែប៉ុននឹង អត់មានធ្វើអី ។ ហើយធ្វើទៅដាំបន្លែដាំអីហូបខ្លួនឯងទៅ អត់មានអីទេ ។

ដារ៉ា ៖ ចុះជាការអនុវត្ត ជាប្រពៃណី ទំនៀមទម្លាប់អី ឬក៏គោរពសាសនា ប្រតិបត្តិសាសនាអីចឹងគេចាប់ផ្តើមមានវិញ ឬកយ៉ាងម៉េច នៅក្នុងពេល៨១-៨៤?

សឿន ៖ យើងមានហើយ ជំនឿ ។ មានជំនឿ មានអីមកវិញ យើងប្រពៃណីរបស់យើងមានឡើងមកវិញ សាសនាអីណា យើងមិនទាន់មានលោកទេ វាអត់មានកន្លែងសម្រាប់លោកណាមក

បង្កើតជាវត្តអត់មានទេ មានតែតាចាស់ៗធ្វើជាលោកអីចឹងទៅ ពេលមានអ្នកស្លាប់អ្នកអីនឹង បានចាស់ៗនឹងឯងៗ

ដារ៉ា : ចុះបើកាលពី៧៥-៧៩?

សឿន : ៧៥-៧៩នោះ វាអត់ៗរលីង ៧៥-៧៩អត់មានលោកផង ហើយយើងអត់មានអីគោរពផង បំបាត់អស់ហើយសាសនាៗ

ដារ៉ា : ក្នុងឆ្នាំ៧៥-៧៩ ពូមានបានធ្វើទំនាក់ទំនងអីទៅផ្ទះទៅសម្បែងអីទេ?

សឿន : សុំគេអត់បានទេៗ ទំនាក់ទំនង ក៏ពិបាកដែរ មិនដឹងទាក់ទងតាមណាដែលទៅទេ វាអត់មានអីទំនាក់ទំនងបាន ហើយសុំទៅលេងផ្ទះនឹងក៏ពិបាកដែរ អត់មានបានទៅទេៗ

ដារ៉ា : ពី៧៥-៧៩ ចន្លោះនឹងដែលបានទៅលេងផ្ទះម្តង ឬ២ដងទេ?

សឿន : ទៅចេះទេ បើបានទៅលេងផ្ទះ ព្រោះអីខ្ញុំនៅក្នុងពេទ្យកងពលនឹង ឈ្មោះ ណៃៗមួយទៀតនឹងនៅក្នុងកងពលនឹង គាត់ទៅលេងផ្ទះគាត់នៅស្តីនឹង ឪពុកម្តាយគាត់ៗ ចឹងគាត់យកខ្ញុំទៅនៅជាមួយនឹងទៅ បានទៅលេងទៅៗ បើថាឲ្យសុំខ្លួនឯងទៅម៉ង អត់មានៗឲ្យទៅៗ

ដារ៉ា : ចឹងពេលមកដល់ឆ្នាំ៨៤ ពូថាទ័ពវៀតណាម និងទ័ពរដ្ឋកម្ពុជា?

សឿន : វៃឡើងៗ

ដារ៉ា : វៃឡើងទៅដល់លើភ្នំនឹងម៉ង?

សឿន : បាទ! វៃឡើងទៅដល់លើភ្នំ ចូលទៅដីថៃៗចឹងទៅ វៃឡើង១០០៣នេះទៀត ក៏វៃទៀតទៅជុំគ្នាទៅនៅៗ ហើយពួកនឹងមុនដំបូងទៅនៅខាងស្រុកអីគេ គេហៅពេទ្យអឹៗគេបញ្ជូនមកនៅខាង តា ម៉ុក នេះទាំងអស់១០០៣ៗ

ដារ៉ា : ទាំងពូអីមកនៅនេះ?

សឿន : បាទ! គេហៅស៊ីងច័ន្ទ នៅក្នុងស្រុកថៃ

ដារ៉ា : នៅក្នុងដីថៃ?

សឿន : បាទ! នៅដីថៃ តាំងពី៨៤នឹងមករហូតៗ

បូលី : ចឹងពេលនៅ១០០១ លែងមានមនុស្សរស់នៅ?

សឿន : បាទ! លែងមានហើយ មានតែកងទ័ពៗនឹងនៅតាមចន្លោះព្រំដែននៅលើភ្នំនឹង ហើយឡើងចុះៗ អ្នកនៅក្នុងក៏នៅក្នុងនឹងទៅៗ

ដារ៉ា : តែចំណែកប្រជាជនប្រមូលនៅស៊ីងច័ន្ទនេះ?

សឿន : បាទ! ស៊ីងច័ន្ទៗ

ដារ៉ា : អានឹងជាជំរំ ជាអី?

សឿន ៖ មួយជំរំខាង តា ម៉ុក ជំរំកងទ័ព មួយទៀតជំរំខាងយូអ៊ិន វាមានពីរផ្នែក ។
ដាវ៉ា ៖ ជំរំខាងយូអ៊ិនគេហៅជំរំអី?
សឿន ៖ ហៅជំរំអូរត្រាវ ។
ដាវ៉ា ៖ អូរត្រាវចឹង?
សឿន ៖ បាទ! អូរត្រាវ ។
ដាវ៉ា ៖ សុទ្ធតែនៅក្នុងទឹកដីថៃ ឬទឹកដីខ្មែរយើងទាំងពីនឹង?
សឿន ៖ ទឹកដីថៃ ។
ដាវ៉ា ៖ ហើយជំរំរបស់ តា ម៉ុក និងជំរំយូអ៊ិន ខុសគ្នាយ៉ាងម៉េចទៅ?
សឿន ៖ ខុសគ្នា មួយគេនៅមានប្រជាជនសុទ្ធសាធមក គេអត់មានធ្វើអីទេ ។
ដាវ៉ា ៖ ជំរំរបស់យូអ៊ិននឹង?
សឿន ៖ បាទ! យូអ៊ិនចិញ្ចឹមទាំងអស់ ហើយអត់មានទៅណាទេ នៅតែនឹង មិនចុះទៅនៅសមរភូមិ មិនចុះទៅអីទេ ។
ដាវ៉ា ៖ អត់មានបិទចំរូង អត់មានអីទេ?
សឿន ៖ អត់មានទេ ។ មានតែជំរកងទ័ពទេ ដែលយើងបិទចំរូង ។
ដាវ៉ា ៖ ហើយប្រជាជននៅក្នុងជំរំរបស់យូអ៊ិននៅអូរត្រាវនឹង ច្រើនប្រជាជនមកពីខាងណា?
សឿន ៖ ចេញពីកងទ័ពទៅ គេដូចថាវាស្អុកស្អាញ គេលែងចង់ឲ្យប្តីគេចុះទៅមុខ ឬក៏មានអ្នកខ្លាចរអាលក្នុងសង្គ្រាមអីគេរត់ទៅហើយ ។ យើងមិនមែនទៅនៅនឹង ធម្មតាបានងាយៗទេ សុទ្ធតែរត់ទៅទេ ។
ដាវ៉ា ៖ សុទ្ធលួចរត់ទៅ?
សឿន ៖ បាទ! លួចរត់ទៅ ។ ប៉ុន្តែក្នុងនឹងវាមានការកកើតនឹងវាខាង១០០៣នឹងច្រើនជាងគេម៉ង ដែលចូលទៅជំរំយូអ៊ិននឹង ដូចខាង១០០១យើងនឹងទៅវាភាគតិចៗទេ ។
ដាវ៉ា ៖ ជំរំអូរត្រាវរបស់យូអ៊ិន ហើយនឹងជំរំស៊ីងច័ន្ទរបស់ តាម៉ុក នេះ ជំរំមួយណាកើតមុនគេ?
សឿន ៖ កេតម៉ាស្រកគ្នា ពេលជាមួយគ្នានឹងឯង ។
ដាវ៉ា ៖ ចុះកាលនឹងម៉េចបាន តា ម៉ុក អនុញ្ញាតិឲ្យមានជំរំរបស់យូអ៊ិនចឹង?
សឿន ៖ អត់ដឹងដែរ ខ្ញុំមិនយល់ដែរ ។
ដាវ៉ា ៖ ហើយដល់ពេលអនុញ្ញាតិឲ្យមានជំរំគ្រប់គ្រងដោយយូអ៊ិនចឹង ហេតុអីបានជាខាងប្រជាជននៅស៊ីងច័ន្ទ តា ម៉ុក នេះអត់ឲ្យចូលឆ្លងគ្នាចឹង?

សឿន ៖ អត់មានឆ្លងចូលទៅមកៗបាន ប៉ុន្តែយើងទៅនៅគេតាមដែរ តាមចាប់យើងមកវិញដែរ ប៉ុនតែចូលដល់ជំរំទៅ លែងហ៊ានទៅហើយ គេខ្លាចអន្តការសហប្រជាជាតិដែរ គេគោរពដែរ អត់ហ៊ានចូលទៅទៀតទេ ។ ប៉ុន្តែយូរៗទៅគេលែងធ្វើអីយើងហើយ បានតែប៉ុននោះហើយ គេលែងធ្វើយើង ។

ដារ៉ា ៖ នៅចេញចូលអត់បានទេ ជំរំទាំងពីរនឹង?

សឿន ៖ បាទ! ចេញចូលទៅមករៀងៗខ្លួនបាន លក់ដូរមានរបស់លក់ដូរចេញចូលទៅវិញទៅមកបាន ។

ដារ៉ា ៖ បើទារសេរីហើយ ឬម៉េច ឬក៏លួចលាក់ពេលនឹង?

សឿន ៖ បើកជាសេរីម៉ង ប៉ុនខាងយើងជំរំកងទ័ពនេះ វាអត់មានអីលក់ដូរដូចគេនៅខាងជំរំយូអ៊ិនៗ បានគេចេញចូលលក់ដូរអីបាន បើកទីកន្លែងផ្ទះគេលក់ដូរអីបាន បើយើងកងទ័ពអត់ទេ ។

ដារ៉ា ៖ ចឹងក្នុងជំរំស៊ីងច័ន្ទរបស់ តា ម៉ុក និង ជំរំរបស់យូអ៊ិន មានការប្រតិបត្តិសាសនា ជំនឿប្រពៃណីខុសគ្នាដែរ ឬយ៉ាងម៉េច?

សឿន ៖ អត់មានខុសគ្នា ដូចគ្នាជំនឿ បើនៅខាងជំរំយូអ៊ិនផង វិតគាត់មានចេញសកម្មភាពសាសនាខ្លាំងជាងនៅក្នុងកងទ័ពទៀត ។ កងទ័ពរៀងនៅស្រពិចស្រពិល រអាលៗវាមិនទាន់ពេញលេញ ប៉ុនមិនមានពីណាគេធ្វើអីទេ ប៉ុនរៀងផ្អើលៗ ។

ដារ៉ា ៖ នៅមានអារម្មណ៍?

សឿន ៖ ហ្នឹងមានអារម្មណ៍ខ្លាចក្រែងលរគេមានបញ្ហាអី ជាមួយខាងលើ ។ ប៉ុនបើថាជាមួយជំរំយូអ៊ិនពេញដីពេញដើងម៉ង រឿងសាសនា តែគេមានសាសនា គេចង់ទៅខាងសាសនាគ្រឹះក៏គេមានដែរ ។

ដារ៉ា ៖ ចុះពេលនឹងជាកងពលជាអីនៅក្នុងជំរំស៊ីងច័ន្ទមានទេ កងពលខាងខ្មែរក្រហម?

សឿន ៖ អ្នកដែលចូលទៅនៅ?

ដារ៉ា ៖ បាទ!

សឿន ៖ មានតើ ។

ដារ៉ា ៖ គេមានបង្កើតជាកងពល?

សឿន ៖ អូ! អត់ទេ រឿងកងពលគេអត់បង្កើតទេ បង្កើតជា ។

ដារ៉ា ៖ អានឹងជំរំប្រជាជននៅសុខ្ទសាធ?

សឿន ៖ បាទ!

ដារ៉ា ៖ ប៉ុន្តែគ្រាន់ប្រជាជននឹង ធ្វើការបម្រើមកកងទ័ព?

សឿន ៖ អត់ទេ អត់មានបម្រើកងទ័ពអីទេ នៅសុទសាធ អត់មានគិតអីតែម៉ង ដីផ្ទួនឯងមានប្រជាជនបណ្តោយ បើសិនជាយើងធ្វើចឹងដីផងដល់យួអ៊ិន គេលែងខបត្តម្មអត្តរឡូ ។

ដារ៉ា ៖ ទេ! សម្រាប់ជំរំស៊ីងច័ន្ទ?

សឿន ៖ អូ! ស៊ីងច័ន្ទអានឹងយើងក្នុងកងទ័ពម៉ង ប្រជាជននឹង យើងខបត្តម្មដល់កងទ័ពបណ្តោយបម្រើកងទ័ពទាំងអស់ប្រជាជននឹង ។

ដារ៉ា ៖ នៅពេលនឹងក្នុងជំរំនឹង មានគេបែងចែកជាភូមិ ជាឃុំ ឬក៏ជាអង្គភាពយ៉ាងម៉េចដែរ នៅស៊ីងច័ន្ទ?

សឿន ៖ យើងមិនមានបែងចែកច្រើនទេ យើងក្តាប់តែមួយទាំងមូលម៉ង ។

ដារ៉ា ៖ ហើយអ្នកណាអ្នកក្តាប់លើជាងគេ ធំជាងគេ?

សឿន ៖ អានឹងបើវាដូចកងទ័ពមានអំណាចគេកាន់កាប់ច្រើនដែរ ដួនកាលអ្នកនៅចាំមូលដ្ឋាននឹង គេមានមួយ ប៉ុនកងទ័ពមកមេច្រើន គេមានការបញ្ហាលិច បញ្ហាកើតមានអី ប៉ុន្តែយើងគ្រាន់ថាអនុវត្តន៍ទៅ ធ្វើទៅតាមគេទៅទោះបីធ្វើបានមិនបានម៉េចក៏យើងចេះតែធ្វើទៅវាមិនមានបញ្ហាអីទេ ។

ដារ៉ា ៖ ចុះនៅនឹងពីឆ្នាំ៨៤មកដល់ឆ្នាំណា?

សឿន ៖ នៅស៊ីងច័ន្ទ យើងនៅ៩០ជំនាន់ឆើតឆើយ ឈុនហាវ៉ាន់ ។

ដារ៉ា ៖ ជំនាន់កាលគ្រប់គ្រងនាយករដ្ឋមន្ត្រីឆើតឆើយ ឈុនណាវ៉ាន់ថៃ?

សឿន ៖ បាទ! ហ្នឹងហើយ បានដេញយើងចុះមក ។

ដារ៉ា ៖ ដេញចុះមកណាវិញ?

សឿន ៖ ដេញចុះយើងមកនៅស្រុកយើងវិញ អត់ឲ្យយើងមកនៅលើភ្នំនឹងទៀតទេ ។

ដារ៉ា ៖ ចុះចេញពីស៊ីងច័ន្ទនឹងមកៗនៅទឹកដីខ្មែរ មកនៅម្តុំណាវិញ?

សឿន ៖ មកនៅតាមអស់នឹង យើងដំបូងនៅបើភូមិនេះដំបូងនៅខាងនោះអូរជីកទៀតនេះ បាននាំគ្នារាយមកនេះ និយាយរួមទៅមកនៅនឹងតែម្តង មកនៅម្តុំនឹងរហូតចឹងទៅ ។

ដារ៉ា ៖ ចឹងអត់បានទៅដល់កន្លែងអន្លង់វែងទេ?

សឿន ៖ អនន់វែងនឹង ខាង តា ម៉ុក ខាង១០០៣គេចុះនៅត្រង់នឹង ខាងកងពលគេផ្សេង ដល់ខាងកងពលនេះផ្សេងចុះមកនៅត្រង់នេះ ។

ដារ៉ា ៖ ចុះពី៨១-៨៤នឹងមក នៅកន្លែងស្រុកអន្លង់វែងយើង មានជាប្រជាជនអីរស់នៅយ៉ាងម៉េចដែរ?

សឿន ៖ មិនមានទេ មានតែកងទ័ព ។

ដារ៉ា : កងទ័ពណា?

សឿន : បាទ!កងទ័ពរដ្ឋកម្ពុជា ៗ នៅជាំនឹងតើ នៅតាំងពីជាំនឹងរហូតមកដល់អន្លង់វែង តាមបណ្តោយនឹងរហូត ។ បន្ទាយស្នាកស្នាមនៅទាល់សព្វថ្ងៃនឹងឯង មកតាមនឹង ។

ដារ៉ា : ចុះដល់ពេលដែលទ័ពរដ្ឋកម្ពុជានៅចឹង មានជាសកម្មភាពអីវៃតទល់គ្នាយ៉ាងម៉េចដែរ?

សឿន : វៃដែរតើ វៃចេញពីកន្លែងនឹងអស់ចឹងទៅ បានយើងបានចុះមកនៅនឹង រដ្ឋកម្ពុជាដកចេញអសតាមបណ្តោយព្រំដែននឹង បានយើងមកនៅនឹង ។

ដារ៉ា : ដែលអាចចុះមកនៅនឹង ពូថាឆ្នាំ៩០?

សឿន : បាទ! ៩០ ។

ដារ៉ា : ចុះមក ដល់ពេលចុះមកដល់អន្លង់វែងអី លែងមានជាទ័ពជាអីហើយក្នុងនឹង?

សឿន : បាទ! នៅទ័ព ។

ដារ៉ា : ចង់និយាយថា លែងមានទ័ពរដ្ឋកម្ពុជានៅហើយពេលនឹង?

សឿន : បាទ! អត់មានទេ ។

ដារ៉ា : ចុះក្រោយមក ក្រោយពីឆ្នាំ៩០នឹង មានជាព្រឹត្តិការណ៍បោះឆ្នោតអីដែរ ចាប់ផ្តើមចរចាអី៩០មក ៩១ ៩២ ពេលនឹងសភាពការណ៍នៅក្រុមខ្មែរក្រហមយ៉ាងម៉េចទៅ?

សឿន : អានឹងយើងមិនទាន់មានសភាពអីមិនទាន់បោះឆ្នោតទេ ជំនាន់អ៊ុនតាក់៩៣ សភាពការណ៍ខាងលើទៅចរចាដល់ភ្នំពេញអីនឹង មានប៉ុននឹងទេ ហើយយើងទៅនៅនឹងទៅ ។ ដល់មកយើងរហូតមកដល់យើងបែកគ្នានេះ បែកគ្នានៅឆ្នាំប៉ុន្មាន៩៧ អឺ!៩៨យើងបែកគ្នា ទៅលើភ្នំខ្លះទៅ ទៅអូរបាយតាប់ខ្លះទៅ ។ បានដល់មក៩៨នឹង មានពេលបោះឆ្នោតមួយហើយបោះឆ្នោតនឹងនាយករដ្ឋមន្ត្រី ។

ដារ៉ា : បាទ! បោះឆ្នោតសកល?

សឿន : បាទ! បោះឆ្នោតអានឹង ។ ប៉ុនខ្ញុំអត់ទេ ខ្ញុំនៅលើនោះទេ ។

ដារ៉ា : នៅលើភ្នំ?

សឿន : បាទ! នៅលើភ្នំ រត់បែកគ្នា ខ្លះគេទៅនោះ ខ្លះគេទៅលើភ្នំ ។ ដល់បោះឆ្នោតរួចអីរួច បានមានការចរចាគ្នានឹង ផ្សះផ្សាគ្នាចូលមកទាំងខ្ញុំទាំងអីនឹងរហូត ខ្ញុំអត់ប្រាប់ អ៊ំប៉ូច នឹងខ្ញុំប្រាប់គាត់ប្រាប់ខ្ញុំថា អ៊ំស្រុកគាលក្បាលវាយូរឆ្នាំហើយ យើងល្មមនាំគ្នាឈប់ហៅយ ។ ហើយយើងរត់មកនេះដូចមិនទំនងសោះ អាអ្នកគៀងឲ្យរត់ឡើងលើភ្នំ នឹងក៏វាពិបាកទៀតនិយាយគ្នាមិនឲ្យត្រូវគ្នា ថាទៅណាទៅទាំងអស់គ្នាមក ថាទៅរដ្ឋាភិបាល ទៅនឹងម៉ង់ទៅមានតែខ្ទាចឯងខ្ទាចអញបែកជា២ ។ ចិត្តខ្ញុំចង់ទៅនោះ យើងនៅសង្គ្រាមយូរហើយ ល្មមបញ្ឈប់

ហើយ។ ចឹងនិយាយជាមួយ ប៉ូច នឹងបាន ប៉ូច ថាមែនគេប្រជុំ ចឹងទៅបានខាងលើគេឯកភាពគ្នាដែរ ឯកភាពយើងសម្រុះសម្រួល ដោយសារយើងមាន ការចរចានៅព្រះវិហារហើយនោះ។ ចឹងយើងនៅត្រឹម តា ម៉ុក នេះទេ ប៉ុន ខៀវ សំផន តាៗ អស់នឹងក៏គាត់វិភាគដែរ គាត់ថាយើងល្មមឈប់ធ្វើសង្គ្រាមទៅ ចរចាទៅ ប៉ុនគាត់ផ្ដាំ ផ្ញើថាយើងមានតែរស់នៅជាមួយរាជរដ្ឋាភិបាលទេ ដែលវាសុខផ្ដល់អាយុជីវិតឲ្យយើង បើយើងទៅនៅខុសពីកន្លែងនឹង យើងមិនអាចរស់រានមានជីវិតទេ ក៏គេស្អប់យើងយូរដែលហើយ។ ចឹងទៅយើងទៅនៅជាមួយរាជរដ្ឋាភិបាល ដែលធ្លាប់ថាជាផ្លូវជាមួយពីមុនមក។ ចឹងយើងគេមានការអនុគ្រោះដល់យើង។ ចឹងទៅយើងក៏នាំគ្នាមក ហើយខ្ញុំក៏ចឹងដែរ នឹកឃើញថាគ្មានទៅនៅណាកើតទេ មានតែនៅខាងរាជរដ្ឋាភិបាលនឹងហើយបានសុខ បាននាំគ្នា ចុះមក។

ដារ៉ា : ពេលឆ្នាំ៩៨ ពេលដែលមានការប្រទូសសារ៉ាយគ្នា ម៉ាពេលនឹងមិនមានអ្នកមកខាងបាយតាប់ មិនមានអ្នកទៅខាងលើភ្នំ?

សឿន : លើភ្នំ។

ដារ៉ា : ដូចលើភ្នំនេះ មាន តា ម៉ុក, សុន សេន, ខៀវ សំផន, នួន ជា, ប៉ុល ពត នៅលើភ្នំនឹង មែនទេចឹង?

សឿន : បាទ! ទៅលើនឹងទាំងអស់។

ដារ៉ា : ហើយពូមានប្រសាសន៍មិញថា មានការប្រជុំដែរថ្នាក់លើ?

សឿន : បាទ! ប្រជុំ។

ដារ៉ា : ប្រជុំៗត្រឹមថ្នាក់ណា ដែលចូលរួមប្រជុំ?

សឿន : យើងប្រជុំត្រឹមថ្នាក់កងពល វរសេនាតូចនឹង នៅប្រជុំនឹងយើង ប្រជុំប្រជាជនយើងទាំងអស់គ្នា។

ដារ៉ា : ប្រជុំជាមួយ កាលនឹងមាន ខៀវ សំផន, មាន ប៉ុល ពត ចូលរួមដែរ?

សឿន : អត់ទេ ប៉ុល ពត គាត់ស្លាប់តាំងពីនៅជាំនេះ ស្លាប់មុនយើងចូលដល់ថៃ។ ប៉ុនតាៗអស់នឹងអត់បានចូលរួមប្រជុំជាមួយយើងទេ ប៉ុនគ្រាន់បានកងពលអី ថ្នាក់ដឹកនាំបន្តបន្ទាប់គ្នាទៅជួបប្រជុំជាមួយគាត់ដែរ។ ហ៉េយអ្នកដែលចរចានឹង ពីណាទេ កាលនឹង ទៅចរចាជាមួយឯកឧត្តម ទៀ បាញ់ កាលនឹង បានត្រូវគ្នានឹង។ ខ្ញុំកាលនឹងជាមួយ ប៉ូច នឹងខ្ញុំខស្សាហ៍និយាយជាមួយគាត់ដែរ ថាអ៊ឺអើយ! អ៊ឹងឯងគួរតែគិតមើលទៅ។ គិតយ៉ាងម៉េច? គិតយ៉ាងម៉េច គិតថាទៅផ្ទះ។ ម៉េចទៅ? យើងនៅនេះ ម៉េចបានបាយស៊ី មានកម្លាំងណាទៀត។ ចឹងហើយក៏នាំគ្នា ឯកភាពគ្នា ខាងលើក៏ឯកភាពសុខចិត្ត ឲ្យយើងមក។ នេះកាល

រត់ឡើងទៅនឹងក៏មិនមែនគេ តាៗនឹងគាត់អត់ចង់ឲ្យយើងទៅជាមួយដែរ ប៉ុន្ដែម៉ាចំនួន យើងមានការភ័យខ្លាច តាមអ្នកបង្ហើលយើងទេ បើចិត្តខ្ញុំចង់ៗទៅនោះទេៗ ហើយដល់ពេលមានអ្នកបង្ហើលចឹងទៅ ដូចថាវាមានប្រើហិង្សាខ្លះដែរ យើងក៏ទៅៗ ។

ដារ៉ា : ចុះកាលនឹងពូ ទេព ប៉ូច នឹងគាត់មានឋានៈជាស្អី ដែលពូអាចពិភាក្សាជាមួយគាត់?

សឿន : គាត់នឹង យើងថា កងពលក៏មិនមែនកងពល ដល់ថ្នាក់គាត់នឹងជាអ្នកដឹកនាំខាងក្រោយវិញ អ្នកដឹកនាំខាងក្រោយ មិនមានជាកងពលមិនមានជាអីទៀត ។

ដារ៉ា : ហើយចុះពូធ្វើអី បានអាចនិយាយ ពិភាក្សាជាមួយ ពូ ប៉ូច នឹងបាន?

សឿន : យើងមានការជិតស្និត ហើយគាត់នឹងក៏មានការជិតស្និតជាមួយយើង ខ្ញុំកាលនឹងជាគ្រូបង្រៀនកូនចៅគេអ្នកក្រោយ ដែលទៅនៅជំរំហើយទេ បានធ្វើជំរំ ។ ទៅនៅជំរំតាំងពី៨៤ នឹងមក បានធ្វើគ្រូបង្រៀនរហូត ដល់ចឹងមានការជិតស្និតជាមួយគាត់នឹងឯងតិច ។

ដារ៉ា : ចឹងបើតាមពូមានប្រសាសន៍នឹង ដូចថាមានខាងលើៗគេប្រជុំគ្នាដែរ?

សឿន : បាទ! ប្រជុំ ។

ដារ៉ា : បានមកចុះចូលនេះ?

សឿន : បាទ! ហ្នឹងហើយ ។

ដារ៉ា : ហើយចុះ តា ម៉ុក គាត់យល់ព្រមដែរ?

សឿន : គាត់យល់ព្រមនឹងហើយ ។ បើមិនយកព្រមម៉េច បើកងទ័ពគេមិនព្រមទៅតាមគាត់ទៀត គេសុខចិត្តមកចូលរស់នៅជាមួយរដ្ឋាភិបាល គេលែងចង់ធ្វើសង្គ្រាមទៀតហើយ គេនិយាយតែប៉ុននឹង ។

ដារ៉ា : ចុះដល់ពេលចុះមក តា ម៉ុក នៅណា?

សឿន : កាលនឹងយើងអត់ដឹង ព្រោះអីអត់បាននៅជាមួយគ្នាទេ យើងនៅក្នុងជំរំយូអ៊ិននឹង អត់ដឹងថាគាត់នៅណា អត់ដឹងសោះ ដឹងតែគេថ្នាក់ពីលើៗយើង ។

ដារ៉ា : តែចង់និយាយថា ពេលដែលឆ្នាំ៩៨ហើយនេះ ដែលពេលមានការប្រជុំនៅខាងលើភ្នំ ប្រជុំហើយដើម្បីចុះមកក្រោមនេះ ។ ចឹងពេលប្រជុំនឹង មិន តា ម៉ុក គាត់មិននៅលើភ្នំនឹងដែរ?

សឿន : នៅៗ ។

ដារ៉ា : ចឹងដល់ពេលប្រជាជន ឬកងទ័ពអីគេចុះមកក្នុងរួបរួមហើយចឹង តា ម៉ុក បើអត់យល់ព្រមជាមួយគេ ចឹងគាត់ទៅណា?

សឿន : យើងអត់ដឹងៗ គាត់ទៅណាមកណាអត់ដឹងទេ ។

ដារ៉ា : ហើយក្រោយមករហូតមកដល់សព្វថ្ងៃនឹង ពូដឹងយ៉ាងម៉េចដែរ អំពីព័ត៌មានទាក់ទងនឹង តា ម៉ុក នឹង?

សឿន : យើងមិនទាន់ដឹងអី ប៉ុនដឹងថាគាត់ស្លាប់តែប៉ុននឹង រឿងអីផ្សេងទៀតយើងអត់ដឹង ។

ដារ៉ា : ចុះមានការចាប់ តា ម៉ុក ចាប់អីយកទៅឃុំឃាំងនៅភ្នំពេញ អានឹងដឹងទេ?

សឿន : ដឹង ។

ដារ៉ា : ដឹងអន្តាល់?

សឿន : ដឹងពេលគេបញ្ជូនគាត់មកវិញ អីដឹងតាមទូរទស្សន៍ផ្សាយផ្ទាល់ ។

ដារ៉ា : ចុះកាលដែលបញ្ជូនគាត់ទៅភ្នំពេញ ជាការចាប់ខ្លួន ឬគាត់ប្រគល់ខ្លួនឲ្យគេចាប់ ព្រោះពេលនឹងគាត់អស់កងទ័ព ហើយប្រជាជនចុះមកក្រោមអស់ហើយ?

សឿន : មិនដឹងជាប្រគល់ មិនដឹងជាចាប់ ខ្ញុំអត់ដឹងដែរ ។

ដារ៉ា : ហើយមួយទៀតដែរ ទាក់ទងទៅនឹងការស្លាប់ការអីរបស់ សុន សេន តើពូអាចដឹងជារឿងរ៉ាវជុំវិញការស្លាប់នឹងខ្លះដែរទេ?

សឿន : អត់ដឹង ដឹងតែគេបាញ់សម្លាប់គាត់ចឹងម៉ង ដឹងប៉ុននឹង រឿងស្អីៗអត់ដឹងសោះ យើងវាមិនហ៊ានសួរនាំគេ ហើយដឹងតាមអ្នកណានិយាយប្រាប់ ក៏គេមិននិយាយប្រាប់យើង ។ គាត់នៅឆ្ងាយពីគ្នាដែរ ។ យើងនៅនេះ ហើយគាត់នៅលើភ្នំនោះ កន្លែងខុសគ្នាចឹង អត់ដឹងសោះ គ្រាន់ដឹងថា គេបាញ់សម្លាប់គាត់តែប៉ុននឹង ។ មិនដឹងជាថាអ្នកណាជាអ្នកទៅបាញ់ អត់ដឹងសោះ ។

ដារ៉ា : ពេលដែលដឹងដំណឹងថា មានការបាញ់សម្លាប់ សុន សេន ចឹង ថាតើនៅក្នុងមូលដ្ឋានភូមិរបស់ពូរស់នៅនេះ មានសភាពការណ៍ មានសភាពយ៉ាងម៉េចដែរ?

សឿន : វាមិនមានស្អីសោះ វាគ្រាន់ថាយើងមិនហ៊ានមាត់ ហ៊ានក មិនចង់សួរដេញដឹកបុសដេញដឹកគល់អី អត់ដឹង រឿងរ៉ាវអីយើងអត់ហ៊ានណា ។ ចឹងយើងនៅស្ងៀមស្ងាត់តែប៉ុននឹង យើងមិនហ៊ានថាយ៉ាងណាៗ ក៏យើងអត់មាត់ដែរ ។ តែមាត់ទៅវាមានការដូចថាខ្សែបណ្តាញអីទៀត ចឹងខ្ញុំនៅស្ងៀមៗ ។ ដល់ប្រជាជនយើង ទោះបីគាត់សោកស្តាយយ៉ាងម៉េចក៏គាត់មិនបញ្ចេញ ស្អប់ ស្រឡាញ់យ៉ាងម៉េច ក៏គាត់មិនបញ្ចេញ គាត់នឹកក្នុងចិត្តគាត់កាលនោះ ។

ដារ៉ា : ចុះរហូតមកដល់សព្វថ្ងៃ គាត់នៅតែលាក់អានឹងនៅក្នុងចិត្ត ឬក៏គាត់បើសិនជាសួរគាត់អាចនិយាយបានដែរ ឬក៏យ៉ាងម៉េច?

សឿន : មិនដឹងដែរ មិនដឹងចិត្តគាត់យ៉ាងណា ។ បើអ្នកគេនៅនេះតែម៉ង អាខ្លះគេថាគេសោកស្តាយដែរ មិនដឹងជាយ៉ាងណាៗ ទាល់ជីវិតមនុស្សម្នាក់ៗទោះបីយ៉ាងណាក៏យើងនៅមានការវា

មិនសមដែរ ធ្វើបាបគ្នាចឹង ។ អានឹងចិត្តខ្ញុំចឹងដែរនឹង វាមិនទំនងសោះ នឹកឃើញបានជាមានរឿងអី បានជាបាញ់សម្លាប់គ្នាដល់អស់ពូជចឹង នឹកស្រណោះអាណិតគាត់ដែរ អានឹងអារម្មណ៍ខ្ញុំទេ បើថាអ្នកដទៃទៀត មិនដឹងជាយ៉ាងណា ។ ទម្រាំអ្នកនៅជិតៗផ្ទាល់ៗ ក្បែរៗនឹងទៀត ដែលដឹងរឿងមិនដឹងជាគេមានចិត្តគាត់នឹងយ៉ាងណាទៀត ។

ដារ៉ា : ចុះពូពេលពី៨៤ មកឆ្នាំ៩៨ ទម្រាំមានការស្រុះស្រួលឡើងវិញចឹង ក្នុងចន្លោះពេលនឹងការរស់នៅអីយ៉ាងម៉េចដែរ មានលក្ខណៈខុសគ្នា បើធៀបជាមួយពី៨៤ មក៨១ ឬក៏ពី៧៥-៧៩?

សឿន : វាពី៧៥មក៧៩នឹង យើងប្រៀបធៀបវិញ វាខុសគ្នាឆ្ងាយ បើខ្ញុំរស់នៅខ្មែរក្រហមដែរទៀតនឹង បន្តពី៨១រហូតដល់៨៤ដល់៩៩-៩៨នឹង វាខុសគ្នាឆ្ងាយណាស់ ។ ដូចខ្ញុំនិយាយខាងដើមអារម្មណ៍របស់យើងក៏វាអត់មានភ័យខ្លាច ព្រួយបារម្ភអីយ៉ាងម៉េចៗ គឺអត់មានទេ បើថា ដូចមានខ្លះ បើថាធ្វើអ៊ំខុសអាងអីរត់ទៅក្នុងចឹង រត់ទៅខាងរដ្ឋកម្ពុជាៗក៏មានបញ្ហាអីសភាពការណ៍អីបែបមិនស្រួលខ្លួនឯងផ្ទាល់រត់មកនេះចឹងទៅ ដល់ចឹងប្រធានគេបន្ធូរៗអានឹងទៅ ប៉ុន្តែរឿងបន្ធូរនឹងក៏គេកាត់បន្ថយរឿងការខុសពីមុនឆ្ងាយដែរ ខុសគ្នាឆ្ងាយណាស់ ចឹងហើយគេអត់មានធ្វើអីអារម្មណ៍ឲ្យយើងភ័យខ្លាចអត់មានទៀតទេ ព្រោះអីតាំងពីបាតដើងរហូតដល់ចុងសក់ យើងអត់មានលំបាកធ្វើខ្លួនឯង ។ បើខ្ទះបីចេងស្រែក មីងៗស្រែក ដល់ចឹងទៅគាត់មើលសកម្មភាពខាងលើ ក៏គាត់អត់មានបញ្ហាដែរ គាត់ដោះស្រាយប្រជាជនដែរខោអាវស្លៀកមិនអស់ទាំងមីងទាំងពូ ទោះបីប្រជាជនក៏ដោយ ក៏ខោអាវកងទ័ពដែរ ។ ឯមីងសារុងសពុតាំងពីក្នុងតាំងពក្រៅឲ្យទាំងអស់ អត់មានសល់អី ដល់ចឹងអារម្មណ៍របស់គាត់ជ្រះស្រឡះជាងមុន ។

ដារ៉ា : ចំពោះលោកពូផ្ទាល់ តើលោកពូយល់ដឹង អាចយល់បាន ឬក៏ដឹងព័ត៌មានបានត្រឹមកម្រិតណា ពី តា ម៉ុក នោះ?

សឿន : មិនសូវយល់ដឹងទេ ។

ដារ៉ា : ដូចថា តា ម៉ុក ជាមនុស្សបែបណា ជាមនុស្សយ៉ាងម៉េច អាចយល់បានត្រឹមកម្រិតណាដែរ?

សឿន : មិនសន្និដ្ឋានបានទេ ព្រោះអីខ្ញុំជាអ្នកតាមដែលចង់ដឹងពីបញ្ហាស្អីៗសកម្មភាពអ៊ីៗខ្ញុំអត់យល់សោះ មិនដឹង ។

ដារ៉ា : ព្រោះបើភាគច្រើនទៅ តាមសួរនាំមក តា ម៉ុក ជាមនុស្សចិត្តល្អបេះ ល្អចុះ ។ បើតាមទស្សនៈពូផ្ទាល់ ពូយល់ឃើញម៉េចដែរ?

សឿន ៖ ហ៊ើ! អានឹងដឹងៗមែន អ្នកណាសុំអីឲ្យ គាត់ចិត្តល្អដែរ ឃើញតែគេសុំបាន សុំលុយបានលុយ ប្រពន្ធខ្ញុំនឹងអ្នកទៅរាយលុយ គាត់ដេរបញ្ចោលមែន ថាហ៊ឹង!ឯងលាក់លុយ ម៉េចហ៊ឹង!ឯងឲ្យអញឆែកមើល អ្នកណាខ្លាចឲ្យគាត់ឆែក អតទៅៗ អ្នកណាមិនខ្លាច គាត់លាក់បានចឹងទៅត្រឹម១០០០-២០០០បាតអីគាត់អត់ថាអី គាត់ចេះថាគាត់គំរាមៗយើង ខ្លាចយើងយកច្រើនៗ គាត់ចិត្តល្អដែរ អ្នកណាសុំអត់ អីសុំលុយបានលុយ សុំនាឡិកាបាននាឡិកា អានឹងយើងឃើញចឹងមែន ប៉ុនឲ្យស៊ីជំរៅទៅទៀត យើងមិនយល់ទេៗ

ដារ៉ា ៖ ចុះចំពោះជាមួយនឹងមេដឹកនាំផ្សេងៗទៀតដែរ ពូអាចដឹង ដូចពូដឹងពីរឿង តា ម៉ុក ចឹងដែរឬយ៉ាងម៉េច?

សឿន ៖ អឺ! ហ្នឹងវិតតែឆ្ងាយទៀត មិនសូវដែលស្គាល់ បានត្រឹមម៉ាឃើញៗ មនដូច តា ម៉ុក គាត់ខស្សាហ៍ទៅមកៗជាមួយជាប់ អាចនិយាយលេងជាមួយគាត់បានខ្លះៗ បើថាក្រៅពីនឹងទៀត អត់ដែលសោះ មិនដែលស្គាល់ទេៗ យើងស្គាល់ៗហើយ ប៉ុន្តែថាឲ្យវាជិតដិតស្គាល់គ្នាឲ្យពេញមែនទែននោះវាមិនស្គាល់ៗ

ដារ៉ា ៖ ចុះបើតាមយោបល់របស់ពូ ថាតើដូចថាមនុស្សប្រភេទណា ឬលំដាប់ណាដែលអាចដឹងរឿងរ៉ាវខាងលើៗ ដូចជាការធ្វើសមាហរណកម្ម ការផ្ដាច់ខ្លួន ឬក៏ដឹងពីព័ត៌មានរបស់មេដឹកនាំការសម្រេចចិត្ត ការធ្វើផែនការអីចឹង ត្រឹមថ្នាក់ណាដែលអាចយល់ដឹងពីបញ្ហានឹងបាន?

សឿន ៖ ថ្នាក់ណា ដូចមិនសូវដឹងដែរៗ

ដារ៉ា ៖ ព្រោះដូចថាយើងសរសេរប្រវត្តិអន្លង់វែងចឹង វាទាក់ទងទៅនឹងរចនាសម្ព័ន្ធ វាទាកទងទៅនឹងការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំពីមុនៗមកចឹង នៅក្នុងស្រុកអន្លង់វែង ក្នុងម៉ាជំនាន់ទៅម៉ាជំនាន់ៗ ចឹងបានខ្ញុំចង់ដឹងសួរ បើពូអត់ដឹងពីបញ្ហានឹងទេ តើមនុស្សប្រភេទណា លំដាប់ខ្ពស់ជាងពូប៉ុនណា ដែលអាចដឹងយើងសួរនាំទៅដែលអាចដឹងរឿងរ៉ាវខ្លះចឹង?

សឿន ៖ អឺ! មិនទាំងស្គាល់ ហើយមិនដងទៀតណា មិនដឹងជាថ្នាក់ណា អាចដឹងជាច្រើនទៅទៀតយើងថាទៅ ក្រែងលរគេមិនដឹង ពិបាកសន្និដ្ឋានចិត្តគំនិតគេ ដឹងគេទំនាយប្រាប់យើងហើយក៏យើងថាទៅវាខុសៗ ចឹងពិបាកសន្និដ្ឋាន ថាថ្នាក់ណាៗដែរ សំខាន់លើការជួបផ្ទាល់មកស្រាវជ្រាវ អាចក្រែងលរប៉ះៗ ហើយខ្ញុំស្រេចហើយ ចឹងបានថាមិនសូវជាចាប់អារម្មណ៍អីប៉ុន្មានទេៗ ទោះបី ធ្វើការរាល់ថ្ងៃនេះ ក៏ចឹងដែរ ខ្លះគេមកសួរថា ក្រសួងនេះប្រធានឈ្មោះអីស្រេច ខ្ញុំអត់ដឹងទេៗ ព្រោះអីខ្ញុំអត់ដែលបានមើលព័ត៌មានអីអត់ទេ ដឹងតែអង្គុយសំកុកធ្វើការងារ ដឹងតែម៉ាមុខប៉ុននឹង អត់មានចង់ដឹងរឿងច្រើនតទៅទៀតៗ ចឹងបានប្រជាជនខ្លះគាត់ថាៗនឹងត្រូវ ការងារដល់ថ្នាក់ប៉ុននឹងហើយ គ្មានដឹងស្អីសោះ ដូចជាមិន

ចង់ចាប់អារម្មណ៍តទៅទៀត ម៉េច ខ្ញុំរាល់ថ្ងៃៗ បើថាដឹងសម្តេចនាយក នាយករដ្ឋមន្រ្តីដឹង តែប៉ុននឹងៗ តិចទៅសួរថា ក្រសួងហិរញ្ញវត្ថុខ្ទង់ឯងរាល់ថ្ងៃកាន់បេនឡា-កឃុំប៉ុននឹង មិនដឹងជាអ្នកណា ពិតប្រាកដ ឃើញក្រដាស គាត ឈុន ក៏ គាត ឈុន ទៅវាពិបាកចឹងៗ

ដារ៉ា : ចុះពូដែលនិយាយរឿងរ៉ាវ ជាប្រវត្តិតស៊ូដែលពូប្រាប់កូនចៅពូទេ?

សឿន : ខ្ញុំធ្លាប់និយាយ ប៉ុននិយាយខ្លួនយើងផ្ទាល់ៗ តស៊ូអីយ៉ាងម៉េច ពីជំនាន់នេះនឹងមានវៃជាមួយនឹងកងទ័ពនេះកងទ័ពនោះចឹងទៅ និយាយបានពីប្រវត្តិរហូតដល់ប្រវត្តិដែលយើងលំបាកវេទនាអីក៏យើងនិយាយដែរៗ លំបាកខ្លះក៏វាឆ្ងាត កូនវាដេញដោល អ្នកណាធ្វើឲ្យប៉ាលំបាក ហ្នឹងហើយក៏ប្រាប់ទៅ ប្រាប់តាមដំណើរនឹងទៅ ក្នុងរបបប៉ុល ពត មានការលំបាកប៉ាហូបបបរ មកធ្វើការងាររលើសពីកម្លាំង ជាប្រវត្តិសាស្រ្តមួយដែលយើងគួរតែនិយាយប្រាប់កូនឲ្យកូនដឹងៗ

ដារ៉ា : ជាទូទៅកូនចៅពូពេលប្រាប់ចឹង មានជាប្រតិកម្មតបមកវិញយ៉ាងម៉េចដែរ តាមពូសង្កេត?

សឿន : វាថា អីក៏យោរយោម៉េះជំនាន់នឹងៗ វាថាតែប៉ុននឹង ដូចថាគេយកទៅសម្លាប់ គេយកយើងទៅដាក់គុកឲ្យយើងស្លាប់នៅក្នុងគុក ឲ្យយើងស្លាប់នៅក្នុងគុក គេប្រើយើងឲ្យយើងស្លាប់នៅកន្លែងការដ្ឋាន ធ្វើការងារ ចឹងមានដែរតើ និយាយប្រាប់ដំណើរកូនចឹងទៅៗ

ដារ៉ា : ទាក់ទងទៅនឹងការសរសេរប្រវត្តិសាស្រ្តអន្លង់វែងនេះដែរ បើសិនជាតាមគំនិតពូផ្ទាល់ តើពូចង់ឲ្យព័ត៌មានត្រង់ចំនុចណា ត្រង់កន្លែងណាខ្លះ ដែលបញ្ចូលទៅក្នុងការសរសេរសៀវភៅប្រវត្តិសាស្រ្តបែបនឹង សម្រាប់តែអន្លង់វែងរបស់ពូ?

សឿន : ដូចខ្ញុំ ហើយខ្ញុំមិនសូវយល់ដឹង ឲ្យសរសេរចំនុចណាៗ

ដារ៉ា : ដែលវាមានលក្ខណៈជាប្រវត្តិសាស្រ្ត ពាក់ព័ន្ធទៅនឹងស្រុកអន្លង់វែងរបស់ពូរស់នៅសព្វថ្ងៃនេះ?

សឿន : អានឹងយើងពិបាកយល់ដែរៗ ចង់ឲ្យសរសេរម៉េច ជាប្រវត្តិពីការរស់នៅរបស់ប្រជាពលរដ្ឋហើយនឹងការលំបាកវេទនារបស់ប្រជាពលរដ្ឋដែលមានកន្លងមក ប៉ុននៅក្នុងស្រុកអន្លង់វែងយើងនឹង ដូចជារឿងលំបាកវេទណាដូចជាមិនមានទេ ក្រោយពីដែលរដ្ឋកម្ពុជាវៃរបបប៉ុលពតដួលរលំមកណា៎ៗ មករស់នៅជាមួយ ប៉ុល ពត តទៅនឹងក៏វាមិនមានអីលំបាកវេទនាដែរ វាមិនដូចពីជំនាន់៧៥មកដល់យើង៧៨ៗ ហ្នឹងបានថារកនឹកវាមិនឃើញចង់សរសេរកន្លែងណា ដែលវាមានចំនុចល្អ សំខាន់ៗសម្រាប់ប្រជាពលរដ្ឋយើងអន្លង់វែងយើងនេះចាប់អារម្មណ៍ រកនឹកវាមិនឃើញៗ មានតែប្រវត្តិអីដែលវាល្អៗ ចង់ចងក្រងអីដែលវាមានសភាពល្អៗចឹងទៅ ហើយវាការលំបាកវេទនាវាតែងតែមានហើយ រស់នៅ វាមិនអត់ទេ

លំបាកវេទនា ។ ក្រោយមកទៀតនឹង វាមានសាច់ហើមសាច់ស្អុយដូចខ្ញុំប្រាប់នៅទួលគ្រួស គេយកទៅដាក់នៅនឹងឯង ។ ពីដំបូងគេហៅយកអ្នកលក់ដូរ តា ម៉ុក ប្រមូលដាក់នឹងមិនឲ្យរកស៊ីទេ គេហៅចិនឃុំ ពីដំបូង ។ ចិនឃុំ នៅភូមឯមុខ នៅក្នុងឃុំអូរស្វាយនោះ ។ ដល់មកទៀតនឹង សាច់ហើម សាច់ស្អុយនឹង គឺអ្នកធ្វើទាហានរដ្ឋកម្ពុជារត់ចូលមកនៅនេះប្រមូលយកមកដាក់នឹង អ្នករកស៊ីដែលណែនាំមិនស្តាប់ យកទៅដាក់នឹង ។ អានឹងការលំបាកវេទនារបស់ប្រជាជនក៏មានដែរ ហើយនឹងបិទចំរូងបិទអីនឹង ប្រវត្តិដែលថាវាដូរចក់វាមានប៉ុននឹងប៉ុនវាមិនមានខ្លាំងក្លាប៉ុន្មានទេ ។

ដារ៉ា : ទៅតាមការដែលពូអាចយល់ដឹងបាន សមាសភាពជា សាច់ហើម សាច់ស្អុយនឹង អាចថាមានច្រើនទេ?

សឿន : ច្រើនណាស់ សូម្បីតែមេឃុំនេះក៏សាច់ហើមសាច់ស្អុយដែរ កាលនឹងប្រវត្តិគាត់នឹងអ្នកគេយកទៅដាក់ទួលគ្រួស ។

ដារ៉ា : ទៅដល់នឹង គេឲ្យធ្វើស្អីនៅកន្លែងនឹង?

សឿន : គេមិនមានឃុំឃាំងយើង មិនវាស់ទីវាស់វាលឲ្យយើងដើរទេ គេប្រើយើងធម្មតាដដែលៗ ប៉ុនគ្រាន់ថា កន្លែងនឹងគេយកទៅដាក់មុំចឹងទៅ ដូចថាកន្លែងអប់រំកសាង ។ ប៉ុនទៅធ្វើការគ្នាវ៉ៃនៅសមរភូមិដូចគ្នាដដែលៗ យកទៅដាក់មុំៗ ។

ដារ៉ា : ចុះសិទ្ធិសេរីភាព អ្នកដែលចាត់ទុកថាសាច់ហើមសាច់ស្អុយនឹង ជាមួយនឹងអ្នកស្រុកអ្នកភូមិធម្មតាអីដែលមិនចាត់ទុកចឹង វាមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ?

សឿន : វាមិនមានស្អី នៅតែរាប់រងគ្នា អត់មានបែងចែកអីទេ នៅតែរាប់រកគ្នាទៅមកៗដើរទៅដើរមកឆ្លងគ្នាទៅលេងទៅវិញទៅមកបាន អត់មានបែងចែកអីអត់ទេ ។ វាសំខាន់តែ តា ម៉ុក គាត់ថាអាណាជាគិញ ជាអីអានឹងខ្លាំងហើយ តា ម៉ុក មិនទុកទេ កាលជំនាន់នោះ មានសម្លាប់ដែរតើ មិនថាអត់ទេ ។

ដារ៉ា : ហើយក្រោយមក អ្នកទាំងអស់នឹងពេលសមាហរណកម្មហើយមក ចូលមកដូចថាជាប្រតិកម្មតបអីជាមួយ តា ម៉ុក អីដែរ?

សឿន : អត់ៗមានអ្នកណាប្រតិកម្មអី ដែលថាវាយើងប្រតិកម្មទៅ មិនដឹងបានអីមកវិញ បើថាវាមានជាប់ទាក់ទិនបងប្អូនអ៎ទៅ ក្រែងលរគេគិតគូ បើយើងអត់មានអីផង ក្នុងក្រុមគ្រួសារយើង បងប្អូនយើងអត់មានពាក់ព័ន្ធជាមួយគាត់ដែរ ធម្មតាដែរ ទាំងអស់គ្នានឹង ។

ដារ៉ា : រឿងសាច់ហើមសាច់ស្អុយនឹងសម្រាប់ តា ម៉ុក ម្នាក់ឯង ឬក្នុងចង្កោមមេដឹកនាំខ្មែរក្រហមទាំងអស់?

សឿន : នឹងទាំងអស់នឹង ព្រោះអីការរៀបចំចងក្រងជាច្បាប់នឹងហើយ គឺអនុវត្តទាំងអស់គ្រប់កងពល

ដារ៉ា : ច្បាប់ទម្លាប់ចេញមកពីណា?

សឿន : ចេញមកពីខាងលើនឹង តាៗទាំងអស់នឹង ចេញមក គាត់ធ្វើមក ទាល់តែមកពីនឹងមក មានអ្នកអនុវត្តន៍ទៅ បើអត់មានទេ គ្មានអ្នកណាហ៊ានធ្វើទេ ។

ដារ៉ា : ចុះពេលពូមកដល់រស់នៅអន្លង់វែងនឹង មានធ្លាប់ឮឈ្មោះ ខៀវ សំផន អី, នួន ជា ហើយនឹងប៉ុល ពត?

សឿន : ឮតើ ។

ដារ៉ា : ឮញឹកញាប់ដែរ?

សឿន : បាទ! ឮៗសូរ យើងស្តាប់វ៉ាដ្យូទៅ វ៉ាដ្យូខ្មែរក្រហម ស្តាប់តាមវ៉ាដ្យូ ហើយតាមនឹងយើងឮសូរតាមមេៗដែលបានទៅរៀនសូត្រទៅជួបផ្ទាល់ៗ គេមកគេនិយាយប្រាប់យើងចឹងទៅឮតាមនឹងខ្លះទៅ ។

ដារ៉ា : ភាគច្រើនប្រាប់ពីរឿងអី?

សឿន : គេប្រាប់ថ្នាក់គេធំៗគេនិយាយថា គេមកពីប្រជុំជាមួយអ្នកនេះ អ្នកនោះតែប៉ុននឹងរឿងអីៗទៀតគេអត់មានទេ ព្រោះអីយើងជាសាមញ្ញអីចឹងទៅគេមិនសូវនិយាយទេ គេខ្លាចបែកការណ៍ គិតយោងតែអាត្មារៀងៗខ្លួនទេម៉ាជំនាន់នោះ ។

ដារ៉ា : រហូតមកដល់ពេលនេះអីចឹង យើងបានរស់នៅដោយសុខស្រួលហើយ ពូគិតថាប្រជាជនសាមញ្ញយើងដែលរស់នៅក្នុងភូមិក្នុងឃុំនឹង គាត់នៅតែមានអារម្មណ៍ខ្លាចមេខ្លាចកើយដែលពីមុនមក ជាទាហានជាអីចុះមកតាមលំដាប់លំដោយចឹងដែរ?

សឿន : រាល់ថ្ងៃនេះ?

ដារ៉ា : បាទ! រាល់ថ្ងៃហ្នឹង ។

សឿន : មិនមានអីគួរឲ្យខ្លាចល្អែងទៀតទេ យើងការងារយើងគិតទៅតាមការងារទៅ អត់មានស់អ្នកនេះធំ អ្នកនេះតូចខ្លាចគោរពស្អី ។ ប៉ុនយើងគោរពសិទ្ធិអំណាចរបស់គេ យើងគោរពដែរណា ។ ប៉ុនថាឲ្យខ្លាចខ្លាំងក្លា យើងមិនខ្លាចទេ យើងគោរពជាមេ ប៉ុនគាត់ថាមិនបានធ្វើជាមេបន្តទៅទៀតនឹង ក៏យើងនៅតែគោរពគាត់នៅដដែល ដូនកាលគាត់ចាស់ ដូចអ៊ំ ប៊ូច ចឹងគាត់ជាចាស់ទុំមួយ យើងគោរពគាត់ទៅ ។ ថាឲ្យគាត់នឹងមានអំណាចអីមកលើយើងទៀតវាអត់មានទេស ។ ប៉ុនគ្រាន់យើងដឹងថា គាត់ពីមុនមកជាមេរបស់យើងមួយដែរ យើងគួរតែគោរពគាត់ជាចាស់ជាទុំតទៅទៀត ប៉ុននឹង ។

ដារ៉ា : ព្រោះខ្ញុំសួរអោយថា អ្នកស្រុកអ្នកភូមិ ដែលគាត់ធ្លាប់រស់នៅជាមួយខ្មែរក្រហមពីមុនមកអីចឹង ហើយទោះបីក្រោយមក មករសនៅជាលក្ខណៈជាប្រជាជន ប៉ុន្តែមានជាកងទ័ពគ្រប់គ្រងពីលើចឹង ចឹងពេលដែលមកធ្វើសមាហរណកម្មហើយ ក្រែងលរថាគាត់អាចនៅមានការគោរពជាបទបញ្ជាទ័ពអីចឹង ។ តើបញ្ហានឹង នៅអាចមានចឹងទេ?

សឿន : អត់មាន ។ យើងរាល់ថ្ងៃនេះ យើងរស់នៅរៀបចំជាភូមិឃុំរបស់យើង ហើយយើងអនុវត្តទៅតាមគោលការណ៍របសរាជរដ្ឋាភិបាលយើង ច្បាប់ ។

ដារ៉ា : ចឹងនៅក្នុងភូមិពូនេះ ជាការអនុវត្តន៍ច្បាប់ ឬបទបញ្ជាផ្សេងៗរបស់រដ្ឋាភិបាលនៅក្នុងតំបន់ដូចថាជាអតីតតំបន់ខ្មែរក្រហមយើងនិយាយចឹង ថាតើយើងមានជួបបញ្ហាការលំបាក ឬក៏បញ្ហាប្រឈមអីខ្លះដែរទេ?

សឿន : នេះ មិនមានលំបាកអី យើងការអនុវត្តន៍ច្បាប់របស់រាជរដ្ឋាភិបាលយើង ហើយបញ្ហាប្រឈមច្បាប់ក៏យើងមានដែរ ក្មេងខូចខិល ឬក៏ស្អីៗផ្សេងៗវាមានប្រឈមនឹងច្បាប់ វាមិនលំបាកអីយើងអ្នកអនុវត្តន៍ទេ វាមិនលំបាក ។

ដារ៉ា : ចុះបញ្ហាចឹងមានទេ នៅពេលចន្លោះឆ្នាំ៨១មកដល់៩៨នេះ នៅពេលដែលខ្មែរក្រហមនៅគ្រប់គ្រងនៅឡើយ?

សឿន : យើងវាមានដែរតើជំនាន់នោះ រឿងអ្នកប្រព្រឹត្តិខុស យើងមិននិយាយថាខ្សែស្រឡាយស្អីៗទេ សំខាន់គឺអ្នកដែលអនុវត្តន៍អីៗ ដូចថាបាញ់សម្លាប់គ្នា លួចធ្វើយាដគ្នា ហើយឡើងប្រពន្ធគេ ចាប់កូនក្រមុំគេ អានឹងចាប់ដូចគ្នានឹងឯង ។ យើងអនុវត្តដូចតែគ្នា បើយើងមិនធ្វើយើងការពារប្រជាជនអត់បានទេ ។ ចឹងហើយខាងនេះគេចាប់ដែរនឹង ខ្លះគេចាបយកទៅដាក់គុកចឹងទៅ ដាក់គុកនឹងនៅទួលគ្រួសនឹង មានសិទ្ធិសេរីភាពធម្មតាណាស ប៉ុនគេយកទៅដាក់ឲ្យឆ្ងាយៗទៅ ។

ដារ៉ា : ខ្ញុំដូចអត់មានអីបន្ថែមទេ ក្រែងលរពូ ពិនិត្យមើលទៅថាដោយសារតែខ្ញុំសម្ភាសន៍ចង់បានព័ត៌មានសរសេរប្រវត្តិសាស្ត្រអន្លង់វែង រួចពូពិនិត្យឃើញថាវាមានការខ្វះចន្លោះកន្លែងណាដែលពូអត់ទាន់បានបន្ថែមអីទេ ពូអាចមានបន្ថែមបាន ។ ពូអាចមានកន្លែងណាបន្ថែមទៀតទេ?

សឿន : បាទ!អត់មានទេ ។ ខ្ញុំដែលគោលបំណងរបស់ខ្ញុំៗចង់បានដែរ ប្រវត្តិសាស្ត្រអន្លង់វែង ប៉ុន្តែបើមានក្នុងអារម្មណ៍របស់ខ្លួនខ្ញុំនឹង ក៏អត់មានមតិអីជួយផ្តល់អីថាកន្លែងណាៗ យ៉ាងណាៗអត់មាន ប៉ុនចង់បាន ។

ដារ៉ា : ចង់បាន?

សឿន ៖ បាទ! ចង់បាន ចង់ដឹង ភាគច្រើនចង់ដឹង ចង់បានដែរ ។

ដារ៉ា ៖ តែអានឹងជួយជាប្រយោជន៍ពូយ៉ាងម៉េចដែរ?

សឿន ៖ វាអាចយើងមានប្រយោជន៍មួយ យើងនៅចងចាំប្រវត្តិសាស្ត្រ យើងចេះដឹងប្រវត្តិសាស្ត្រ ដែលយើងអត់ដឹង គឺមកដឹងវិញ បាទ! មានតែចឹង ។

ដារ៉ា ៖ រឿងការដឹង ជាធម្មតាពេលយើងចងក្រងជាសៀវភៅប្រវត្តិសាស្ត្រចឹង យើងអាចហើយ យើងដឹង ។ ប៉ុន្តែ ចេញពីការដឹង វាជួយអីពូបានខ្លះ អំពីការដឹងប្រវត្តិសាស្ត្របែបនឹង ជាប្រយោជន៍ សម្រាប់ពូក៏ដោយ សម្រាប់សហគមន៍ពូក៏ដោយ សម្រាប់កូនចៅពូក៏ដោយ វាជាប្រយោជន៍យ៉ាងម៉េច?

សឿន ៖ វារឿងប្រយោជន៍នឹង ខ្ញុំមើលវាមិនទាន់ឃើញ ប៉ុនបើប្រយោជន៍នឹងយើងដឹងប្រវត្តិសាស្ត្រ នឹងទៅយើងអាចរំលឹកឡើងវិញ រាល់ការដែលយើងភ្លេចភ្លាំងទៅ អានឹងជាផលប្រយោជន៍ មួយដែរ ។ ផលប្រយោជន៍មួយទៀត ទៅវាអាចថាវាមានការពាក់ព័ន្ធសំខាន់មកលើយើង អីចឹងទៅ យើងអាចមានការពិគ្រោះយោបល់អីទៅ អានឹងអារម្មណ៍ខ្ញុំ ចិត្តខ្ញុំ ។

ដារ៉ា ៖ ពូចឹងខ្ញុំអស់មានសំនួរហើយ ខ្ញុំអរគុណពូច្រើនមែនទែន ដែលពូបានចំណាយពេលវេលា សម្រាប់បទសម្ភាសន៍នេះ ។ ខុសត្រូវអីសុំអភ័យទោសផង ព្រោះដូចថាខ្ញុំបានចំណាយពេល វេលា ដូចថាយកពេលវេលាពូអស់ច្រើនមែនទែន រហូតដល់ម៉ោង១ម៉ោង២ចឹង ។ បាទ! សុំអភ័យទោសផង ហើយក៏សុំអរគុណពូដែរ ។

សឿន ៖ បាទៗ ។

«ចប់»